ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport


វិទ្យាស្ថានជាតិអប់រំ

National Institute of Education


# និក្ខេបបទ

# ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំ នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្ដាល

## SITUATION OF PERSONNEL CAPACITY DEVELOPMENT AT SECONDARY RESOURCE SCHOOLS IN KANDAL PROVINCE


កង កុសល

KANG KOSAL


ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩

ឯកទេស៖ គ្រប់គ្រងអប់រំ

ឆ្នាំសិក្សា ២០២១-២០២២

ក្រសួងអប់រំ យុវជន និងកីឡា

Ministry of Education, Youth and Sport

វិទ្យាស្ថានជាតិអប់រំ

National Institute of Education

# និក្ខេបបទ

# ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំ នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្តាល

SITUATION OF PERSONNEL CAPACITY DEVELOPMENT AT SECONDARY RESOURCE SCHOOLS

IN KANDAL PROVINCE

**កង កុសល**

KANG KOSAL

**ដើម្បីបំពេញលក្ខខណ្ឌបញ្ចប់ការបណ្តុះបណ្តាល**

**ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩**

**ឯកទេស៖ គ្រប់គ្រងអប់រំ**

**ឆ្នាំសិក្សា ២០២១-២០២២**

**គ្រូណែនាំគោល៖ បណ្ឌិត អៃ សុខហ៊ាង**

**គ្រូណែនាំរង៖ បណ្ឌិត ឈាង សឡាត**

# សេចក្តីអះអាងរបស់បេក្ខជន

ខ្ញុំបាទ **កង កុសល** សូមបញ្ជាក់ថា និក្ខេបបទស្រាវជ្រាវដែលមានចំណងជើងថា «**ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្តាល**» សម្រាប់បំពេញលក្ខខណ្ឌសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំ ពិតជាស្នាដៃរបស់ខ្ញុំបាទទាំងស្រុង។ ស្នាដៃនេះពុំទាន់បានប្រើប្រាស់ដើម្បីបំពេញលក្ខខណ្ឌសិក្សាសម្រាប់ទទួលសញ្ញាបត្រនៅវិទ្យាស្ថាននេះ ឬសាកលវិទ្យាល័យណា ឬវិទ្យាស្ថានថ្នាក់ស្មើណាមួយនៅឡើយទេ។ ពុំមានសេចក្តីដកស្រង់ ឬខ្លឹមសារអ្វីមួយត្រូវបានប្រើប្រាស់ក្នុងអត្ថបទស្រាវជ្រាវនេះ ដោយគ្មានការអនុញ្ញាតពីអ្នកនិពន្ធ ឬចុះបញ្ជីឯកសារយោងឡើយ។ និក្ខេបបទស្រាវជ្រាវខាងលើនេះពិតជាត្រូវបានស្រាវជ្រាវនិងចងក្រងដោយខ្ញុំបាទ ពិតប្រាកដមែន។

ថ្ងៃ អង្គារ ៦កើត ខែមិគសិរ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ,ថ្ងៃទី ២៩ ខែវិច្ឆិកា ឆ្នាំ២០២២

**ហត្ថលេខា**

**កង កុសល**

# លិខិតបញ្ជាក់

**បណ្ឌិត** **អ៉ែ សុខហ៊ាង** ជាគ្រូណែនាំគោល

**បណ្ឌិត** **ឈាង សទ្ធាត** ជាគ្រូណែនាំរង

## សូមបញ្ជាក់ និងទទួលស្គាល់ថា

លោក **គង កុសល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ពិតជាបានសរសេរនិក្ខេបបទស្រាវជ្រាវស្តីពី«**ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំនៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្ដាល**» ពិតប្រាកដមែន។

ថ្ងៃ ពុធ ១០កើត ខែ មិគសិរ ឆ្នាំ ខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ២០២២



**បណ្ឌិត អ៉ែ សុខហ៊ាង**

ជាគ្រូណែនាំគោល



**បណ្ឌិត ឈាង សទ្ធាត**

ជាគ្រូណែនាំរង

# លិខិតឧទ្ទេសនាមគណៈកម្មការវាយតម្លៃការការពារនិក្ខេបបទ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
**លេខ:៣៧០២៥..អយក.ខ៩ន**

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

ថ្នាក់ដឹកនាំ និងបុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំង ជា **គណៈកម្មការមេប្រយោគ** សម្រាប់ការការពារនិក្ខេបបទថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-ឯកឧត្តមបណ្ឌិតសភាចារ្យ | ហង់ជួន ណារ៉ុន | ខុទ្ទកាល័យ អយក | ប្រធាន |
| ២-ឯកឧត្តមបណ្ឌិតសភាចារ្យ | ណាត ប៊ុនរឿន | ខុទ្ទកាល័យ អយក | អនុប្រធាន |
| ៣-ឯកឧត្តម | យក់ ង៉ុយ | ខុទ្ទកាល័យ អយក | សមាជិក |
| ៤-ឯកឧត្តម | ឈាង សេងហាក់ | ខុទ្ទកាល័យ អយក | សមាជិក |
| ៥-ឯកឧត្តម | ម៉ក់ ង៉យ | អគ្គនាយកដ្ឋានឧត្តមសិក្សា | សមាជិក |
| ៦-ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | សមាជិក |
| ៧-ឯកឧត្តមបណ្ឌិត | ឌី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៨-ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៩-ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | សមាជិក |
| ១០-ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យរាជធានីភ្នំពេញ | សមាជិក |
| ១១-លោកបណ្ឌិត | ឈូក ច័ន្ទឆាយា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | ឌី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោកបណ្ឌិត | នូវ រ៉ា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | សមាជិក |
| ១៥-លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ១៦-លោកបណ្ឌិត | អ៊ែ សុងហ៊ាង | SEAMEO TED អយក | សមាជិក |
| ១៧-លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ១៨-លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | នី វង្សា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០-លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១-លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២-លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣-លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

ឯកឧត្តម លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតនៅថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែ កត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន**

**កន្លែងទទួល៖**

- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងអប់រំ យុវជន និងកីឡា**
លេខ:..៣៧៦២៦..អយក.ទុ៤ន

(**ការសម្ងាត់**)

## លិខិតឧទ្ទេសនាម

យោង៖ ផែនការអនុវត្តកម្មវិធីបណ្ដុះបណ្ដាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

បុគ្គលិកអប់រំ នៃក្រសួងអប់រំ យុវជន និងកីឡា ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទ** ថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

| | | | |
|---|---|---|---|
| ១-លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២-លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣-លោកបណ្ឌិត | អាន រ៉ូប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤-លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៥-លោកបណ្ឌិត | សោន វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៦-លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៧-លោកបណ្ឌិត | លី គីមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៨-លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៩-លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១០-លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១១-លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១២-លោក | លឹម ភ៉ន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៣-លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៤-លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៥-លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៦-លោកស្រីបណ្ឌិត | ឡឹយ សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៧-លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៨-លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ១៩-លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២០.លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២១.លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២២.លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៣.លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៤.លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ២៥.លោកស្រី | ឯម សុភាលក្ខី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២២០ ៦៧៣ / ២២០ ៣០៤ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០ / ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / administration@moeys.gov.kh គេហទំព័រ : www.moeys.gov.kh

លោក លោកស្រី ដូចមានរាយនាមខាងលើ ត្រូវអញ្ជើញមកវាយតម្លៃការការពារនិក្ខេបបទរបស់និស្សិតពីថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ ចាប់ពីម៉ោង៧:៣០នាទីព្រឹកតទៅ នៅវិទ្យាស្ថានជាតិអប់រំ។

ថ្ងៃ ចន្ទ ៧កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី ៣១ ខែតុលា ឆ្នាំ២០២២
**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

**បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន**

កន្លែងទទួល៖
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- គ្រប់អង្គភាព ពាក់ព័ន្ធក្រោមឱវាទទីស្តីការក្រសួងអប់រំ យុវជន និងកីឡាដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីខ្លួន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ - ឯកសារ វជអ

# សេចក្តីថ្លែងអំណរគុណ

ជាបឋមខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុតចំពោះក្រសួងអប់រំ យុវជន និងកីឡា វិទ្យាស្ថានជាអប់រំ និងមូលនិធិគាំទ្រការអប់រំអន្តរជាតិនៅកម្ពុជា(CIESF) ដែលបានរៀបចំផ្តល់អាហាររូបករណ៍ដល់ខ្ញុំបាទដើម្បីបានចូលរៀនថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំនៅវិទ្យាស្ថានជាតិអប់រំជំនាន់ទី៩ រហូតដល់បានបញ្ចប់ដោយជោគជ័យ។

ខ្ញុំបាទក៏សូមគោរពថ្លែងអំណរគុណដល់ឯកឧត្តមនាយក លោកនាយករង លោក លោកស្រីដែលជាសាស្ត្រចារ្យ និងលោកគ្រូ អ្នកគ្រូនៅវិទ្យាស្ថានជាតិអប់រំទាំងអស់ដែលបានចំណាយកំលាំងកាយចិត្តយកចិត្តទុកដាក់ក្នុងការបណ្តុះបណ្តាលចំពោះរូបខ្ញុំបាទតាំងពីថ្ងៃចាប់ផ្តើមដំបូង រហូតទទួលបានជោគជ័យដូចថ្ងៃនេះ។ ខ្ញុំបាទក៏មិនអាចបំភ្លេចបាននូវការដឹងគុណជូនចំពោះ **បណ្ឌិត អ៊ែ សុខហ៊ាង** ជាគ្រូណែនាំគោល និង **បណ្ឌិត ឈាង សទ្ធាត** ជាគ្រូណែនាំរង បានចំណាយពេលវេលាដ៏មានតម្លៃជួយបង្ហាត់បង្ហាញ លើផ្នែកបច្ចេកទេស វិធីសាស្ត្រនៃការរៀបចំ និងផ្តល់ជាធាតុចូលសំខាន់ៗសម្រាប់ដំណើរការនៃ សំណេរ ស្រាវជ្រាវ ព្រមទាំងមេរៀនដែលទាក់ទងក្នុងមុខវិជ្ជាមួយចំនួននៅក្នុងឯកទេសគ្រប់គ្រងអប់រំ និងផ្តល់កម្លាំងចិត្តសម្រាប់ជារៀងរហូតមកដល់ខ្ញុំបាទជាច្រើន។

ខ្ញុំបាទពិតជាមិនអាចបំភ្លេចបានក្នុងការបង្ហាញនូវសេចក្តីដឹងគុណចំពោះ លោកគ្រូ អ្នកគ្រូនៃសាលារៀនធនជាន ដែលបានចូលរួមផ្តល់ទិន្នន័យតាមរយៈកម្រង់សំណួរ ដល់ខ្ញុំបាទដើម្បីឱ្យការប្រមូលទិន្នន័យ និងការសរសេរនិក្ខេបបទនេះទទួលបានជោគជ័យ។ ខ្ញុំបាទសូមគោរពអគុណចំពោះក្រុមគ្រួសារមិត្តភក្តិដែលបានគាំទ្រ និងលើកទឹកចិត្តឱ្យខ្ញុំបាទបន្តការសិក្សាដើម្បីអភិវឌ្ឍលើជំនាញអប់រំនេះអោយកាន់តែប្រសើរឡើង។

ជាទីបញ្ចប់ខ្ញុំបាទសូមគោរពជូនពរចំពោះឯកឧត្តម លោក លោកស្រីសាស្ត្រចារ្យ លោកគ្រូ អ្នកគ្រូនាងកញ្ញា និងមិត្តរួមជំនាន់ទាំងអស់សូមមានសុខភាពល្អ កម្លាំងកាយមាំមួន ជោគជ័យគ្រប់ភារកិច្ច និងសូមទទួលបាននូវពុទ្ធពរទាំងបួនប្រការគឺ អាយុ វណ្ណៈ សុខៈ និងពលៈកុំបីឃ្លៀងឃ្លាតឡើយ។

សូមអរគុណ!

# មាតិកា

**សេចក្តីអះអាងរបស់បេក្ខជន** ............ ii

**លិខិតបញ្ជាក់** ............ iii

**សេចក្តីថ្លែងអំណរគុណ** ............ viii

**បញ្ជីតារាង** ............ xi

**បញ្ជីរូបភាព** ............ xii

**មូលន័យសង្ខេប** ............ xiii

**ជំពូកទី១៖ សេចក្តីផ្តើម** ............ 1

១.១. លំនាំបញ្ហានៃការស្រាវជ្រាវៈ ............ 1

១.២. ចំណោទបញ្ហានៃការស្រាវជ្រាវៈ ............ 3

១.៣. គោលបំណងនៃការស្រាវជ្រាវៈ ............ 4

១.៤. សំណួរស្រាវជ្រាវ ............ 5

១.៥. សារៈសំខាន់នៃការស្រាវជ្រាវៈ ............ 5

១.៦. ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវៈ ............ 5

១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ............ 6

**ជំពូកទី ២៖ រំលឹកទ្រឹស្តី** ............ 8

២.១.ស្ថានភាពទូទៅក្នុងខេត្តកណ្តាល ............ 8

២.២. និយមន័យ ............ 10

២.៣ វិធានការកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ............ 13

២.៤ ផែនការយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ យុវជន និងកីឡា ២០១៩-២០២៣ ............ 14

២.៥. លក្ខណៈវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាន ............ 15

២.៦ ទ្រឹស្តីនៃការគ្រប់គ្រង និងដំណើរការអគារធនធាន ............ 16

២.៧ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន ............ 18

២.៨ ស្ថានភាពនៃបច្ចេកវិទ្យាក្នុងវិស័យអប់រំ កម្ពុជា ............ 19

២.៩ សមត្ថភាព និងតួនាទីគ្រូបង្រៀន ............ 25

**ជំពូកទី ៣៖.វិធីសាស្ត្រស្រាវជ្រាវ** ............ 31

៣.១ វិធីសាស្ត្រស្រាវជ្រាវ ........ 31
៣.២ គម្រោងវិភាគ ........ 31
៣.៣  ការសិក្សាស្រាវជ្រាវតាមបរិមាណវិស័យ ........ 32
៣.៣.១ ទំហំសំណាក និងការធ្វើសំណាក ........ 32
៣.៣.២. ឧបករណ៍សម្រាប់ការស្រាវជ្រាវៈ ........ 33
៣.៣.៣ កម្រិតចង្អុលបង្ហាញ ........ 34
៣.៣.៤ កម្រងសំណួរ ........ 35
៣.៣.៥ ការប្រមូលទិន្នន័យ ........ 35
៣.៣.៦ ការវិភាគទិន្នន័យ ........ 36
៣.៤ ក្រមសីលធម៌នៃការស្រាវជ្រាវ ........ 37
**ជំពូកទី៤ៈ.លទ្ធផល  និងការពិភាក្សា** ........ 38
៤.១. ទិន្នន័យពីព័ត៌មានទូទៅរបស់គ្រូបង្រៀន ........ 38
៤.១.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន ........ 38
៤.២. លទ្ធផលនៃការសិក្សាស្រាវជ្រាវ ........ 43
៤.២.១. ទិន្នន័យពីការឆ្លើយតបរបស់គ្រូបង្រៀន ........ 43
៤.៣ ការពិភាក្សា ........ 48
**ជំពូកទី ៥ៈ សេចក្តីសន្និដ្ឋាន និងសំណូមពរ** ........ 54
៥.១. សេចក្តីសន្និដ្ឋាន ........ 54
៥.២. សំណូមពរ ........ 55
**ឯកសារយោង** ........ 57
**ឧបសម្ព័ន្ធ** ........ 60
ឧបសម្ព័ន្ធ«ក» ........ 60
ឧបសម្ព័ន្ធ«ខ» ........ 67
ឧបសម្ព័ន្ធ«គ» ........ 69

# បញ្ជីតារាង

តារាង២.១៖ ចំនួនបុគ្គលិកអប់រំក្នុងឆ្នាំសិក្សា២០២១-២០២២……………………………………………..8

តារាង២.២៖ ស្ថិតិចំនួនសាលារៀនក្នុងឆ្នាំសិក្សា២០២១-២០២២……………………………………….9

តារាង២.៣៖ ស្ថិតិចំនួនសិស្សឆ្នាំសិក្សា ២០២១-២០២២……………………………………………..9

តារាង២.៤៖ រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងស.ម.ធ និងបណ្ដាញ គណៈគ្រប់គ្រងស.ម.ធ ព្រមទាំងគណៈគ្រប់គ្រងអគាធនធាន……………………………………………………………………………16

តារាង៣.១៖ គម្រោងស្រាវជ្រាវរៀបរាប់ពីវិធីសាស្ត្រតាមបរិមាណវិស័យ……………………………32

តារាង៣.២៖ ចំនួនសំណាកនៃការចុះប្រមូលទិន្នន័យ……………………………………………………33

តារាង៤.១៖ ចំណេះដឹងផ្នែកបច្ចេកវិទ្យា…………………………………………………………………..44

តារាង៤.២៖ ចំណេះដឹងផ្នែកគរុកោសល្យ………………………………………………………………..45

តារាង៤.៣៖ ចំណេះដឹងផ្នែកខ្លឹមសារមេរៀន……………………………………………………………47

តារាង៤.៤៖ សរុបពីកម្រិតយល់ដឹងរបស់គ្រូបង្រៀន…………………………………………………48

# បញ្ជីក្រាប

ក្រាប៤.១៖ ចំនួនសំណាក……………………………………………………………………………...…….38

ក្រាប៤.២៖ បង្ហាញពីកម្រិតវប្បធម៌របស់អ្នកចូលរួម………………………………………..….....39

ក្រាប៤.៣៖ បង្ហាញពីបទពិសោធន៍ការងាររបស់អ្នកចូលរួម………………………………………..40

ក្រាប៤.៤៖ បង្ហាញពីកម្រិតក្របខណ្ឌនិងមុខវិទ្យាបង្រៀន……………………………..………..41

ក្រាប៤.៥៖ បង្ហាញអំពីកម្រិតថ្នាក់ដែលសំណាកចូលរួម……………………………..………..44

ក្រាប៤.៦៖ បង្ហាញពីកម្រិតអាយុរបស់អ្នកចូលរួម……………..……………………..………..43

# មូលន័យសង្ខេប


ការសិក្សាស្រាវជ្រាវទៅលើប្រធានបទ «ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំ នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្ដាល» មានគោលបំណងសិក្សាពីស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន និងស្វែងយល់ពីកម្រិតសមត្ថភាពខ្ពស់ ឬទាបរបស់គ្រូដែលកំពុងបង្រៀន នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្ដាល។

ការប្រមូលទិន្នន័យគឺប្រើប្រាស់វិធីសាស្ត្រស្រាវជ្រាវតាមបរិមាណវិស័យ ប្រមូលទិន្នន័យពីគ្រូបង្រៀននៅសាលាមធ្យមសិក្សាធនធាន ក្នុងខេត្តកណ្ដាលចំនួន១៨០ នាក់។ កម្រងសំណួរត្រូវបានចែកជូនទៅតាមក្រុមគោលដៅ មានចំនួន៣៣ សូចនាករ។

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញពីកម្រិតមធ្យមពិន្ទុនៃកម្រិតសមត្ថភាព របស់អ្នកចូលរួមដែលជាគ្រូបង្រៀននៅសាលាមធ្យមសិក្សាធនធាន។ ក្នុងចំណោមជំនាញសមាសភាពទាំង៣ផ្នែកសំខាន់ៗដែលអ្នកចូលរួមបានវាយតម្លៃ ជាលទ្ធផលបញ្ជាក់ថា ការអភិវឌ្ឍសមត្ថភាពគ្រូនៅសាលាមធ្យមធនធានស្ថិតក្នុងកម្រិតមធ្យមនៅឡើយ ដែលមានមធ្យមពិន្ទុស្មើនឹង ៣.២៥។ ការយល់ដឹងទៅលើផ្នែកបច្ចេកវិទ្យ ដែលអ្នកចូលរួមខ្សោយ ព្រោះកម្រិតមធ្យមភាគទាបជាង៣.០ ដែលរួមមាន៨ជំនាញដែលក្នុងនោះមានដូចជា ការដោះស្រាយបញ្ហាបច្ចេកទេសកុំព្យូទ័របានដោយខ្លួនឯង ការយល់ដឹងពីមូលដ្ឋាននៃផ្នែករឹងនិងផ្នែកទន់របស់កុំព្យូទ័រ ការប្រើប្រាស់ម៉ាស៊ីនបញ្ចាំងស្លាយក្នុងដំណើរការបង្រៀនការប្រើប្រាស់កុំព្យូទ័រ ការប្រើប្រាស់កម្មវិធីWord ការប្រើប្រាស់កម្មវិធីExcel ការប្រើប្រាស់កម្មវិធីPowerPoint អាចប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីរក្សាទុកទិន្នន័យ (Cloud, Flash Drive) ការបង្រៀនដោយបញ្ចូលបច្ចេកវិទ្យាគឺមានភាពងាយស្រួល បានតាមដានជាប្រចាំនូវការវិវត្តន៍នៃបច្ចេកវិទ្យា អាចប្រើកាមេរ៉ាឌីជីថល Digital Camera ដែលអ្នកចូលរួមខ្សោយជាងគេ។

តាមរយៈលទ្ធផលនេះផងដែរ ក៏បានបង្ហាញជាលទ្ធផលលើ២ជំនាញដែលអ្នកចូលរួមខ្លាំងពីកម្រិតសមត្ថភាពផ្នែកចំណេះដឹងលើខ្លឹមសារមេរៀន និងចំណេះដឹងផ្នែកគរុកោសល្យ ស្ថិតក្នុងកម្រិត «ល្អ» ដែល

ទទួលយកបានក៏ប៉ុន្តែចំណេះដឹងផ្នែកបច្ចេកវិទ្យាស្ថិតក្នុងកម្រិតប្រឈមខ្លាំងដែលមធ្យមភាគពិន្ទុ ២.៧៤ ដែលគ្រូត្រូវតែបំពេញបន្ថែម ក៏ដូចជាក្រសួងត្រូវយកចិត្តទុកដាក់ជាពិសេស។

ជារួម លទ្ធផលនៃស្ថានភាពការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំ នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្តាលឋិតក្នុងកម្រិតមធ្យម ដែលតម្រូវឱ្យមានការអភិវឌ្ឍន៍លើសមត្ថភាពបច្ចេកវិទ្យាដល់បណ្តាគ្រូបង្រៀន និងត្រូវបានយកបច្ចេកវិទ្យាមកប្រើប្រាស់ក្នុងការបំពេញការងារប្រចាំថ្ងៃ ទាំងក្នុងកិច្ចការរដ្ឋបាល ក៏ដូចជាដំណើរការបង្រៀន។

ពាក្យគន្លឹះ៖ **ស្ថានភាព សមត្ថភាពរបស់បុគ្គលិកអប់រំ សាលាមធ្យមសិក្សាធនធាន**

# ជំពូកទី១៖ សេចក្តីផ្តើម

## ១.១ លំនាំបញ្ហានៃការស្រាវជ្រាវ

ការរីកចម្រើននៃវិទ្យាសាស្រ្ត បច្ចេកវិទ្យា និងស្វែងរកឧត្តមភាពនៅលើពិភពលោក បានជម្រុញឱ្យប្រទេសនីមួយៗខិតខំធ្វើការប្រកួតប្រជែង ផលិតផលនិងសេវាកម្មរបស់ខ្លួន(អយក, ២០១៣)។ នៅក្នុងវេទិកាអប់រំជាសកលនៅទីក្រុងអ៊ីនឈ័ន សាធារណរដ្ឋកូរ៉េ(កូរ៉េខាងត្បូង) នាថ្ងៃទី២១ ខែឧសភា ឆ្នាំ ២០១៥ ។ បានធ្វើសេចក្តីថ្លែងការណ៍អំពីកិច្ចបន្តចក្ខុវិស័យអប់រំ ជាសកល ឆ្នាំ២០៣០ និងក្នុងគោលបំណង « **ធានាឲ្យការអប់រំមានគុណភាពប្រកបដោយសមធម៌ បរិយាបន្ន និងលើកកម្ពស់ឱកាសក្នុងការសិក្សាពេញមួយជីវិតសម្រាប់អ្នកទាំងអស់គ្នា** » ។ ក្នុងន័យនេះដើម្បីសម្រេចបាននូវចក្ខុវិស័យដ៏មានខ្លឹមសារនិងអត្ថន័យដែលគួរជាទីមោទនៈនេះទទួលបានជោគជ័យទាមទារឲ្យមានការចូលរួមពីគ្រប់អ្នកពាក់ព័ន្ធ (អយក, ២០១៩)។

រាជរដ្ឋាភិបាល សាលារៀន និងគ្រូបង្រៀន គឺជាអ្នកបំពេញតួនាទីជួរមុខគេ ដែលត្រូវធ្វើការរួមគ្នាយ៉ាងជិតស្និទ្ធជាមួយសិស្សានុសិស្ស ព្រមទាំងមាតាបិតា អាណាព្យាបាលរបស់ពួកគេផងដែរ។ ដើម្បីធានានិរន្តរភាពក្នុងការ អភិវឌ្ឍធនធានមនុស្ស ចាំបាច់ត្រូវធ្វើការអភិវឌ្ឍគ្រូបង្រៀនឱ្យមានសមត្ថភាពពេញលេញ សំដៅជំរុញតាមការអនុវត្តក្របខណ្ឌច្បាប់ គោលនយោបាយ ឱ្យបានសម្រេចតាមផែនការយុទ្ធសាស្រ្តវិស័យអប់រំ និងយុទ្ធសាស្រ្តចតុកោណរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា។ ធនធានមនុស្សជាកម្លាំងចលករ ក្នុងការសម្រេចបំណងប្រាថ្នា ។ រាជរដ្ឋាភិបាលកម្ពុជា ក៏កំពុងបានយកចិត្តទុកដាក់ជាពិសេសក្នុងការអភិវឌ្ឍន៍វិស័យអប់រំ ដើម្បីឱ្យបានឆ្លើយតបទៅតាម គោលដៅអភិវឌ្ឍប្រកបដោយចីរភាពក្នុងវិស័យអប់រំ ដែលជាគោលដៅមួយនៃគោលដៅអភិវឌ្ឍប្រកបដោយចីរភាពទាំង ១៧ ចំនុចសម្រាប់ឆ្នាំ ២០៣០។ ក្នុងន័យនេះវិស័យអប់រំគឺជាកត្តាមួយដ៏សំខាន់បំផុតសម្រាប់ការអភិវឌ្ឍទៅលើធនធានមនុស្សការអភិវឌ្ឍប្រទេសដើម្បីឱ្យមានការរីកចម្រើនទាំងផ្នែក ចំណេះដឹងវិទ្យាសាស្ត ចំណេះដឹងបច្ចេកវិទ្យា និងជំនាញដើម្បីឆ្លើយតបទៅបរិបទមួយនេះគ្រូបង្រៀនត្រូវមានសមត្ថភាព គុណភាពដើម្បីអប់រំឱ្យមានគុណភាពខ្ពស់ដែលអាចឆ្លើយតបទៅនឹងការវិវត្តនៃសង្គមឆ្ពោះទៅកាន់ភាពដ៏ល្អ

ប្រសើរដើម្បីប្រកួតប្រជែងជាមួយប្រទេសដទៃនឹងធ្វើឲ្យការអប់រំមានសារៈសំខាន់នឹងធ្វើឲ្យមានគុណភាព តម្លាភាព សមធម៌ដែលផ្ដល់សេវាអប់រំជូនប្រជាពលរដ្ឋ (អយក, ២០១៦)។ ដោយផ្អែកទៅលើគោលដៅរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា គឺត្រូវផ្លាស់ប្ដូរប្រទេសកម្ពុជា ពីប្រទេសដែលមានប្រាក់ចំណូលទាប ទៅកាន់ប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ ២០៣០ និងក្លាយជាប្រទេសដែលមានប្រាក់ចំណូលខ្ពស់នៅឆ្នាំ ២០៥០ ក៏ដូចជាការត្រៀមខ្លួនឆ្លើយតបទៅនិងបដិវត្តន៍ឧស្សាហកម្មទី ៤ចុចសូន្រ រាជរដ្ឋាភិបាលចាំបាច់ត្រូវកំណត់ទិសដៅក្នុងការទាញយកសក្ដានុពលនៃការពង្រឹងបន្ថែមសមត្ថភាពគ្រូបង្រៀន ដែលជាគន្លឹះចម្បង ជួយសម្រួចការអប់រំ ដើម្បីឱ្យមានកំណើនសេដ្ឋកិច្ច និងប្រសិទ្ធភាពក្នុងការប្រកួតប្រជែងនានា ចាំបាច់ទាមទារឱ្យពលរដ្ឋដែលជាកម្លាំងស្នូលត្រូវតែមានចំណេះដឹង និងជំនាញពាក់ព័ន្ធដែលសមស្របតម្រូវការទីផ្សារការងារក្នុងស្រុក និងនៅក្រៅប្រទេសផងដែរ។ ដូចនេះហើយវិស័យអប់រំពិតជាដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍន៍ប្រទេសជាតិ ដោយសារតែការអប់រំ ត្រូវផ្ដោតលើការកសាងជំនាញ និងផ្ដល់ឱកាសដល់សិស្ស និស្សិតគ្រប់ៗរូបអាចទទួលបាននូវជំនាញបច្ចេកទេសផ្សេងៗ ដើម្បីអាចសម្រេចបានជោគជ័យនូវការអភិវឌ្ឍន៍ ដែលផ្ដល់អត្ថប្រយោជន៍ពេញលេញដល់ប្រជាពលរដ្ឋគ្រប់ៗគ្នាទាំងអស់ ( Cambodia SDG4-Education 2030 Roadmap,2019 )។ ហើយគ្រូត្រូវបានទទួលស្គាល់នឹងឱ្យតម្លៃខ្ពស់ គ្រូថាមានតួនាទី និងភារកិច្ចដ៏សំខាន់ ក្នុងការកសាងធនធានមនុស្ស និងផ្ដល់ជាវិភាគទានដល់ការអភិវឌ្ឍ បុគ្គល គ្រួសារ សហគមន៍ សង្គមជាតិ និង សកលលោក (អយក, ២០១២ )។

លើសពីនេះទៅទៀតក្រសួងក៏បានដាក់ចេញនូវគោលនយោបាយជាងសាមសិបគោលនយោបាយដើម្បីធានាដល់ការអភិវឌ្ឍប្រព័ន្ធអប់រំរបស់កម្ពុជាឆ្លើយតបទៅនឹងតម្រូវការរបស់សិស្ស និស្សិត ក៏ដូចជាតបទៅគោលនយោបាយអប់រំជាតិ ដែលក្នុងនោះ គោលនយោបាយស្ដីពី«សាលាមធ្យមសិក្សាធនធាន» ក៏ត្រូវបានដាក់ចេញដើម្បីលើកកម្ពស់ការប្រើប្រាស់សម្ភាឧបទេសដល់គ្រូបង្រៀន ដែលជាអ្នកផ្ដល់ការអប់រំ ដល់យុវជនជំនាន់ក្រោយ ឱ្យទទួលបាននូវសម្បទាទាំងបីគឺ **វិជ្ជាសម្បទា បំណិនសម្បទា និង**

**ចរិយាសម្បទា**ពិតប្រាកដ ស្របទៅតាមចតុស្តម្ភនៃការអប់រំទាំង ៤ គឺ «*រៀនដើម្បីមានចំណេះដឹង រៀនដើម្បីមានចំណេះធ្វើ រៀនដើម្បីក្លាយជាពលរដ្ឋល្អ និងរៀនដើម្បីចេះរស់នៅជាមួយគ្នា*»។

លើសពីនេះទៅទៀតនៅក្នុងក្របខណ្ឌគោលនយោបាយស្តីពី គ្រូបង្រៀនមានគោលបំណងអភិវឌ្ឍគ្រូបង្រៀនឱ្យមានគុណភាព សមត្ថភាព ស្មារតីទទួលខុសត្រូវស្របតាមក្រមសីលធម៌វិជ្ជាជីវៈ និងងផ្តល់លក្ខខណ្ឌចាំបាច់ក្នុងការបំពេញការងារប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ( អយក, ២០១៣)។

## ១.២ ចំណោទបញ្ហានៃការស្រាវជ្រាវ

ដោយយើងមើលឃើញថាសង្គមសព្វថ្ងៃមានការរីកចម្រើនខ្លាំងទៅលើបច្ចេកវិទ្យាទាំងប្រទេសជិតខាងនិងប្រទេសកម្ពុជាឬទូទាំងប្រទេសនៅសកលលោក ដូចនេះនៅក្នុងវិស័យអប់រំមានតួនាទីសំខាន់ជាពិសេសគឺគ្រូបង្រៀនដើម្បីឲ្យការអប់រំទទួលបានគុណភាពខ្ពស់យើងត្រូវពង្រឹងលើសមត្ថភាពនិងអភិវឌ្ឍន៍គ្រូបង្រៀនឲ្យមានគុណភាពសមត្ថភាពស្មារតីទទួលខុសត្រូវលើវិជ្ជាជីវៈរបស់ខ្លួន ( អយក, ២០១៣) ។ ផ្អែកលើវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកំណែទម្រង់វិស័យអប់រំឆ្នាំ ២០១៤ ជាពិសេសលទ្ធផលនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ ក្រសួងបានដាក់ចេញកំណែទម្រង់វិស័យអប់រំ យុវជន និង កីឡា ១៥ចំណុចដោយឈរលើមូលដ្ឋានសសរស្តម្ភ ៥ នៅឆ្នាំ ២០១៥ ( អយក, ២០១៩ )។ ហើយនៅក្នុងខ្លឹមសារសសរស្តម្ភទី១ ការអនុវត្តផែនការសកម្មភាពគោលនយោបាយគ្រូបង្រៀន ដែលជាចំណុចមួយដែលបង្ហាញពីការពង្រឹងសមត្ថភាពគ្រូបង្រៀន ហើយខ្លឹមសារនៅក្នុងសសរស្តម្ភទី១នេះគឺផ្តោតលើការបំប៉នគ្រូថ្នាក់ទី១២ មុខវិជ្ជាគណិតវិទ្យា និងវិទ្យាសាស្រ្តទូទាំងប្រទេស ការបណ្តុះបណ្តាលគ្រូកម្រិតមូលដ្ឋានដែលកំពុងបង្រៀននៅវិទ្យាល័យ តាមប្រព័ន្ធពន្លឿនដើម្បីឱ្យក្លាយជាគ្រូបង្រៀនកម្រិតឧត្តម្ភ ការអនុវត្តស្តង់ដារគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ និងស្តងដារវិជ្ជាជីវៈគ្រូបង្រៀន ។

ម្យ៉ាងវិញទៀតនៅក្នុងកម្មវិធីអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន ជាការបំប៉ននូវសមត្ថភាពគ្រូបង្រៀន ហើយក៏ជាយុទ្ធសាស្រ្តមួយក្នុងការលើកកម្ពស់ការទទួលខុសត្រូវ និងម្ចាស់ការរបស់គ្រូបង្រៀន ក្នុងការ

រៀនសូត្រពីគ្នាជាប្រចាំរាល់ការលំបាក និងបទពិសោធន៍ដែលកើតឡើងជាប្រចាំ ទាក់ទងទៅនឹងការរៀន និង បង្រៀនសិស្ស ( អយក, ២០១៧)។

ក្នុងរបាយការណ៍សង្ខេបស្តីពីការបង្រៀន និងរៀនពីចម្ងាយប្រចាំ ខែមេសា ឆ្នាំសិក្សា ២០២០-២០២១ របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ ក៏បានលើឡើងពីបញ្ហាមួយចំនួនដែលកើតមានឡើង ទាក់ទងនិងសមត្ថភាពរបស់គ្រូក្នុងការប្រើប្រាស់បច្ចេកវិទ្យា ក្នុងការបង្រៀន និងរៀនផងដែរ (អយក, ២០២១)។

តាមរយៈរបាយការណ៍ស្រាវជ្រាវមួយដែលរៀបចំឡើងដោយនាយកដ្ឋានគោលនយោបាយ នៃក្រសួងអប់រំយុវជន និងកីឡា ក៏បានកត់សម្គាល់ឃើញផងដែរថា ជាទូទៅសមត្ថភាពគ្រូពាក់ព័ន្ធនឹងបច្ចេកវិទ្យា នៅមានកម្រិត ដោយគ្រូភាគច្រើនពុំទាន់មានឧបករណ៍បច្ចេកវិទ្យា ដូចជាស្មាតហ្វូន កុំព្យូទ័រ ឬសេវាអ៊ីនធឺណិតល្អជាដើម។ ការចំណាយលើសេវាអ៊ីនធឺណិត ក៏ជាបញ្ហាប្រឈមមួយដែរ (អយក, ២០២០)។

ដូចនេះដើម្បីសម្រេចបាននូវគុណភាពគ្រូបង្រៀន យើងត្រូវផ្តោតលើគោលដៅយុទ្ធសាស្ត្រ សំខាន់ៗដូចជាការអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ គឺ ទាមទារឱ្យមានការបណ្តុះវប្បធម៌រៀនពេញមួយជីវិត ដោយមានការចែករំលែកចំណេះ និងបទពិសោធន៍ជាមួយបណ្តាញអ្នកអប់រំ រៀបចំយន្តការប្រកបដោយប្រសិទ្ធភាពដើម្បីគាំទ្រគ្រូបង្រៀននៅកន្លែងធ្វើការ។ ឆ្លងតាមខ្លឹមសារមួយនេះជាសំណួរទៅវិញថា តើគ្រូបង្រៀនយើងសព្វថ្ងៃមានកញ្ចប់សមត្ថភាព ឆ្លើតតបទៅនឹងបន្ទុករបស់ខ្លួនហើយឬនៅ?

## ១.៣ គោលបំណងនៃការស្រាវជ្រាវ

១.សិក្សាពីស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន នៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាល។

២.ស្វែងយល់ពីកម្រិតសមត្ថភាពខ្ពស់ ឬទាបរបស់គ្រូដែលកំពុងបង្រៀន នៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាល។

## ១.៤ សំណួរស្រាវជ្រាវ

១. តើការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្តាលមានកម្រិតណា?

២. តើគ្រូនៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្តាលមានកម្រិតសមត្ថភាពខ្ពស់ ឬខ្សោយលើផ្នែកអ្វីខ្លះ?

## ១.៥ សារៈសំខាន់នៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះ មានសារៈសំខាន់ណាស់ជាកញ្ចក់ឆ្លុះបង្ហាញពីកម្រិតសមត្ថភាពរបស់ខ្លួនក្នុងនាមជាគ្រូបង្រៀន ដើម្បីធ្វើឲ្យងាយស្រួលក្នុងការអភិវឌ្ឍសម្តភាពរបស់ខ្លួនឲ្យសមស្របតាមស្តង់ដាសាលាមធ្យមធនធាន។ប្រកបដោយមនសិការវិជ្ជាជីវៈ ដែលជាកត្តារុញច្រានដល់លទ្ធផលសិក្សារបស់សិស្សានុសិស្ស ស្របតាមគោលដៅរបស់ក្រសួងអប់រំ។ជាសារមួយសម្រាប់ក្រសួងអប់រំ យុវជន និងកីឡា ឲ្យបានមើលឃើញពីនូវ ចំណេះដឹង និងជំនាញដែលចាំបាច់ ដែលត្រូវធ្វើបណ្តុះបណ្តាល និងងាយស្រួលក្នុងការជួយដោះស្រាយ ប្រឈមនានាដែលអាចនឹងកើតមានឡើង។ ឯកសារជំនួយស្មារតីសម្រាប់អ្នកសិក្សាក្នុងការសិក្សារៀនសូត្រ និងការសិក្សាស្រាវជ្រាវផ្សេងៗផងដែរ។

ដើម្បីលើកកម្ពស់គុណភាពនៃការអប់រំរបស់ក្រសួងអប់រំ យុវជន និងកីឡា ព្រមទាំងជួយលើកកម្ពស់គុណភាពអប់រំប្រកបដោយប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៅក្នុងវិស័យអប់រំ។

## ១.៦ ដែនកំណត់ និង វិសាលភាពនៃការស្រាវជ្រាវ

### ១.៦.១ វិសាលភាពនៃការស្រាវជ្រាវ:

ការសិក្សាស្រាវជ្រាវតែសាលារៀនធនធានដែលមានទីតាំងតែនៅក្នុងខេត្តកណ្តាលដែលនៅក្នុងនោះជ្រើសរើសសាលាមធ្យមធនធានចំនួន៣ (១ វិទ្យាល័យហ៊ុន សែន សិរីភាព ២ វិទ្យាល័យហ៊ុន សែន កោះធំ និង ៣ វិទ្យាល័យទេពប្រណម្យ)។

### ១.៦.២ ដែនកំណត់នៃការស្រាវជ្រាវ:

ការស្រាវជ្រាវទៅលើប្រធានបទនេះ ផ្តោតទៅលើ ស្ថានភាពនៃកញ្ចប់សមត្ថភាពរបស់បុគ្គលិកអប់រំ (ដែលក្នុងនោះអ្នកសិក្សាជ្រើរើសយកតែគ្រូដែលកំពុងបង្រៀន ដោយពុំគិតបុគ្គលិកផ្សេងៗ ទៀតដូចជា

បុគ្គលិក រដ្ឋបាល បណ្ណារក្ស ឬបុគ្គលិកផ្សេងទៀតនោះទេ ) និង ដំណោះស្រាយនានា ដើម្បីចូលរួមក្នុងការអភិវឌ្ឍសមត្ថភាពរបស់បុគ្គលិកអប់រំ នៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាល ។

## ១.៧ រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

រចនាសម្ព័ន្ធនៃការសិក្សាស្រាវជ្រាវនេះបានបែងចែកជា ៥ ជំពូកដូចខាងក្រោម ៖

### ជំពូកទី១ ៖ សេចក្តីផ្តើម

បង្ហាញពីលំនាំបញ្ហានៃការស្រាវជ្រាវ ចំណោទបញ្ហានៃការស្រាវជ្រាវ សំណួរស្រាវជ្រាវ គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ដែនកំណត់ និងវិសាលភាពនៃការស្រាវជ្រាវ ព្រមទាំងរចនាសម្ព័ន្ធនៃការស្រាវជ្រាវ។

### ជំពូកទី២ ៖ រំលឹកទ្រឹស្តី

អ្នកស្រាវជ្រាវលើកឡើងនូវទ្រឹស្តីផ្សេងៗ ដែលពាក់ព័ន្ធទៅ នឹងសមាសភាព៣ផ្នែកសំខាន់ៗ គឺចំណេះដឹកផ្នែងបច្ចេកវិទ្យា ចំណេះដឹងផ្នែកគរុកោសល្យ និងចំណេះដឹងផ្នែកខ្លឹមសារមេរៀន និងពីអ្នកសិក្សាស្រាវជ្រាវមុនៗ ដែលមានខ្លឹមសារទាក់ទងនឹងចំណុចទាំងអស់ដែលបានចោទឡើងក្នុងចំណោទបញ្ហា ដើម្បីលើកយកមកបង្ហាញ និងការពារអំណះអំណាងនៅក្នុងសារណាសម្រាប់ស្រាវជ្រាវ និងបង្កើតស្នាដៃថ្មីនេះឡើង។

### ជំពូកទី៣ ៖ វិធីសាស្ត្រស្រាវជ្រាវ

បង្ហាញពីគម្រោងវិភាគ ដោយប្រើប្រាស់ វិធីសាស្ត្របែបបរិមានវិស័យ ដោយប្រើប្រាសកម្រងសំណួរជាឧបករណ៍ស្រាវជ្រាវ វិធីសាស្ត្រវិភាគទិន្នន័យដោយកម្មវិធី SPSS និងវិធីសាស្ត្រស្រាវជ្រាវដែលបញ្ជាក់ពីវិសាលភាពនៃការស្រាវជ្រាវ វិធីសាស្ត្រប្រមូលទិន្នន័យ វិធីសាស្ត្រជ្រើសរើសគំរូ និងប្រភេទគំរូ។

### ជំពូកទី៤ ៖ លទ្ធផល និងការពិភាក្សា

អ្នកស្រាវជ្រាវនឹងយកទិន្នន័យ ដែលប្រមូលបានមកវិភាគ និងបកស្រាយ ដើម្បីរកឱ្យឃើញនូវចំណុចទាំងអស់ដែលបានចោទសួរក្នុងចំណោទបញ្ហា។

## ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ

អ្នកស្រាវជ្រាវនឹងធ្វើការសន្និដ្ឋាន លើគ្រប់ចំណុចដែលទទួលបានយកមកវិភាគ ហើយផ្ដល់ជាយោបល់ ធ្វើសំណូមពរទៅលើចំណុចមួយចំនួនដែលត្រូវកែលម្អ ដើម្បីជាការចូលរួមចំណែកក្នុងការអភិវឌ្ឍគ្រឹះស្ថានសិក្សាសាធារណៈ ឱ្យកាន់តែល្អប្រសើរឡើងថែមទៀត។

# ជំពូកទី២៖ រំលឹកទ្រឹស្តី.

## ២.១ ស្ថានភាពទូទៅក្នុងខេត្តកណ្តាល

កណ្តាល ជាខេត្តមួយដែលមានចម្ងាយ ១១គ.ម ពីរាជធានីភ្នំពេញ ដែលមានទីតាំងនៅប៉ែកអាគ្នេយ៍នៃប្រទេសកម្ពុជា និងមានព្រំដែនខាងកើតជាប់ខេត្តព្រៃវែង ខាងត្បូងជាប់ ខេត្តតាកែវ ខាងកើតឈៀងខាងជើងជាប់ ខេត្តកំពង់ចាម ខាងកើតឈៀងខាងត្បូងជាប់នឹង វៀតណាម។ កណ្តាលគឺជាខេត្តមួយក្នុងចំណោមខេត្តដែលស្ទុកស្តម្ភជាងគេក្នុងប្រទេស។ ខេត្តកណ្តាលមានស្រុកចំនួន១១ ក្រុង១ ឃុំ១៤ ៧ ភូមិចំនួន១០៨៧ និង១៤៧សង្កាត់ មានប្រជាជនចំនួន ១០៧៥១២៥នាក់ ហើយខេត្តនេះផងដែរមានផ្ទៃដី ៣៥៦៨គីឡូម៉ែតការេ។ ហើយខេត្តនេះផងដែរមានផ្ទៃដី ៣៥៦៨ សហាតិមាត្រការ៉េ។ ប្រជាជនខេត្តកណ្តាលភាគច្រើនប្រកបរបរកសិកម្ម ដាំដំណាំ ក្រៅពីនេះរដូវធ្វើស្រែ ពួកគាត់មានរបរមួយទៀតគឺ របរឡើងត្នោត និងធ្វើស្រូវប្រាំង ព្រមទាំងដាំដំណាំផ្សេងៗទៀត ដើម្បីផ្គត់ផ្គង់ជីវភាពគ្រួសាររបស់ខ្លួន។

### ២.១.១ ចំនួនបុគ្គលិកអប់រំ

តារាង២.១៖ ចំនួនបុគ្គលិកអប់រំក្នុងឆ្នាំសិក្សា២០២១-២០២២

| ចំនួនបុគ្គលិកអប់រំក្នុងឆ្នាំសិក្សា២០២១-២០២២ | | |
|---|---|---|
| **ចំនួនបុគ្គលិកអប់រំ** | **សរុប (នាក់)** | **ស្រី (នាក់)** |
| បុគ្គលិកអប់រំគ្រប់កម្រិតថ្នាក់ | **៩ ១៧៩** | **៤ ៦៣៨** |
| គ្រូមត្តេយ្យសិក្សា | ៥២៨ | ៤៩៩ |
| គ្រូបឋមសិក្សា | ៣ ២៤១ | ១ ៨១០ |
| គ្រូបង្រៀនកម្រិតមូលដ្ឋាន | ១ ៩០៤ | ៨៩៥ |
| គ្រូបង្រៀនកម្រិតឧត្តម | ៣ ១៤២ | ១ ៣១២ |
| ការិ.អ យ ក ស្រុក/ក្រុង | ១២៥ | ៣៦ |
| គរុ.វិក្រិតការ ខេត្ត | ៥០ | ២១ |

| | | |
|---|---|---|
| ម.គរុ.ភូមិភាគហ ស ខេត្ត | ៧៦ | ២៦ |
| មន្ទីរអប់រំ យុវជន និងកីឡាខេត្ត | ១១៣ | ៣៩ |

(មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល,ស្ថិតិ និងសូចនាករអប់រំសាធារណៈ២០២១-២០២២)។

### ២.១.២ ចំនួនសាលារៀន

តារាង២.២៖ ស្ថិតិចំនួនសាលារៀនក្នុងឆ្នាំសិក្សា២០២១-២០២២

| **ស្ថិតិចំនួនសាលារៀន** | | |
|---|---|---|
| **សាលា** | **ចំនួនសាលារៀន** | **ចំនួនថ្នាក់រៀន** |
| មត្តេយ្យសិក្សា | ២៤៨ | ៥១៧ |
| បឋមសិក្សា | ៣៧៣ | ៤,៣២៣ |
| មធ្យមសិក្សាបឋមភូមិ | ១០០ | ៧៥៩ |
| មធ្យមសិក្សាទុតិយភូមិ | ៤០ | ១,២១១ |
| **សរុប** | **៧៦១** | **៦,៨១០** |

(មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្តាល,ស្ថិតិ និងសូចនាករអប់រំសាធារណៈ២០២១-២០២២)។

### ២.១.៣ ចំនួនសិស្ស

តារាង២.៣៖ ស្ថិតិចំនួនសិស្សឆ្នាំសិក្សា ២០២១-២០២២

| **ស្ថិតិចំនួនសិស្សឆ្នាំសិក្សា ២០២១-២០២២** | | |
|---|---|---|
| **ចំនួនសិស្ស** | **សរុប (នាក់)** | **ស្រី (នាក់)** |
| មត្តេយ្យសិក្សា | ១៥,៨២២ | ៧,៨៣៥ |
| បឋមសិក្សា | ១៦១,៦៣៨ | ៧៦,៦៧៩ |
| មធ្យមសិក្សាបឋមភូមិ | ៣២,០៧៣ | ១៦,៦២៦ |
| មធ្យមសិក្សាទុតិយភូមិ | ៥៤,១៩១ | ២៩,១៥២ |

| | | |
|---|---|---|
| **សរុប** | **២៦៣,៧២៤** | **១៣០,៣៣២** |

(មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល,ស្ថិតិ និងសូចនាករអប់រំសាធារណៈ២០២១-២០២២)។

## ២.២ និយមន័យ

**ការរៀន៖** គឺជាទង្វើនៃការទទួលបានអ្វីមួយថ្មី ឬការកែប្រែ និងពង្រឹងចំណេះដឹង អាកប្បកិរិយា បំណិន គុណតម្លៃ ឬចំណង់ចំណូលចិត្តដែលមានស្រាប់ ហើយអាចពាក់ព័ន្ធ និងការសំយោគព័ត៌មានប្រទេសផ្សេងៗគ្នាសម្រាប់ការប្រើប្រាស់ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, ២០១៥)។ ការសិក្សា គឺជាសកម្មភាពរបស់សិស្សម្នាក់ៗដែលចង់បានចំណេះដឹងសម្រាប់យកទៅប្រើប្រាស់ក្នុងជីវភាពរស់នៅរបស់ខ្លួន និងធ្វើយ៉ាងណាឲ្យកាន់តែមានភាពប្រសើរឡើង ពោលគឺធ្វើឲ្យមានការផ្លាស់ប្ដូរជីវិតរស់នៅទាំងឥរិយាបថ និងស្មារតី បញ្ញា សតិសម្បជញ្ញៈ។

**ការបង្រៀន៖** ជាសកម្មភាពសម្របសម្រួលការរៀនរបស់សិស្ស លើកទឹកចិត្តឲ្យចេះរៀនដោយខ្លួនឯង ពង្រឹង និងពង្រីកចំណេះដឹង បទពិសោធន៍ដល់សិស្សគ្រប់រូប។ សកម្មភាពនៃការបង្រៀនរួមមាន ការពន្យល់ ការដាក់ចំណោទ ការសួររកហេតុ និងផល ការសួរសំណួរ ការលើកទឹកចិត្ត ការតាមដានសាវតាររបស់សិស្ស ការប្រឡង ឬការវាយតម្លៃអំពីការរីកចម្រើនរបស់សិស្ស។ល។ ក្រៅពីមានចិត្តគរុកោសល្យ គ្រូបង្រៀនក៏ដូចជាអ្នកដទៃទៀតចាំបាច់ត្រូវតែបន្តការស្រាវជ្រាវរកអ្វីដែលថ្មី អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈរបស់ខ្លួន និងការបង្កើតអ្វីដែលថ្មីពេញមួយជីវិតការងារ (នាយកដ្ឋានអភិវឌ្ឍកម្មវិធីសិក្សា ក្របខណ្ឌកម្មវិធីសិក្សាអប់រំចំណេះទូទៅ និងអប់រំបច្ចេកទេស, ២០១៥) ។ Modern Concept បានលើកឡើងថា ការបង្រៀនគឺជាបុព្វហេតុដែលជំរុញឲ្យសិស្សខិតខំរៀនសូត្រ និងទទួលបានចំណេះដឹង បទពិសោធន៍ និងមធ្យោបាយសម្រាប់ការរស់នៅរបស់ខ្លួន ជាមួយសង្គមឲ្យបានសមស្របទៅតាមបំណងប្រាថ្នាដែលពួកគេចង់បានផងដែរ។ទិដ្ឋភាពដ៏សំខាន់បំផុតនៃដំណើរការបង្រៀនគឺសិស្សនិងអ្វីដែលពួកគេត្រូវរៀន។ (Dr.A.H.Sequeira,2002)។

**ការរៀន៖** គឺជាកិច្ចការរបស់គ្រូក្នុងការប្រើប្រាស់ចំណេះដឹងរបស់ខ្លួនសម្រាប់ការអភិវឌ្ឍសមត្ថភាពរបស់សិស្សឲ្យមានភាពល្អប្រសើរ (Thomas Green)។ ការបង្រៀន គឺជាសកម្មភាពនៃការចែករំលែកការ

អប់រំដល់អ្នកសិក្សាក្នុងថ្នាក់រៀនមួយ (Traditional Teaching)។ ការបង្រៀន គឺជាការយកចិត្តដាក់ទៅលើសកម្មភាពរបស់សិស្សរួមមាន សកម្មភាពលេង និការបង្កើតថ្មី ឬរបកគំហើញ Paul H.Hirst,2004)។

**មធ្យមសិក្សា:** ជាកម្រិសិក្សាបន្តពីបឋមសិក្សាបឋមភូមិដែលមានកម្រិតថ្នាក់ចាប់ពីថ្នាក់ទី១ ដល់ថ្នាក់ទី៦ ហើយមធ្យមសិក្សានេះចែកចេញជាពីរ គឺជាកម្រិតសិក្សាមធ្យមសិក្សាបឋមភូមិដែលរាប់ចាប់ពីថ្នាក់ទី៧ ដល់ថ្នាក់ទី៩ និងមធ្យមសិក្សាទុតិយភូមិចាប់ពីថ្នាក់ទី១០ដល់ថ្នាក់ទី១២។ការអប់រំមធ្យមសិក្សាត្រូវបណ្ដុះបណ្ដាលបុគ្គលិកលក្ខណៈពេលេញដោយពង្រីកវិសាលភាពចំណេះដឹង បំណិន ការអប់រំវិជ្ជាជីវៈ ការអប់រំសីលធម៌ ដើម្បីរួមចំណែកក្នុងការអភិវឌ្ឍសេដ្ឋកិច្ច សង្គម និងមានលក្ខណសម្បត្តិបន្តទៅថ្នាក់បន្ទាប់ ឬបណ្ដុះបណ្ដាលបច្ចេកទេសវិជ្ជាជីវៈ ឬចូលរួមក្នុងជីវភាពសង្គមបានប្រសើរ។ (ច្បាប់ស្ដីពីការអប់រំ, ១៩ តុលា ២០០៧)។

**ធនធាន៖** គឺទ្រព្យរបស់ផ្សេងៗដែលគង់នៅ : គេមានធនធានច្រើន (វចនានុក្រមសម្ដេចសង្ឃរាជ ជួន ណាត ទំព័រ ៤៧៣ បោះពុម្ព ព.ស. ២៥៤៥ គ.ស. ២០០១)។ ធនធាន មានបីគឺធនធានមនុស្ស ធនធានសម្ភារៈ និងធនធានថវិកា។

**សាលាធនធាន៖** គឺជាខ្នងបង្អែកឱ្យសាលាបណ្ដាញទាំងអស់ ព្រោះសាលារៀននេះមានសម្ភាររូបវ័ន្តគ្រប់គ្រាន់ ដូចជា៖ បន្ទប់ពិសោធន៍ សាលប្រជុំ និងបណ្ណាល័យ ដែលបំពាក់ដោយសៀវភៅសម្រាប់សិក្សាស្រាវជ្រាវ (ឯកសារស្ដីពីការលើកកម្ពស់សមត្ថភាពគ្រប់គ្រង និងប្រើប្រាស់អគារធនធាន និងសាលាបណ្ដាញ,២០២០)។

**សាលាមធ្យមសិក្សាធនធាន៖** គឺជាសាលាដែលបានបំពាក់ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភាររូបវ័ន្ត (អគារសិក្សា សាលប្រជុំ បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ បណ្ដាញទឹក បណ្ដាញភ្លើង.....) និងបណ្ដុះបណ្ដាលការប្រើប្រាស់សម្ភាររូបវ័ន្តទាំងនោះ។ សាលាមធ្យមសិក្សាធនធាននឹងចែករំលែកបទពិសោធ ក្នុងការប្រើប្រាស់ធនធានទាំងនោះដល់សាលារៀនក្នុងបណ្ដាញរបស់ខ្លួន (គោលនយោបាយស្ដីពីសាលាមធ្យមសិក្សាធនធាន របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ,២០០៨)។

**សាលាមធ្យមសិក្សាធនធាន៖** គឺជាសាលាមធ្យមសិក្សាមួយដែលមានឧត្តមភាពស្ថិតនៅក្នុងក្រុង ស្រុក ខណ្ឌ នៃរាជធានី ខេត្ត ដែលត្រូវបានជ្រើសរើសឡើង ដើម្បីនាំមុខក្នុងការធ្វើឱ្យសាលារៀន មានភាពរីកចម្រើនគ្រប់ផ្នែក ដូចជាការអនុវត្តកម្មវិធីសិក្សា លទ្ធផលសិក្សា ចែករំលែកបទពិសោធ(ការបង្រៀននិងរៀន ការគ្រប់គ្រងរដ្ឋបាល ការគ្រប់គ្រងបុគ្គលិក និងការគ្រប់គ្រងហិរញ្ញវត្ថុ) ការរៀបចំផែនការប្រតិបត្តិប្រចាំឆ្នាំ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍសាលារៀន និងការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន។ សាលាមធ្យមសិក្សាធនធាន នឹងក្លាយជាសាលាមធ្យមសិក្សានាំមុខក្នុងចំណោមសាលាបណ្ដាញ ជាមជ្ឈមណ្ឌលចែករំលែកការប្រើប្រាស់មូលដ្ឋានសម្ភាររូបវន្តអប់រំ ចែករំលែកបទពិសោធ សមត្ថភាព និងជាមជ្ឈមណ្ឌលកម្មសិក្សារបស់គរុសិស្ស-និស្សិត (ក្របខណ្ឌពិនិត្យតាមដាន និងវាយតម្លៃសាលាមធ្យមសិក្សាធនធាន ,២០១៨)។

**សាលាមធ្យមសិក្សាធនធាន៖** គឺជាសាលាមធ្យមសិក្សាមួយនៅស្រុក ខណ្ឌ ឬខេត្ត ក្រុង ដែលត្រូវបានជ្រើសរើសឡើង ដើម្បីនាំមុខក្នុងការធ្វើឱ្យសាលារៀន មានភាពរីកចម្រើនគ្រប់ផ្នែក ជាពិសេសការអនុវត្តកម្មវិធីសិក្សា និងលទ្ធផលសិក្សា។ សាលាមធ្យមសិក្សាធនធាន នឹងក្លាយជាសាលារៀននាំមុខក្នុងបណ្ដាញសាលាមធ្យមសិក្សាដែលមានក្នុងមូលដ្ឋាន (ឯកសារស្ដីពីការលើកកម្ពស់សមត្ថភាពគ្រប់គ្រង និងប្រើប្រាស់អគារធនធាន និងសាលាបណ្ដាញ,២០២០)។

**សាលាមធ្យមសិក្សាធនធាន៖** នឹងលើកកម្ពស់វិជ្ជាជីវៈគ្រូបង្រៀន ចែករំលែកបទពិសោធ ក្នុងការងារបង្រៀន និងរៀន ការងារគ្រប់គ្រង ណែនាំកសាង និងអនុវត្តផែនការអភិវឌ្ឍសាលារៀន និងអភិវឌ្ឍសមត្ថភាពគ្រូ។

**សាលាមធ្យមសិក្សាធនធាន៖** នឹងក្លាយជាសមាសភាគដ៏រឹងមាំមួយនៃយុទ្ធសាស្ត្រ គន្លឹះរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលធ្វើឱ្យសាលាមធ្យមសិក្សាអភិវឌ្ឍ តាមរយៈភាពជាអ្នកដឹកនាំ នៃសាលាមធ្យមសិក្សាក្នុងបណ្ដាញ។

## ២.៣ វិធានការកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា

វិធានការអាទិភាព ០៨ចំណុចឆ្នាំ ២០១៤ ក្នុងការធ្វើកំណែទម្រង់ស៊ីជម្រៅវិស័យអប់រំ យុវជន និងកីឡាគឺ៖ ១)ការបង្កើនគុណភាព និងប្រសិទ្ធភាពនៃសេវាអប់រំ ២)ការពង្រឹងការគ្រប់គ្រងបុគ្គលិក ៣)ការពង្រឹងការប្រឡងគ្រប់ប្រភេទ ៤)ការកែទម្រង់ឧត្តមសិក្សា ៥)ការអភិវឌ្ឍសម្រាប់យុវជន នូវជំនាញបច្ចេកទេស និងជំនាញទន់ ៦)ការអនុវត្តស៊ីជម្រៅកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៧)ការកែទម្រង់ការងារអប់រំកាយ និងកីឡា និង ៨)ការបង្កើតធនាគារខួរក្បាលវិស័យអប់រំ។ ក្នុងការធ្វើកំណែទម្រង់ការគ្រប់គ្រងបុគ្គលិកឱ្យទទួលបានប្រសិទ្ធភាពក្រសួងបានដាក់ចេញនូវគោលនយោបាយចំនួន៦គឺ៖ ១)លើកកម្ពស់ជីវភាពបុគ្គលិកអប់រំ ២)សិក្សាគោលការណ៍ប្រាក់បៀវត្ស និងប្រាក់ឧបត្ថម្ភផ្សេងៗដល់បុគ្គលិកអប់រំ ៣)ពង្រឹងសមត្ថភាពមន្ត្រីគ្រប់គ្រងលើការអនុវត្តគោលការណ៍ដំឡើងថ្នាក់ និងឋានន្តរស័ក្តិរបស់បុគ្គលិកអប់រំ ៤)ពិនិត្យតម្រូវការ និងការផ្គត់ផ្គង់បុគ្គលិកអប់រំនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ៥)ពង្រឹងការបំពេញភារកិច្ចរបស់គណៈកម្មការវាយតម្លៃបុគ្គលិក និងកែលម្អនីតិវិធី វាយតម្លៃក្នុងការតែងតាំងមន្ត្រីគ្រប់គ្រង និង ៦)ពង្រីកការអនុវត្តគោលការណ៍ស្តីពីការផ្លាស់ប្តូរទីកន្លែងបម្រើការងាររបស់បុគ្គលិកអប់រំ។

កម្មវិធីកំណែទម្រង់ជាអាទិភាពសម្រាប់ឆ្នាំ ២០១៥ ដល់ ២០១៨គឺ៖ ១)កំណែទម្រង់ការគ្រប់គ្រងបុគ្គលិក ២)ការពង្រាយគ្រូបង្រៀន ៣)កំណែទម្រង់មជ្ឈមណ្ឌលបណ្តុះបណ្តាលគ្រូបង្រៀន ៤)ការលើកកម្ពស់គុណវុឌ្ឍិគ្រូបង្រៀន ៥)ការងារអធិការកិច្ច ៦)ការវាយតម្លៃលទ្ធផលសិក្សា ៧)កំណែទម្រង់ការប្រឡងសញ្ញាបត្រមធ្យមសិក្សា ៨)កំណែទម្រង់កម្មវិធីសិក្សា និងសៀវភៅសិក្សាគោល ៩)ការសាងសង់អគារសិក្សា និងការជួសជុល ១០)ការវាយតម្លៃគ្រឹះស្ថានឧត្តមសិក្សា ១១)ការលើកកម្ពស់វិស័យកីឡា ១២)ការអនុវត្តផែនការសកម្មភាពគោលនយោបាយយុវជន ១៣)ការអប់រំបច្ចេកទេស ១៤)ការបង្កើតសាលារៀនជំនាន់ថ្មី និង ១៥)ការរៀបចំគន្លងអាជីព និងការបណ្តុះបណ្តាលនាយកសាលា។

## ២.៤ ផែនការយុទ្ធសាស្ត្រកំណែទម្រង់ វិស័យអប់រំ យុវជន និងកីឡា ២០១៩-២០២៣

នៅក្នុងអាណត្តិទី៦នេះ រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ដោយចាត់ទុកការអភិវឌ្ឍធនធានមនុស្ស ជាអាទិភាពទី១។ ក្រសួងអប់រំ យុវជន និងកីឡា ប្តេជ្ញាសម្រេចឱ្យបាននូវមុំទី១ ស្តីពី "ការពង្រឹងគុណភាពអប់រំ វិទ្យាសាស្ត្រ និងបច្ចេកវិទ្យា" ដោយបានដាក់ផ្តល់អាទិភាពលើ ១)ការយកចិត្តទុកដាក់លើគ្រូបង្រៀន ២)ការពង្រីកវិសាលភាពសាលារៀនគ្រប់កម្រិត ៣)ការពង្រឹងអធិការកិច្ចគ្រប់ជ្រុងជ្រោយលើការគ្រប់គ្រងសាលារៀន ៤)ការជំរុញការអប់រំបច្ចេកទេសនៅមធ្យមសិក្សាទុតិយភូមិ ៥)ការអប់រំបំណិនឱ្យស្របតាមទីផ្សារការងារ ៦)ការអភិវឌ្ឍកម្មវិធីសិក្សា និងសៀវភៅសិក្សាគោលគ្រប់ជ្រុងជ្រោយ និង ៧)ការត្រៀមប្រកួតកីឡាស៊ីហ្គេមឆ្នាំ ២០២៣។

ដើម្បីគាំទ្រដល់ការអនុវត្តយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា ឆ្នាំ២០១៩-២០២៣ ក្រសួងអប់រំ យុវជន និងកីឡាបានដាក់ចេញនូវយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡាមានដូចខាងក្រោម ៖

យុទ្ធសាស្ត្រកំណែទម្រង់ការគ្រប់គ្រងរបស់ក្រសួងអប់រំគឺ៖ ១)កំណែទម្រង់ការសិក្សា ២)កំណែទម្រង់ការគ្រប់គ្រងរដ្ឋបាល ៣)កំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុ និង៤)កំណែទម្រង់ការគ្រប់គ្រងធនធានមនុស្ស។

យុទ្ធសាស្ត្រកំណែទម្រង់ឧត្តមសិក្សាគឺ៖ ១)ពិនិត្យលទ្ធភាពប្រែក្លាយគ្រឹះស្ថានឧត្តមសិក្សាសាធារណៈទៅជាគ្រឹះស្ថានឧត្តមសិក្សាសាធារណៈរដ្ឋបាល ២)ផ្តល់ស្វ័យភាពដល់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈក្នុងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានមនុស្ស ៣)រៀបចំក្របខណ្ឌកម្មវិធីសិក្សាដែលឆ្លើយតបនឹងការវិត្តឧស្សាហកម្ម ៤)ជំរុញការស្រាវជ្រាវ និង ៥)វាយតម្លៃគុណភាពអប់រំផ្ទៃក្នុង និងគុណភាពអប់រំតាមគ្រឹះស្ថានឧត្តមសិក្សា។

យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍយុវជនគឺ៖ ១)ផ្តល់ឱកាសឱ្យយុវជនទទួលបានការអប់រំ និងការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈប្រកបដោយគុណភាព និងសមធម៌ ២)លើកទឹកចិត្តយុវជនឱ្យមាន

គំនិតផ្តួចផ្តើម ច្នៃប្រឌិត បង្កើតថ្មី និងស្មារតីសហគ្រិនភាព ៣)អភិវឌ្ឍយុវជនឱ្យមានកាយសម្បទា ចំណេះដឹង ចំណេះធ្វើ សីលធម៌រស់នៅល្អ ចេះរួមរស់ជាមួយគ្នា ដោយសន្តិភាព និងសុខដុមនីយកម្ម ៤) បង្កឱកាសឱ្យយុវជនចូលរួមបញ្ចេញមតិ ទស្សនៈ និងធ្វើសេចក្តីសម្រេចចិត្តនានា នៅក្នុងការអភិវឌ្ឍសហគមន៍ និងសង្គមជាតិ និង៥)ពង្រឹងយន្តការគ្រប់គ្រង និងពិនិត្យតាមដានកម្មវិធីអភិវឌ្ឍយុវជន។

យុទ្ធសាស្ត្រកំណែទម្រង់ការអភិវឌ្ឍវិស័យអប់រំកាយ និងកីឡាគឺ៖ ១)អភិវឌ្ឍក្របខណ្ឌច្បាប់ និងគតិយុត្តិ ២)អភិវឌ្ឍកីឡាកម្រិតខ្ពស់ ៣)អភិវឌ្ឍវិស័យអប់រំកាយ និងកីឡានៅគ្រប់គ្រឹះស្ថានសិក្សា និងសហគមន៍ និង៤)អភិរក្ស និងអភិវឌ្ឍកីឡាគ្រប់ប្រភេទ (ឯកសារយុទ្ធសាស្ត្រកំណែទម្រង់វិស័យអប់រំ យុវជន និងកីឡា,២០១៩-២០២៣)។

## ២.៥ លក្ខណៈវិនិច្ឆ័យសាលាមធ្យមសិក្សាធនធាន

សាលារៀនដែលចាត់ទុកជាសាលាមធ្យមសិក្សាធនធាន ត្រូវបំពេញតាមលក្ខណៈ វិនិច្ឆ័យចំនួន ៥គឺ៖ (១)សាលារៀនមានទីតាំងក្នុងទីប្រជុំខេត្ត-ក្រុង ស្រុក-ខណ្ឌ (២)សាលារៀនមានការគ្រប់គ្រង និងសហការល្អជាមួយសហគមន៍ (៣)សាលារៀនមានទីតាំងធំទូលាយ ងាយស្រួលក្នុងការសាងសង់អគារបន្ថែមនៅពេលអនាគត (៤)សាលារៀនមានសុវត្ថិភាព និងសន្តិសុខ ធានាការពាររាល់វត្ថុមានតម្លៃក្នុងសាលា និង (៥)សាលារៀនមានប្រភពថាមពលអគ្គិសនី និងទឹកស្អាតសម្រាប់បម្រើឱ្យបន្ទប់ពិសោធន៍ និងបន្ទប់កុំព្យូទ័រ។

លើសពីនេះទៅទៀត សាលាមធ្យមសិក្សាធនធាន ត្រូវបំពេញកម្រិតអប្បបរមានៃហេដ្ឋារចនាសម្ព័ន្ធរូបវន្តដូចតទៅ៖ ១)មានការិយាល័យសម្រាប់នាយក នាយករងសាលារៀន និងលេខាធិការ ២)មានសាលប្រជុំ សាលគ្រូបង្រៀន បន្ទប់ពិសោធន៍វិទ្យាសាស្ត្រ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ ឃ្លាំងសម្រាប់ដាក់សម្ភារៈ និងបន្ទប់សម្រាប់គ្រូរៀបចំមេរៀន ៣)មានបណ្ណាល័យ ៤)មានអាហារដ្ឋាន ឬបន្ទប់រៀបអាហារសម្រន់ និង៥)មានបង្គន់អនាម័យ និងបន្ទប់ទឹកនារីគ្រប់គ្រាន់។

## ២.៦ ទ្រឹស្តីនៃការគ្រប់គ្រង និងដំណើរការអគារធនធាន

### ២.៦.១. ធនធានមនុស្សរបស់អគារធនធាន

ក. គណៈគ្រប់គ្រងអគារធនធាន

១. ប្រធាន (នាយកវិទ្យាល័យ)            ២. អនុប្រធាន (នាយករងបច្ចេកទេស)

៣. សមាជិក (ក្រុមប្រឹក្សាបច្ចេកទេស)  មន្ទីរ អយក, តែងតាំងគណៈកម្មការនេះ

**ខ. បុគ្គលិកបន្ថែម៨នាក់ (ស.ណ.ន លេខ០៧)**

បរិច្ចការីបន្ទប់ពិសោធន៍៤នាក់ (គីមី រូប ជីវៈ ផែនដី)

- ប្រើគ្រូស.ម.ធ ឬបណ្ណាញ       - ធ្វើការ១៦/១៨ម៉

បុគ្គលិកទទួលបន្ទុកគ្រប់គ្រងកុំព្យូទ័រ២នាក់

- ម្នាក់ទទួល១បន្ទប់     - ប្រើគ្រូស.ម.ធ ឬបណ្ណាញ      - ធ្វើការ១៦/១៨ម៉

ពលករអណ្តែត២នាក់

- ម្នាក់យាមសុវត្ថិភាព    - ម្នាក់សម្អាតបន្ទប់ សម្ភារៈនិងបម្រើភេសជ្ជៈប្រជុំ
- ត្រូវចេះសហការគ្នា   - ករណីការងារច្រើនហួសសមត្ថភាពធ្វើបានគណៈគ្រប់គ្រងអគារធនធាន

គប្បីចាត់ចែងទៅតាមលទ្ធភាពជាក់ស្តែង។

**តារាង២.៤៖ រចនាសម្ព័ន្ធគណៈកម្មការគ្រប់គ្រងស.ម.ធ និងបណ្ណាញ គណៈគ្រប់គ្រងស.ម.ធ ព្រមទាំងគណៈគ្រប់គ្រងអគារធនធាន**




(សៀវភៅណែនាំប្រតិបត្តិសាលាមធ្យមសិក្សាធនធាន,២០១១)

### ២.៦.២ ការប្រើប្រាស់អគារធនធាន

**ក. ដំណាក់កាលដំបូង** ត្រូវរៀបចំកម្មវិធីមួយចំនួន ដើម្បីណែនាំឱ្យបុគ្គលិកអប់រំ សិស្សានុសិស្ស និងសាលាមធ្យមសិក្សាបណ្តាញស្គាល់ពីសម្ភាររូបវន្ត និងផលប្រយោជន៍របស់វាក្នុងការសិក្សា។

**ខ. អាទិភាពនៃការប្រើប្រាស់អគារធនធាន** អាគារធនធានគឺជាធនធានដែលសម្បូរបែបដែលមានតែ១គត់ នៅក្នុងសាលាមធ្យមសិក្សាបណ្តាញ។ វាមិនត្រឹមតែផ្តល់ការប្រើប្រាស់ដល់សាលាមធ្យមសិក្សាបណ្តាញប៉ុណ្ណោះទេ គឺសម្រាប់សហគមន៍សិក្សាក្នុងមូលដ្ឋានទាំងមូលដែរ។ តម្រូវការប្រើប្រាស់អាគារធនធានប្រាកដជាមានជំលែង ធៀបទៅនឹងលទ្ធភាពផ្គត់ផ្គង់ ដូច្នេះការកំណត់អាទិភាពជាការសំខាន់ណាស់។ ការកំណត់អាទិភាពអាស្រ័យលើលក្ខណៈវិនិច្ឆ័យដែលកំណត់ដោយគណៈកម្មការគ្រប់គ្រងសាលាមធ្យមសិក្សាធនធាន និងបណ្តាញ។

គណៈកម្មការគ្រប់គ្រងស.ម.ធ និងបណ្តាញត្រូវប្រជុំគ្នាវិភាគពីតម្រូវការជាអាទិភាពរួមសម្រាប់សាលាមធ្យមសិក្សាបណ្តាញទាំងមូល ដោយស្របតាមបេសកកម្ម និងចក្ខុវិស័យរបស់សាលាមធ្យមសិក្សាធនធាន និងសាលាបណ្តាញ ដូចជាសាលារៀនណាដែលខ្វះខាតជាងគេ? សាលារៀនណាដែលមានតម្រូការជាងគេ (ចំពោះសាលារៀន ដែលគ្មានសម្ភារៈសោះ មានអាទិភាពជាងសាលារៀនដែលមានសម្ភារៈដែរតែមិនទំនើប)។

### ២.៦.៣ មូលនិធិ និងប្រាក់ចំណូល

### ក. ការប្រើប្រាស់មូលនិធិ

**ក.១ រដ្ឋាភិបាលៈ ថវិការកម្មវិធី(PB)** : នា.ម.ច.ទមានតួនាទីសំខាន់ក្នុងការផ្តល់យោបល់ដល់ក្រសួង អយក, និងរាយការណ៍ច្បាស់លាស់ពីតម្រូវការហិរញ្ញវត្ថុ ចំណាយចរន្ត និងតម្លៃរំលោះរបស់ស.ម.ធ និងបណ្តាញសម្រាប់ដំណើរការសាលារៀន។ គម្រោងចំណាយប្រចាំឆ្នាំសម្រាប់អគារធនធាន ១.ទឹក និងភ្លើងក្នុងអគារធនធាន និង ២.វត្ថុធាតុដើម និងសម្ភារៈចាំបាច់សម្រាប់បន្ទប់ពិសោធន៍+កុំព្យូទ័រ។

**ខ. ការរក និងប្រើប្រាស់ប្រាក់ចំណូល** ដើម្បីត្រៀមទទួលខុសត្រូវផ្នែកមូលនិធិរបស់ស.ម.ធនៅឆ្នាំទី៣ និងឆ្នាំបន្តបន្ទាប់ ទាមទារឱ្យគណៈគ្រប់គ្រងអគារធនធាន គណៈគ្រប់គ្រងស.ម.ធនិងបណ្តាញ ព្រម

ទាំង អ្នកពាក់ព័ន្ធ ចូលរួមក្នុងដំណើរការកសាងផែនការ និងទទួលខុសត្រូវក្នុងការពង្រីក សមត្ថភាពធនធានហិរញ្ញវត្ថុរបស់សាលារៀនដើម្បីដោះស្រាយរាល់ចំណាយចាំបាច់ ទៅលើការប្រើប្រាស់( ទឹក ភ្លើង) បុគ្គលិក(កម្មករ...) ការជួសជុល សម្ភារបរិក្ខារ ការផ្គត់ផ្គង់ និងសម្ភារៈនានា។

**គ. មធ្យោបាយ ប្រភព និងជម្រើសមួយចំនួនដែលសាលាមធ្យមសិក្សាធនធានអាចរកថវិកាសម្រាប់ជានានិរន្តរភាពអគារធនធាន** ADB នឹងផ្តល់ការជួយឧបត្ថមប្រាក់ចំណាយ សម្រាប់ដំណើរការអគារធនធាន ចំនួន៧៨០០ដុល្លារ ដល់អគារធនធានមួយក្នុងមួយឆ្នាំ។ តាមការប៉ាន់ស្មានទៅលើការចំណាយចរន្តសម្រាប់មួយខែ ទៅលើដំណើរការ និងតម្លៃរំលោះសម្ភារបរិក្ខារគឺមានតម្លៃប្រមាណ ១៩០០ ដុល្លារសម្រាប់អគារធនធានមួយ ក្នុងមួយខែ។ នេះជាតម្លៃចំណាយខ្ពស់ បើធៀបនឹងលទ្ធភាពផ្គត់ផ្គង់របស់រដ្ឋ ដូច្នេះគណៈ គ្រប់គ្រងស.ម.ធ គួរស្វែងរកមូលនិធិ( ប្រាក់ចំណូល) បន្ថែមដើម្បីបន្តនិរន្តរភាព។

**ឃ. ការធានានិរន្តរភាពដំណើរការអគារធនធាន**

គណៈកម្មការគ្រប់គ្រងស.ម.ធ និងបណ្តាញត្រូវតែសិក្សាពីរបៀបរកទីផ្សារ និងបង្កើតប្រព័ន្ធទទួលខុសត្រូវមួយ ដើម្បីគ្រប់គ្រងកម្មវិធីរកប្រាក់ចំណូល ពីព្រោះកម្មវិធីនេះមិនមែនដើម្បីស្វែងរកផលប្រយោជន៍គិតតែពីប្រាក់ចំណេញនោះទេ ប៉ុន្តែគួរតែប្រើប្រាស់កម្មវិធីទាំងនេះសម្រាប់៖ ១)ជាផលប្រយោជន៍ដល់បុគ្គលិកដែលបានធ្វើការលើសម៉ោងឬគ្រប់គ្រងកម្មវិធី ២)ការថែរក្សា/ជួសជុលសម្ភារបរិក្ខារ ៣)ទិញវត្ថុធាតុដើម និង៤)ចំណាយចាំបាច់ផ្សេងៗក្នុងអគារធនធាន។ល។

## ២.៧ ការអភិវឌ្ឍវិជ្ជាជីវៈគ្រូបង្រៀន

ណារ៉ុន (២០២១) នៅក្នុងយុគសម័យនេះគ្រូបង្រៀនត្រូវមានលក្ខណៈសម្បត្តិ៥យ៉ាងដែលមាននៅក្នុងស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀនគឺ៖

ទីមួយ៖ ចំណេះដឹងខ្លឹមសារមេរៀនរឹងមាំ និងមានវប្បធម៌ទូទៅទូលំទូលាយ រួមទាំងចំណេះដឹងផ្នែកភាសាបរទេសផងដែរ។

ទីពីរ៖ បំណិនវិជ្ជាជីវៈជាពិសេសចំណេះដឹងខាងផ្នែកចិត្តវិទ្យា និងគរុកោសល្យ រួមទាំងសមត្ថភាព ក្នុងការស្រាវជ្រាវ។

ទីបី៖ ការអភិវឌ្ឍវិជ្ជាជីវៈជាប្រចាំ ដើម្បីមានបទពិសោធន៍កាន់តែខ្លាំងក្លាឡើង

ទីបួន៖ សីលធម៌វិជ្ជាជីវៈ ដើម្បីបង្កើតវប្បធម៌សាលារៀនវិជ្ជមាន និងផ្តល់ឱកាសឱ្យសិស្សបានសិក្សារៀនសូត្រ ដើម្បីសម្រេចបានសក្តានុពល។

ទីប្រាំ៖ បំណិនឌីជីថល និងការប្រើប្រាស់បច្ចេកវិទ្យា ក្នុងការអនុវត្តវិធីសាស្ត្របង្រៀន ដើម្បីអប់រំសិស្សឱ្យមានបំណិនសតវត្សទី២១។

## ២.៨ ស្ថានភាពនៃបច្ចេកវិទ្យាក្នុងវិស័យអប់រំ កម្ពុជា

សមត្ថភាពបច្ចេកវិទ្យាព័ត៌មាន និងទំនាក់ទំនង-ICT គឺផ្អែកលើការប្រើប្រាស់ឧបករណ៍ និងឧបករណ៍បច្ចេកទេសសម្រាប់ការចាប់យក ការរំខាន និងការផ្ទេរចំណេះដឹង។ ពួកវារួមបញ្ចូលបច្ចេកវិទ្យាណាមួយដែលជួយផលិត រៀបចំ រក្សាទុក ទំនាក់ទំនង និងផ្សព្វផ្សាយព័ត៌មាន។ សមត្ថភាព ICT ត្រូវបានប្រើប្រាស់បច្ចេកវិទ្យាក្នុងការគ្រប់គ្រង និងដំណើរការព័ត៌មាន រួមមានបច្ចេកវិទ្យាទាំងអស់សម្រាប់រៀបចំ និងទំនាក់ទំនងព័ត៌មាន។ វាមានន័យថាសមត្ថភាព ICT មានសារៈសំខាន់ខ្លាំងណាស់ក្នុងការធ្វើឱ្យប្រសើរឡើងនូវទំនាក់ទំនងនៅក្នុងដំណើរការសិក្សា និងការបង្រៀន។

នាប៉ុន្មានឆ្នាំចុងក្រោយនេះ ក្រសួងអប់រំ យុវជន និងកីឡាបានសហការជាមួយដៃគូអភិវឌ្ឍបានរៀប និងបង្កើតនូវគេហទំព័រសិក្សាស្រាវជ្រាវជាច្រើនមានដូចជា គេហទំព័រធនធានសិក្សាកម្ពុជា (oer.moeys.gov.kh) ដែលផ្តល់ភាពងាយស្រួលដល់គ្រូ ឬអ្នកសិក្សាអាចស្វែងរក និងចែករំលែកនូវធនធានសំបូរបែបដើម្បីលើកម្ពស់ការរៀន និងបង្រៀន។ គេហទំព័រ CPDMO(cpd.moeys.gov.kh) និងកម្មវិធី(app) HRCPD ដែលអនុញ្ញាតអោយគ្រូស្វែងរកសកម្មភាព អ.វ.ប ក្នុងការអភិវឌ្ឍវិជ្ជាជីវៈ។ កម្មវិធី (app) E-SCHOOL ដែលគ្រូអាចដក់ស្រងនូវខ្លឹមសារមេរៀន សំណួរ និងវីដេអូសម្រាប់ការបង្រៀប និងរៀនបាន។

### ២.៨.១ គោលនយោបាយចំពោះបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍

គោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំនៅកម្ពុជាបានបង្ហាញពីដំណាក់កាលមួយនៃការងារសំខាន់របស់ក្រសួងអប់រំយុវជន និងកីឡា ក្នុងការធ្វើកំណែទំរង់

សេវាអប់រំនៅកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់។ គោលនយោបាយនេះក៏បានបញ្ជាក់ច្បាស់អំពីការជួយគាំទ្រ និងលើកកម្ពស់ការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មានសម្រាប់ជនជួបការលំបាក (អយក, ២០០៤)។ គោលនយោបាយនេះមានខ្លឹមសារ និងផ្តោតការយកចិត្តទុកដាក់ចំពោះផែនសំខាន់ៗចំនួន៤ផែនទី១៖ បង្កលក្ខណៈឱ្យគ្រូ និងសិស្សគ្រប់រូបទាំងអស់ ជាពិសេសនៅកម្រិតមធ្យមសិក្សា បានប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដោយជានាអះអាងថា បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ពិតជាត្រូវបានប្រើប្រាស់ជាយានជួយកាត់បន្ថយគម្លាតឌីជីថល រវាងសាលារៀនកម្ពុជាជាមួយនឹងសាលារៀនផ្សេងៗទៀតនៅប្រទេសជិតខាង។

ផែនទី២៖ សង្កត់ធ្ងន់ទៅលើតួនាទី និងមុខងាររបស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដែលជាឧបករណ៍សម្រាប់រៀន និងបង្រៀនទៅតាមមុខវិជ្ជាផ្សេងៗ និងក៏ជាមុខវិជ្ជាដោយឡែកផងដែរ។ ការទទួលព័ត៌មានតាមអ៊ីនធឺណិត បណ្តាញព័ត៌មានអន្តរជាតិ និងការប្រាស្រ័យទាក់ទង គ្នាដែលកាន់តែសកម្មតាមរយៈអីមែល( សាអេឡិចត្រូនិច) រវាងសាលារៀនជាមួយសាលារៀន និង រវាងបុគ្គលជាមួយបុគ្គលនោះអាចបំពេញមុខនាទីយ៉ាងសំខាន់ នៅក្នុងការអភិវឌ្ឍអាជីពជូនអ្នកអប់រំ។

ផែនទី៣៖ លើកកម្ពស់ការអប់រំសម្រាប់ទាំងអស់គ្នា តាមរយៈការអប់រំពីចម្ងាយ និងស្វ័យសិក្សា ជាពិសេសគឺនៅក្នុងចំណោមក្រុមកុមារ ក្រុមជំទង់ និងក្រុមជនពេញវ័យជួបការលំបាក ដែលបាត់បង់ឱកាសចូលសិក្សានៅកម្រិតអប់រំមូលដ្ឋាន រួមមានអក្ខរកម្ម និងបណ្តុះបណ្តាលបំណិនដោយមិនគិតពីអាយុ ភេទ ជនជាតិភាគតិច ពិការភាព ឬទីកន្លែង ហើយត្រូវបានគួបផ្សំជាមួយនឹងវិទ្យុ ទូរទស្សន៍ ឯកសារបោះពុម្ភ និងប្រព័ន្ធផ្សព្វផ្សាយព័ត៌មានចម្រុះ។

ផែនទី៤៖ សង្កត់ធ្ងន់ទៅលើការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដើម្បីលើកកម្ពស់ផលិតភាព ភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពការគ្រប់គ្រងអប់រំ។ តាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មានគ្រប់គ្រងនេះ នឹងត្រូវបានប្រើប្រាស់កាន់តែច្រើន ដើម្បីឲ្យការងារមានល្បឿនលឿន ជាងមុន រួមមានការកត់ត្រាលទ្ធផលបំពេញមុខងាររបស់គ្រូ និងសិស្ស ការប្រាស្រ័យទាក់ទងព័ត៌មានរវាងរដ្ឋាភិបាលជាមួយ

នឹងសាលារៀន កិច្ចតែងការបង្រៀន ការវាយតម្លៃ ការធ្វើតេស្ត ការគ្រប់គ្រង ហិរញ្ញវត្ថុ និងការថែរក្សាបញ្ជីសារពើពន្ធ។

មួយវិញទៀតគោលនយោបាយនេះក៏បានផ្តោតជាសំខាន់ទៅលើផ្នែកពីរជាសំខាន់ទៀតដូចជា៖

១. ផ្តល់លទ្ធភាពទទួលបាននូវបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍សម្រាប់គ្រូ និងសិស្សទាំងអស់ ជាពិសេសនៅកម្រិតអនុវិទ្យាល័យដែលធានាថាបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ត្រូវបានប្រើជាឧបករណ៍សម្រាប់កាត់បន្ថយគម្លាតឌីជីថលរវាងសាលារៀននៅកម្ពុជា និងសាលារៀនដទៃទៀតនៅប្រទេសជិតខាង។

២.សង្កត់ធ្ងន់ទៅលើតួនាទីមុខងាររបស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដែលមាននៅក្នុងវិស័យអប់រំជាឧបករណ៍បង្រៀន និងរៀនក្នុងមុខវិជ្ជាផ្សេងៗគ្នា និងមុខវិជ្ជាខ្លួនវាផ្ទាល់។ ការទទួលបានព័ត៌មាននៅលើអ៊ីនធឺណិត និងបង្កើនការប្រាស្រ័យទាក់ទងគ្នាតាមរយៈអ៊ីម៉ែលរវាងសាលារៀន និងបុគ្គលិកអាចដើរតួនាទីយ៉ាងសំខាន់ក្នុងការអភិវឌ្ឍវិជ្ជាជីវៈរបស់អ្នកអប់រំ។ បន្ថែមលើវិទ្យុ និងទូរទស្សន៍ជាឧបករណ៍បង្រៀន និងរៀន។

លើសពីនេះទៅទៀតនៅឆ្នាំ២០១៨ គោលនយោបាយអប់រំនៃប្រទេសកម្ពុជាដែលបានបោះពុម្ពផ្សាយដោយក្រសួងអប់រំ យុវជន និងកីឡា បានចែងអំពីចំណុចសំខាន់ៗជាច្រើនដែលមានទាក់ទងទៅនឹងចក្ខុវិស័យ គោលដៅ យុទ្ធសាស្ត្រ និងគោលការណ៍ផ្សេងៗក្នុងការបង្រៀន និងរៀនដោយប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍។ ក្រសួងអប់រំយុវជន និងកីឡាមានចក្ខុវិស័យលើកយកការលើកកម្ពស់ការបង្រៀន និងរៀនសម្រាប់សិស្ស និស្សិតគ្រប់រូប ដែលបញ្ចប់ការសិក្សាឱ្យមានគំនិតនវានុវត្តន៍ ការច្នៃប្រឌិត ប្រកបដោយក្រមសីលធម៌ អាចប្រកួតប្រជែងបានក្នុងសង្គមព័ត៌មាន និងសេដ្ឋកិច្ច ដែលផ្អែកលើពុទ្ធិ។

## ២.៨.២ អត្ថប្រយោជន៍នៃការប្រើប្រាស់បច្ចេកវិទ្យា

តាមរយៈលោក (Alexander,2021) បានបង្ហាញអំពីអត្ថប្រយោជន៍ការប្រើប្រាស់បច្ចេកវិទ្យាចំនួន ៧ចំណុចដែលមានដូចជា៖

១. វាផ្តល់ជូននូវជម្រើសដ៏ធំទូលាយនៃសម្ភារៈដែលអាចចូលប្រើបានយ៉ាងងាយស្រួលព្រោះបច្ចេកវិទ្យាអប់រំដែលមាននាពេលបច្ចុប្បន្ននេះផ្តល់ឱ្យសិស្សនូវជម្រើសជាច្រើនដែលពួកគេអាចជ្រើសរើសអ្វីដែលល្អបំផុតសម្រាប់តម្រូវការសិក្សារបស់ពួកគេ។ ហើយវាជួយពួកគេអភិវឌ្ឍជំនាញ និងចំនេះដឹងត្រឹមត្រូវ ដើម្បីឱ្យពួកគេអាចក្លាយជាអ្នកជំនាញដ៏ល្អនៅក្នុងវិស័យដែលពួកគេជ្រើសរើស។

២.វាជួយកែលម្អជំនាញទំនាក់ទំនងរបស់អ្នកសិក្សា និងការអនុវត្តនៅក្នុងការកំណត់សាលារៀន និងកន្លែងធ្វើការ។អ្នកសិក្សាដែលអាចប្រាស្រ័យទាក់ទងគ្នាបានកាន់តែប្រសើរឡើងតាមរយៈមធ្យោបាយបច្ចេកវិទ្យាក៏នឹងអនុវត្តការសិក្សាបានប្រសើរជាងមុន ក៏ដូចជានៅក្នុងការកំណត់ការងារផងដែរ ពីព្រោះជំនាញទំនាក់ទំនងមានសារៈសំខាន់ណាស់ដើម្បីសម្រេចគោលដៅលដៅប្រកបដោយប្រសិទ្ធភាព។

៣.វាផ្តល់នូវបទពិសោធន៍សិក្សាដ៏រីករាយ និងទាក់ទាញសម្រាប់សិស្សដែលសព្វថ្ងៃសិស្សមិនត្រឹមតែតម្រូវឱ្យរៀនប៉ុណ្ណោះទេ បច្ចេកវិទ្យាអប់រំផ្តល់ឱ្យសិស្សនូវឱកាសឱ្យមានភាពសប្បាយរីករាយក្នុងពេលកំពុងសិក្សា ដែលនឹងជួយឱ្យពួកគេរក្សាការលើកទឹកចិត្ត និងរំភើបចំពោះការសិក្សារបស់ពួកគេ។

៤.វាអនុញ្ញាតឱ្យអ្នកសិក្សាអាចចូលប្រើអ៊ីនធឺណិតពីគ្រប់ទីកន្លែងគ្រប់ពេលវេលា អ៊ីនធឺណិតបានក្លាយជាផ្នែកសំខាន់មួយនៃជីវិតរបស់យើង ដែលយើងស្ទើរតែរកមនុស្សដែលមិនប្រើវាជារៀងរាល់ថ្ងៃ។ នៅក្នុងពិភពលោកនាពេលបច្ចុប្បន្ននេះ វាមានសារៈសំខាន់ណាស់សម្រាប់សិស្សានុសិស្សដើម្បីអាចចូលប្រើអ៊ីនធឺណិតពីគ្រប់ទីកន្លែងគ្រប់ពេលវេលា ដើម្បីពួកគេអាចធ្វើការងារ និងស្រាវជ្រាវរបស់ពួកគេដោយមិនចាំបាច់ធ្វើដំណើរគ្រប់ទីកន្លែង ឬរង់ចាំពេលវេលាជាក់លាក់ណាមួយនៅពេលដែលពួកត្រូវការ គេអាចធ្វើដូច្នេះបាន។ ការប្រើប្រាស់បច្ចេកវិទ្យាអប់រំជួយសិស្សក្នុងរឿងនេះ ព្រោះវាអនុញ្ញាតឱ្យពួកគេភ្ជាប់ជាមួយអ៊ីនធឺណិត ទោះបីជាពួកគេនៅក្នុងថ្នាក់រៀន សាលារៀន ឬនៅផ្ទះក៏ដោយ។

៥.វាជួយសិស្សរៀនជំនាញថ្មី និងទទួលបានចំណេះដឹងថ្មីៗការរៀនជំនាញថ្មី និងការទទួលបានចំណេះដឹងថ្មីគឺជាទិដ្ឋភាពសំខាន់ពីរយ៉ាងនៃជីវិតដែលអ្នកសិក្សាគួរតែអាចរីករាយ។ តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាអប់រំ អ្នកសិក្សាអាចទទួលបានជំនាញទាំងនេះ ហើយក៏អាចអភិវឌ្ឍចំណេះដឹងរបស់ពួកគេតាមរយៈកម្មវិធីផ្សេងៗដែលមាននៅលើអ៊ីនធឺណិត។ កម្មវិធីទាំងនេះផ្តល់ជូនសិស្សនូវឱកាសដើម្បី

ស្វែងយល់អំពីប្រធានបទផ្សេងៗដែលគួរឱ្យចាប់អារម្មណ៍ និងមានប្រយោជន៍សម្រាប់វិស័យការងារ ឬការសិក្សារៀងៗខ្លួន។

៦.វាអនុញ្ញាតឱ្យសិស្សកែលម្អខ្លួនឯងទាំងផ្លូវចិត្ត និងរាងកាយ តាមរយៈការប្រើប្រាស់ឧបករណ៍ទាំងនេះ សិស្សានុសិស្សអាចបង្កើនការរៀនសូត្រ និងជំនាញការយល់ដឹងរបស់ពួកគេ ដែលជួយពួកគេឱ្យប្រសើរឡើងនូវការអនុវត្តការសិក្សារបស់ពួកគេ ក៏ដូចជាសុខភាពរាងកាយរបស់ពួកគេ។

៧.វាជួយអ្នកសិក្សាឱ្យទាន់សម័យជាមួយនឹងភាពជឿនលឿននៃបច្ចេកវិទ្យាថ្មីៗ សិស្សានុសិស្សដែលអាចបន្តជឿនលឿនតាមបច្ចេកវិជ្ជាចុងក្រោយបង្អស់នឹងអាចបង្កើនចំនេះដឹងរបស់ពួកគេលើវិស័យផ្សេងៗ និងអភិវឌ្ឍជំនាញថ្មីៗដែលពួកគេអាចប្រើប្រាស់បាននាពេលអនាគត។ និស្សិតទាំងនេះក៏នឹងទំនងជាស្វែងរកការងារធ្វើផងដែរ ព្រោះវានឹងមានការយល់ដឹងយ៉ាងល្អអំពីនិន្នាការចុងក្រោយបំផុតក្នុងវិស័យផ្សេងៗ និងអាចជួយក្រុមហ៊ុនឱ្យកាន់តែមានប្រសិទ្ធភាពដោយដឹងពីរបៀបដែលបច្ចេកវិទ្យាថ្មីអាចត្រូវបានប្រើប្រាស់សម្រាប់គោលបំណងផ្សេងៗ។

ចំណែក ( Margaret and Peter ,2006 ) ក៏បានលើកឡើងផងដែរនូវអត្ថប្រយោជន៍នានាដែលបានមកពីការបច្ចេកវិទ្យា នៅក្នុងការអប់រំ ដែលមានដូចខាងក្រោមនេះ៖ ការទទួលបានចំណេះដឹងជាសកលការចែករំលែកបទពិសោធន៍និងការអនុវត្តល្អបំផុតបានឆាប់រហ័ស ដើរដោយខ្លួនឯង និងការរៀនសូត្រដោយខ្លួនឯង ការរៀនសូត្រក្លាយជាអន្តរកម្មនិងរីករាយតាមរយៈឧបករណ៍ព័ត៌មានសំម្បូរណ៍បែប។ ការជំរុញការរៀនសូត្រលើការពិសោធន៍ ការបើកឱ្យមានការគិតថ្មី និងបង្កើតបរិយាកាសនៃការបង្កើតថ្មី។

បើយោងតាម ( Anthony,2012 ) ផលប៉ះពាល់នៃអាយស៊ីធីក្នុងវិស័យអប់រំមិនអាចត្រូវបានសង្កត់ធ្ងន់ទេ តែមានការកត់សម្គាល់បានថាវាបានផ្តល់នូវគុណប្រយោជន៍មួយចំនួនដូចជា៖១.បានលុបបំបាត់បញ្ហាទាក់ទងនឹងលំហ និងពេលវេលា សិស្សអាចទំនាក់ទំនងគ្នាបានគ្រប់ទីកន្លែងគ្រប់ពេលវេលាសិស្សអាចទាក់ទងគ្រូគ្រប់ទីកន្លែងគ្រប់ពេលវេលា និស្សិតអាចប្រមូល និងផ្លាស់ប្តូរព័ត៌មានគ្រប់ទីកន្លែងគ្រប់ពេលវេលា។២.ផ្តល់លទ្ធភាពទទួលបានចំណេះដឹងជាគោលការណ៍ សិស្សអាចទាញយកចំណេះដឹងជាសកល។ ៣.ធ្វើឱ្យការបម្រើនិងចែករំលែកចំណេះដឹងកាន់តែងាយស្រួល សិស្សអាចអាចធ្វើការជាបុគ្គល ឬរួម

គ្នាបង្កើតកំណត់ត្រា និងធ្វើបទបង្ហាញពីវឌ្ឍនភាពរបស់ពួកគេ ហើយពួកគេអាចប្រើវាក្នុងការងារប្រឡងផ្សេងៗ។សិស្សនិស្សិតអាចទទួលបានបណ្តុះបណ្តាលសម្រាប់ការចូលរួមការស្រាវជ្រាវទំនាក់ទំនងជាសកលនាពេលអនាគត។

### ២.៨.៣ ផលប៉ះពាល់នៃបច្ចេកវិទ្យាអប់រំ

ប៉ុន្មានឆ្នាំថ្មីៗនេះបានឃើញការវិវត្តន៍ដ៏អស្ចារ្យនៅក្នុងពិភពបច្ចេកវិទ្យា។ ជាមួយនឹងមនុស្សកាន់តែច្រើនឡើងចូលទៅក្នុងប្រព័ន្ធផ្សព្វផ្សាយឌីជីថល វាចាំបាច់សម្រាប់គ្រូបង្រៀនក្នុងការប្រើឧបករណ៍ចុងក្រោយបំផុតដែលមាននៅក្នុងការងាររបស់ពួកគេដើម្បីចូលរួមជាមួយសិស្ស។ ដើម្បីចូលរួមជាមួយសិស្សក្នុងការរៀនសូត្រ មនុស្សម្នាក់ត្រូវតែមានគំនិតច្នៃប្រឌិត និងគំនិតថ្មីៗគួរតែត្រូវបានណែនាំដើម្បីឱ្យសិស្សមានការរំភើបអំពីអ្វីដែលពួកគេកំពុងរៀន។ ការប្រើប្រាស់បច្ចេកវិទ្យាអប់រំបានក្លាយជាកត្តាចាំបាច់សម្រាប់គ្រូបង្រៀន ដោយសារសារៈសំខាន់របស់វានៅក្នុងឧស្សាហកម្មអប់រំនាពេលបច្ចុប្បន្ននេះ។

ភាពជឿនលឿននៃបច្ចេកវិទ្យាដែលបានធ្វើឡើងក្នុងរយៈពេលជាច្រើនឆ្នាំបានជះឥទ្ធិពលលើគ្រប់វិស័យនៃជីវិត។ ដោយសារបច្ចេកវិទ្យាកាន់តែអាចចូលប្រើប្រាស់បាន វាបានជ្រាបចូលទៅក្នុងគ្រប់ផ្នែកនៃជីវិតរបស់យើង ហើយជាលទ្ធផល ឥឡូវនេះយើងរំពឹងថាគ្រប់ឧបករណ៍ទាំងអស់ដែលយើងប្រើនឹងមានភាពជឿនលឿនតាមដែលអាចធ្វើបាន។ សាលារៀនក៏បានទទួលយកបច្ចេកវិទ្យាជាផ្នែកសំខាន់នៃដំណើរការអប់រំរបស់ពួកគេ ហើយជាលទ្ធផល ឥឡូវនេះពួកគេផ្តល់ជូននូវថ្នាក់វិទ្យាសាស្ត្រកុំព្យូទ័រ ដែលសិស្សរៀនពីរបៀបសរសេរកូដកុំព្យូទ័រ និងប្រើប្រាស់វាសម្រាប់ការងារ ឬគម្រោងរបស់ពួកគេ។

តាមការសិក្សាស្រាវជ្រាវមួយរបស់(Serkan Unal and Ibrahim Hakki Ozturk,2012) ដែលបានសិក្សាពីឧបសគ្គចំពោះការធ្វើសមាហរណកម្ម ICT ទៅក្នុងការបង្រៀនរបស់គ្រូបង្រៀន ករណីសិក្សាស្តីពី គ្រូបង្រៀនសិក្សាសង្គមនៅក្នុងប្រទេសទួរគី ជាលទ្ធផលបានបង្ហាញថាបញ្ហាប្រឈមរបស់គ្រូបង្រៀនទាំងនោះរួមមាន៖

១.កង្វះឧបករណ៍អាយស៊ីធីនៅក្នុងថ្នាក់រៀន៖ ការរកឃើញរបស់ការសិក្សានេះបង្ហាញថាមធ្យោបាយនៃឧបករណ៍បច្ចេកវិទ្យាស្ថាប័ន ឬទិញសម្រាប់ប្រើប្រាស់ក្នុងសាលារៀន និងជាពិសេសនៅក្នុង

បរិយាកាសថ្នាក់រៀនមានលក្ខណៈកម្រណាស់ ដែលប៉ះពាល់យ៉ាងខ្លាំងដល់ការប្រើប្រាស់វិធីសាស្ត្រផ្អែកលើបច្ចេកវិទ្យា ហើយនឹងការប្រើប្រាស់ធនធានអាយស៊ីធីនៅក្នុងថ្នាក់របស់ពួកគេ ដោយប្រើប្រាស់សម្ភារៈទាំងនោះក្នុងការអនុវត្តការបង្រៀនរបស់ពួកគេ។

២.កង្វះធនធានបង្រៀនផ្អែកលើបច្ចេកវិទ្យា ៖ កង្វះនៃការច្នៃប្រឌិត និងគុណភាពនៃធនធានបង្រៀនគឺជាឧបសគ្គដ៏សំខាន់មួយដែលប្រឆាំងនឹង ការរួមបញ្ចូលប្រកបដោយប្រសិទ្ធភាពក៏ដូចផលិតភាពនៃអាយស៊ីធីក្នុងការអនុវត្តថ្នាក់រៀនរបស់គ្រូ។

៣.ជំនឿរបស់គ្រូ និងផលប៉ះពាល់នៃវិធីសាស្ត្របង្រៀនតាមបែបប្រពៃណី៖ ជាទូទៅគ្រូបង្រៀនមិនទាន់មានជំនឿចិត្តក្នុងការប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា នៅក្នុងការបង្រៀន ហើយគ្រូបង្រៀនមួយចំនួនទៀតយល់ថាការបង្រៀនដោយប្រើប្រាស់ វិធីសាស្ត្រប្រពៃណីមានលក្ខណៈងាយស្រួលជាង។

៤.បញ្ហាទាក់ទងនឹងការបណ្តុះបណ្តាលគ្រូក្នុងការបង្រៀន៖ ការពិតដែលថាគ្រូបង្រៀនមិនមានចំណេះដឹងគ្រប់គ្រាន់អំពីវិធីសាស្ត្រ និងវិធីសាស្ត្រផ្អែកលើអាយស៊ីធីប្រកបដោយភាពច្នៃប្រឌិតនាំមកនូវបញ្ហាទាក់ទងនឹងការបណ្តុះបណ្តាលគ្រូ។ បញ្ហាពាក់ព័ន្ធមួយទៀតគឺការបណ្តុះបណ្តាលដែលបានផ្តល់ឱ្យអំពីអាយស៊ីធីភាគច្រើនគឺ សម្រាប់ចំណេះដឹងនិងជំនាញទូទៅ។

៥.បញ្ហាទាក់ទងនឹងកង្វះពេលវេលា៖ ភាពទូលំទូលាយ និងគុណភាពនៃការបណ្តុះបណ្តាលគ្រូការសិក្សាបង្ហាញថាបញ្ហាទាក់ទងនឹងកង្វះពេលវេលាគឺ កម្មវិធីបណ្តុះបណ្តាលគ្រូ។ ទីបំផុតបញ្ហាទាក់ទងនឹងកង្វះពេលវេលា ក៏ជាឧបសគ្គមួយទៀតរារាំងប្រឆាំងនឹងការប្រើប្រាស់វិធីសាស្ត្របង្រៀនផ្អែកលើអាយស៊ីធីការធ្វើសមាហរណកម្ម ICT ទៅក្នុងការអនុវត្តថ្នាក់រៀនរបស់គ្រូ។

## ២.៩ សមត្ថភាព និងតួនាទីគ្រូបង្រៀន

និយាយអំពីការអប់រំ ពិតណាស់មានទំនាក់ទំនងជិតស្និទ្ធជាមួយគ្រូ។ ក្នុងនាមជាអ្នកមានវិជ្ជាជីវៈដែលដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការអប់រំ គ្រូបង្រៀនក្លាយជាបុគ្គលដ៏សំខាន់ក្នុងការកំណត់ភាពជោគជ័យនៃការអប់រំ។ នេះក៏ព្រោះថាគ្រូបង្រៀងប្រៀបបាននឹងទ័ពស្រួចរបស់ក្រសួងអប់រំ ដែលស្ថិតនៅក្នុងសមរភូមិមុខ ក្នុងសង្គ្រាមនៃការអប់រំ គ្រូបង្រៀនជាអន្តរបុគ្គលផ្ទាល់ និងត្រូវបង្កើតទំនាក់ទំនងល្អ ឬ

ទំនាក់ទំនងល្អជាមួយសិស្ស វាបម្រើដើម្បីលើកទឹកចិត្ត និងគ្រប់គ្រងអារម្មណ៍របស់សិស្សបានយ៉ាងល្អ (Looney, 2011)។

**គុណភាពគ្រូបង្រៀន** គឺជាគន្លឹះដ៏សំខាន់ក្នុងការអភិវឌ្ឍន៍ការអប់រំប្រកបដោយគុណភាព (Harris, 2011)។ ជាការពិតណាស់ គ្រូបង្រៀនដែលមានសមត្ថភាពនឹងក្លាយជាកត្តាកំណត់នៃភាពជោគជ័យនៃការអប់រំដែលមានស្រាប់។

**គុណភាពគ្រូបង្រៀន** គឺពិតជាត្រូវបានគេមើលឃើញនៅក្នុងទិដ្ឋភាពផ្សេងៗ។ ទិដ្ឋភាពទាំងនេះគឺជាកត្តាកំណត់គុណភាពគ្រូបង្រៀននាពេលបច្ចុប្បន្ន។ Looney (2011) បានពន្យល់ថា គ្រូបង្រៀនដែលមានសមត្ថភាពត្រូវមានសមត្ថភាពជាច្រើន រួមទាំងមានចំណេះដឹងទូលំទូលាយ បង្កើតទំនាក់ទំនងល្អ ការគ្រប់គ្រងថ្នាក់រៀន សមត្ថភាពក្នុងការវាយតម្លៃ ជំនាញពាក្យសំដី ការបង្រៀន និងជំនាញសហការគ្នានៅកន្លែងធ្វើការ។ ស៊ីជម្រៅដោយ Liakopoulou (2011) ថាគ្រូបង្រៀនដែលមានសមត្ថភាព/សមត្ថភាពបានបែងចែកជាបួន៖ 1) មានបុគ្គលិកលក្ខណៈល្អ 2) ជំនាញបង្រៀនល្អ 3) ចំណេះដឹងទូលំទូលាយ និង 4) អាកប្បកិរិយា និងអាកប្បកិរិយានៃការបង្រៀន។ ដូច្នេះ គ្រូដែលមានសមត្ថភាព ប្រាកដជាត្រូវបំពេញគ្រប់ទិដ្ឋភាពទាំងនេះ។

**សមត្ថភាពគ្រូបង្រៀន** គឺជាការរួមបញ្ចូលគ្នានៃជំនាញ ចំណេះដឹង អាកប្បកិរិយា និងតម្លៃដែលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងទម្លាប់នៃសកម្មភាព និងការគិត (Suhadi, 2014)។ ជាងនេះទៅទៀតតាមរយៈលោក Hakim (2015) បានលើកឡើងថាជាសមត្ថភាពរបស់មនុស្សក្នុងការអនុវត្តការងារ ឬការអនុវត្តការងារ ឬភារកិច្ចដែលផ្អែកលើជំនាញផ្សេងៗ ចំណេះដឹង និងអាកប្បកិរិយាការងារ។ សមត្ថភាពក្លាយជាសកម្មភាពជាបន្តបន្ទាប់ដែលមនុស្សម្នាក់ធ្វើដោយស្មារតីទទួលខុសត្រូវចំពោះលក្ខខណ្ឌនៃភាពជោគជ័យក្នុងការបំពេញភារកិច្ច (Yasin, 2011)។ សមត្ថភាពគឺជាកត្តាកំណត់នៃភាពជោគជ័យនៃគុណភាពរបស់គ្រូខ្លួនឯង។ គ្រូដែលមានសមត្ថភាព ប្រាកដជាមានជំនាញល្អ។

សមត្ថភាពមួយដែលត្រូវការដោយគ្រូសព្វថ្ងៃគឺជំនាញគរុកោសល្យ។ សមត្ថភាពគរុកោសល្យទាក់ទងនឹងរបៀបដែលគ្រូបង្រៀន ជំនាញបង្រៀនរបស់គ្រូ ការប្រើប្រាស់យុទ្ធសាស្ត្រ និងវិធីសាស្ត្រសម

ស្រប។ ជាទូទៅ គោលគំនិតនៃសមត្ថភាពគរុកោសល្យ គឺសមត្ថភាពក្នុងការយល់អំពីអ្នកសិក្សា រៀបចំការបង្រៀន និងអនុវត្តក្នុងការធ្វើពេគវិនិច្ឆ័យការសិក្សា វាយតម្លៃការរៀន និងអភិវឌ្ឍការរៀនសូត្រ (Hakim, 2015)។ មួយវិញទៀត Yasin (2011)ក៏បានបង្ហាញថា សមត្ថភាពគរុកោសល្យគឺជាសមត្ថភាពរបស់អ្នកអប់រំក្នុងការគ្រប់គ្រងការរៀនសូត្ររបស់សិស្ស រួមទាំង។ ការយល់ដឹងរបស់សិស្ស បង្កើតការរចនាការរៀនសូត្រ ការអនុវត្តការរៀនសូត្រ សមត្ថភាពក្នុងការវាយតម្លៃលទ្ធផលសិក្សា អភិវឌ្ឍសិស្សក្នុងការអនុវត្តសក្តានុពលរបស់ពួកគេ។

លើសពីនេះ សមត្ថភាពគរុកោសល្យមិនត្រឹមតែនិយាយអំពីវិធីសាស្ត្របង្រៀនប៉ុណ្ណោះទេ ប៉ុន្តែមានចំណុចជាច្រើនទៀតដែលទាក់ទងយ៉ាងស៊ីជម្រៅទៅនឹងសមត្ថភាពគរុកោសល្យ។ សមត្ថភាពគរុកោសល្យគឺជាសមត្ថភាពរបស់បុគ្គលក្នុងការសំរបសំរួល និងសមត្ថភាពក្នុងការរួមបញ្ចូលគ្នានូវប្រភពនៃចំណេះដឹងនៅក្នុងការរួមបញ្ចូលគ្នាដូចជា (សៀវភៅ អត្ថបទ និងប្រភពផ្សេងទៀត) និងរួមបញ្ចូលគ្នានូវប្រភពខាងក្រៅរបស់វា (ដូចជាជំនាញ បទពិសោធន៍ និងចំណេះដឹង) ដើម្បីទទួលបានសមត្ថភាពគរុកោសល្យប្រកបដោយប្រសិទ្ធភាព ( Suciu, 2011) ។ កាន់តែសាមញ្ញ Apelgren (2010) ពន្យល់ថា សមត្ថភាពគរុកោសល្យ គឺជាសមត្ថភាពក្នុងការប្រើប្រាស់អាកប្បកិរិយា ចំណេះដឹង និងសមត្ថភាពបង្រៀន ដើម្បីជួយសិស្សតាមរបៀបដ៏ល្អបំផុត។ ដូចនេះ សមត្ថភាពគរុកោសល្យ គឺជាសមត្ថភាពមួយដែលគ្រូបង្រៀនត្រូវអភិវឌ្ឍនៅពេលនេះ។

គុណភាពនៃសមត្ថភាពគរុកោសល្យទាក់ទងនឹងវិធីដែលគ្រូប្រើក្នុងការបង្រៀនសិស្សហើយវាបានដើរតួនាទីយ៉ាងសំខាន់ក្នុងដំណើរការសិក្សា។ សមត្ថភាពនេះបានប្រែក្លាយការបង្រៀនទៅជា តួនាទីមួយក្នុងការសម្រេចបាននូវការសិក្សាប្រកបដោយគុណភាពដែលអាចបង្ហាញពីវិជ្ជាជីវៈរបស់គ្រូផ្ទាល់ផងដែរ (Hakim, 2015)។ សមត្ថភាពគរុកោសល្យគឺជាកត្តាសំខាន់ក្នុងការអភិវឌ្ឍន៍ និងសម្រេចបាននូវការអប់រំប្រកបដោយគុណភាពខ្ពស់ (Apelgren, 2011)។ ដូច្នេះ សមត្ថភាពគរុកោសល្យដែលមានដោយគ្រូនៅពេលនេះ ចាំបាច់ត្រូវមានការអភិវឌ្ឍន៍ និងធ្វើឲ្យប្រសើរឡើង។

**ខ. គំរូអភិវឌ្ឍន៍សមត្ថភាព**

ក្នុងការអភិវឌ្ឍន៍សមត្ថភាព ត្រូវបានគេយកចិត្តទុកដាក់ទៅលើគំរូអភិវឌ្ឍន៍សមត្ថភាពជាច្រើន ដែលមិនត្រឹមតែមាននៅក្នុងប្រទេសប៉ុណ្ណោះទេ ថែមទាំងនៅក្នុងប្រទេសផ្សេងៗក្នុងតំបន់ ទាំងមូលដែលត្រូវបានអនុវត្តក្នុងការអភិវឌ្ឍន៍សមត្ថភាពផងដែរ។ ជាការពិតណាស់ គំរូមួយជាមួយនឹងគំរូមួយផ្សេងទៀត មានប្រព័ន្ធ និងទម្រង់ផ្សេងគ្នា។ មានគំរូអភិវឌ្ឍន៍សមត្ថភាពគ្រូបង្រៀនជាច្រើនប្រភេទ។ គំរូដែលមានជាច្រើន ដែលក្នុងនោះគឺការគ្រប់គ្រងតាមសាលា (SBM)។ យោងតាមគោលគំនិត SBM ដែលមានទំនោលទៅលើការអភិវឌ្ឍន៍ដើម្បីបង្កើនប្រសិទ្ធភាពរបស់សាលាដោយផ្តល់ស្វ័យភាពទាំងអស់ដល់ការគ្រប់គ្រងសាលារៀន និងអ្នកពាក់ព័ន្ធក្នុងការរៀបចំការសម្រេចចិត្ត និងការគ្រប់គ្រងផ្ទៃក្នុង (Syahruddin, 2013)។ សរុបមក គោលគំនិតរបស់ SBM គឺសាមញ្ញណាស់ អ្វីដែលត្រូវបានសង្កត់ធ្ងន់គឺសមត្ថភាពក្នុងការគ្រប់គ្រងដោយខ្លួនឯង។

## ២.៩.១ អភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀន ក្នុងពេលបម្រើការងារ

ដើម្បីអភិវឌ្ឍសមត្ថភាពវិជ្ជាជីវៈគ្រូបង្រៀនក្នុងពេលបម្រើការងារ ត្រូវបានបណ្តុះវប្បធម៌រៀនពេញមួយជីវិតដោយចេះចែករំលែកចំណេះដឹង និងបទពិសោធន៍ជាមួយបណ្តាញ ក្រុមអ្នកអប់រំ។ ត្រូវអភិវឌ្ឍ និងអនុវត្តការងារវិក្រឹតការគ្រូបង្រៀន ពង្រឹងចំណេះដឹងភាសាខ្មែរ គណិតវិទ្យា ប្រវត្តិវិទ្យា និងវិទ្យាសាស្ត្រសម្រាប់គ្រូបង្រៀនថ្នាក់ទី៩ និងថ្នាក់ទី១២។ សិក្សាវាយតម្លៃតម្រូវការនៃការងារវិក្រឹតការគ្រូបង្រៀននិងកសាងជម្រើសនានាសម្រាប់ការងារវិក្រឹតការ ព្រមទាំងបង្កើតប្រព័ន្ធវិក្រឹតការរៀបរយសម្រាប់វិក្រឹតការគ្រូបង្រៀនដោយផ្អែកលើអតីតភាពការងារ។ បង្កើតឲ្យមានរចនាសម្ព័ន្ធការងារវិក្រឹតការថ្មីមួយនៅក្នុងគ្រឹះស្ថានបណ្តុះបណ្តាលគ្រូ បង្រៀន(វិទ្យាស្ថានបណ្តុះបណ្តាលគ្រូបង្រៀន) អនុវត្តការងារវិក្រឹតការតាមបីរូបភាព៖ ១.នៅនឹងកន្លែង ២.មិនរៀបរយតាមការចាំបាច់នៃវិស័យអប់រំ ៣.រៀបរយដែលមានប្រព័ន្ធកម្មវិធីត្រឹមត្រូវ។ រៀបចំវគ្គវិក្រឹតការបង្កើនគុណវុឌ្ឍិគ្រូបង្រៀនតាមរូបភាព៖ ១.វិក្រឹតការជាជំហានៗ(មួយជុំ២ជំហាន ហើយមួយជំហាន១.៥ខែ) ២.វិក្រឹតការរយៈពេលវែង(១ ឬ២ឆ្នាំ) និង៣.វិក្រឹតការតាមប្រព័ន្ធក្រេឌីតធ្វើនៅនឹងកន្លែងឬតាមការសិក្សាពីចម្ងាយដែលមានការវាយតម្លៃ និងគ្រប់គ្រងច្បាស់លាស់ដើម្បីទទួល

បានសញ្ញាបត្រសមមូលនឹងសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ សញ្ញាបត្របរិញ្ញាបត្រ និងសញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់។

អនុវត្តអាហារូបករណ៍ និងកម្មវិធីបណ្តុះបណ្តាលដោយប្រើលិខិតបញ្ជាក់សម្រាប់ការងារ វិក្រឹតការ (កម្មវិធីវិក្រឹតការពន្លឿនសម្រាប់ឲ្យគ្រូបង្រៀនទទួលបានសញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់) ដោយផ្តល់អាហារូបករណ៍ និងកម្មវិធីបណ្តុះបណ្តាលដោយប្រើលិខិតបញ្ជាក់ចំនួន ១០០០កន្លែងក្នុងមួយឆ្នាំ ដល់បេក្ខជនជ័យលាភីក្នុងការប្រឡងប្រជែងនិងការវាយតម្លៃគ្រូបង្រៀន។ ចាប់ផ្តើមដំណើរការវគ្គវិក្រឹតការដល់បេក្ខជនជ័យលាភីឲ្យទទួលបានសញ្ញាបត្រ បរិញ្ញាបត្រ ឬបរិញ្ញាបត្រជាន់ខ្ពស់និងពិនិត្យ តាមដានការអនុវត្តអាហារូបករណ៍ព្រមទាំងផ្តល់ អាទិភាពដល់គ្រូឧទ្ទេសនៅគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនឲ្យទទួលបានវិក្រឹតការលើកកម្ពស់សមត្ថភាពរបស់ខ្លួន ឲ្យមានកម្រិតយ៉ាងទាបបរិញ្ញាបត្រជាន់ខ្ពស់។ បង្កើតប្រព័ន្ធក្រេឌីត សម្រាប់ផ្តល់ក្រេឌីតដល់អ្នកដែលបានឆ្លងកាត់វគ្គវិក្រឹតការ ត្រូវធ្វើការរៀបចំឲ្យមានការឯកភាពគ្នាមួយលើរាល់ប្រភេទនៃវិក្រឹតការ ដើម្បីកំណត់ចំនួនក្រេឌីតចាំបាច់សម្រាប់ទទួលបាននូវការលើកកម្ពស់គុណវុឌ្ឍិ និងផលប្រយោជន៍បន្ថែម(បៀវត្ស ដំឡើងតួនាទី) ឧ.១.វគ្គសិក្សារយៈ ពេលវែង ២.វិក្រឹតការមិនរៀបរយទាំងក្នុងនិងឆ្លងវិស័យ ៣.វគ្គសិក្សាការងាររដ្ឋបាល ៤.ការ បំប៉នសមត្ថភាពនៅនឹងកន្លែង និង៥. សមិទ្ធផលផ្សេងទៀត។ សមាហរណកម្មរាល់សកម្មភាពការងារវិក្រឹតការទាំងអស់ដែលរៀបចំដោយក្រសួងអប់រំ ម្ចាស់ជំនួយ អង្គការក្រៅរដ្ឋាភិបាល ដោយប្រើប្រាស់ស្តង់ដារជាប្រព័ន្ធ ក្រេឌីត និងប្រព័ន្ធទិន្នន័យតាមដានការងារវិក្រឹតការ។

លើកកម្ពស់ការសិក្សាពេញមួយជីវិតរបស់គ្រូបង្រៀន។រៀបចំ និងអភិវឌ្ឍប្រភេទវគ្គបណ្តុះបណ្តាលមួយចំនួនភ្ជាប់នឹងការលើកទឹកចិត្តនិងប្រព័ន្ធក្រេឌីតដែលគ្រូបង្រៀន អាចជ្រើសរើសបានសម្រាប់បំប៉នសមត្ថភាពលើការអប់រំបញ្ចូលគ្នាICT ប្រព័ន្ធផ្សព្វផ្សាយចម្រុះ ការរៀន ពហុភាសា ការសិក្សាស្រាវជ្រាវមេរៀន ការប្រើប្រាស់បណ្ណាល័យ ការបង្រៀនភាសាអង់គ្លេស ការផលិតនិងប្រើប្រាស់សម្ភារឧបទេស។ ពង្រឹងប្រព័ន្ធគាំទ្រគ្រូបង្រៀននៅនឹងកន្លែង គឺត្រូវធ្វើការសិក្សាពីចំណុចខ្លាំង ចំណុចខ្សោយនិងការប្រឈមនានាដើម្បីឈ្វេងយល់កាន់តែច្បាស់ពីតម្រូវការវិជ្ជាជីវៈរបស់គ្រូបង្រៀន នៅនឹងកន្លែងធ្វើការ។ អភិវឌ្ឍ និង

អនុវត្តយន្តការគាំទ្រគ្រូបង្រៀននៅសាលារៀន ដើម្បីពង្រឹងចំណេះដឹងមុខវិជ្ជាឯកទេសនិងគរុកោសល្យ។ បង្កើតជាប្រព័ន្ធមួយសម្រាប់រាល់ការបំប៉នសមត្ថភាពគ្រូបង្រៀននៅនឹងកន្លែងគ្រប់គ្រឹះស្ថានសិក្សា គឺធ្វើការសាកល្បងអនុវត្តការធ្វើវិក្រឹតការនៅនឹងកន្លែងភ្ជាប់ នឹងការប្រជុំបច្ចេកទេស និងប្រព័ន្ធសន្សំក្រេឌីតដោយគាំទ្រការត្រួតពិនិត្យ និងវាយតម្លៃត្រឹមត្រូវ។ អភិវឌ្ឍកម្មវិធីសម្រាប់គ្រូឧទ្ទេសវគ្គវិក្រឹតការនៃស្តង់ដាគ្រឹះស្ថានបណ្តុះបណ្តាលគ្រូបង្រៀនក្នុងការចុះជួយបំប៉នសមត្ថភាពគ្រូបង្រៀន នៅនឹងកន្លែងដោយមានបញ្ជាក់ខ្លឹមសារកាលបរិច្ឆេទអ្នកចូលរួម។

រៀបចំគោលការណ៍ណែនាំស្តីពីតម្រូវការនិងផលប្រយោជន៍នៃការអភិវឌ្ឍវិជ្ជាជីវៈរបស់គ្រូបង្រៀន។ភ្ជាប់កម្មវិធីអភិវឌ្ឍវិជ្ជាជីវៈទៅនឹងរចនាសម្ព័ន្ធលាភការ ផលប្រយោជន៍របស់គ្រូបង្រៀន គឺភ្ជាប់ប្រព័ន្ធក្រេឌីតនៃការអភិវឌ្ឍវិជ្ជាជីវៈ ទៅនឹងផលប្រយោជន៍របស់គ្រូបង្រៀនដែលមានសមត្ថភាពពេញលេញដូជា: ប្តូរក្របខណ្ឌ កើនបៀវត្ស ដំឡើងថ្នាក់ ឋានន្តរសក្តិតាមសញ្ញាបត្រ។

# ជំពូកទី៣៖.វិធីសាស្ត្រស្រាវជ្រាវ

## ៣.១ វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវស្តីពី "**ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពបគ្គលិកអប់រំ នៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាល**" មានគោលបំណងសិក្សាស្វែងយល់ពីស្វែងយល់ពី កម្រិតសមត្ថភាពគ្រូបង្រៀនដែលកំពុងបម្រើការងារនៅក្នុងសាលាមធ្យមសិក្សាធនជាននៅក្នុងខេត្តកណ្តាល និងដើម្បីចូលរួមក្នុងការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនអោយកាន់តែប្រសើរ។ ការសិក្សាស្រាវជ្រាវនេះគឺអនុវត្តតាមបែបបរិមាណវិស័យ។

## ៣.២ គម្រោងវិភាគ

អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្រងសំណួរ សម្រាប់ការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យនៃប្រធានបទដែលលើកយកមកសិក្សា។ ស្របតាមផែនការនៃការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ និងកម្មវិធីសិក្សា ព្រមទាំងនិក្ខេបបទមានរយៈពេលកំណត់ច្បាស់លាស់ អ្នកសិក្សាស្រាវជ្រាវអាចបញ្ចប់ការសរសេរនិក្ខេបបទ និងឡើងការពារកិច្ចការស្រាវជ្រាវនៅថ្ងៃទី៦ ខែវិច្ឆិកា ឆ្នាំ២០២២ តាមផែនការគ្រោងទុក។ អ្នកសិក្សាស្រាវជ្រាវប្រើប្រាស់ការអនុវត្តក្នុងការចុះប្រមូលទិន្នន័យដោយប្រើប្រាស់វិធីសាស្ត្រតាមបែបបរិមាណវិស័យ។ ការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ គឺធ្វើនៅវិទ្យាល័យទាំងអស់ដែលជាសាលាធនជាន ដោយប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យពី គ្រូបង្រៀនដែលបាននឹងកំពុងបង្រៀនតាមមុខវិជ្ជា ។

**វិធីសាស្ត្របរិមាណវិស័យ** (Quantitative Research Design)៖ ប្រើប្រាស់កម្រងសំណួរក្នុងការប្រមូលទិន្នន័យពីគ្រូបង្រៀនដែលកំពុងបំពេញការងារបង្រៀននៅសាលាមធ្យមសិក្សាធនជាន ដោយមិនរាប់បញ្ចូលបុគ្គលិកដែលទទួលបន្ទុក បន្ទប់ពិសោធន៍ បណ្ណាល័យ បន្ទប់កុំព្យូទ័រ បន្ទប់សោតទស្សន៍ នោះទេ។ ការរៀបចំកម្រងសំណួរគឺចែកចេញជាបីផ្នែក៖ ១) ព័ត៌មានទូទៅ ២) សូចនាករសម្រាប់វាស់វែងកម្រិតសមត្ថភាពរបស់គ្រូបង្រៀន ៣) មតិយោបល់ដែលជាការយល់ឃើញរបស់គ្រូចំពោះសមត្ថភាពដែលខ្លួនកំពុងមានក្នុងការបំពេញតួនាទីរបស់គ្រូ។

តារាង៣.១៖ គម្រោងស្រាវជ្រាវរៀបរាប់ពីវិធីសាស្ត្រតាមបរិមាណវិស័យ៖

| គោលបំណង | ឧបករណ៍ស្រាវជ្រាវ | សំណាកគំរូ | ការវិភាគទិន្នន័យ |
| --- | --- | --- | --- |
| ១.សិក្សាពីស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន នៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាល។ | បរិមាណវិស័យ៖ ប្រើប្រាស់កម្រងសំណួរ (Questionnaires) | -គ្រូគ្រូបង្រៀនដែលកំពុងបំពេញការងារបង្រៀននៅសាលាមធ្យមសិក្សាធនជាន (n= ១៨០នាក់) | -កម្រិតចង្អុលបង្ហាញពីទាបបំផុត (១) ដល់ខ្ពស់បំផុត (៥)<br>-ភាគរយ (%) គម្លាតមធ្យម (Mean) គម្លាតស្តង់ដា (Standard Deviation) |
| ២.ស្វែងយល់ពីកម្រិតសមត្ថភាពខ្ពស់ ឬទាបរបស់គ្រូដែលកំពុងបង្រៀន នៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាល។ | បរិមាណវិស័យ៖ ប្រើប្រាស់កម្រងសំណួរ (Questionnaires) | -គ្រូបង្រៀនដែលកំពុងបំពេញការងារបង្រៀននៅសាលាមធ្យមសិក្សាធនជាន(n= ១៨០នាក់) | -កម្រិតចង្អុលបង្ហាញពីទាបបំផុត (១) ដល់ខ្ពស់បំផុត (៥)<br>- ភាគរយ (%) គម្លាតមធ្យម (Mean) គម្លាតស្តង់ដា (Standard Deviation) |

## ៣.៣ ការសិក្សាស្រាវជ្រាវតាមបរិមាណវិស័យ

### ៣.៣.១ ទំហំសំណាក និងការធ្វើសំណាក

ការប្រមូលទិន្នន័យតាមបែបបរិមាណវិស័យ គឺរៀបចំកម្រងសំណួរលើក្រដាស និងទៅតាមពេលវេលាដែលបានកំណត់ជាមួយសាលាគោលដៅនីមួយៗ។មួយវិញទៀត ចំនួនសំណាកមួយចំនួនគឺមិនទទួលបានទិន្នន័យត្រឡប់មកវិញទេ។ ការសិក្សាស្រាវជ្រាវនេះ បានទទួលទិន្នន័យពីសំណាកក្នុង

បរិមាណវិស័យសរុបចំនួន ១៨០នាក់ ពីគោលដៅដែលអ្នកសិក្សាស្រាវជ្រាវបានកំណត់គឺ គ្រូបង្រៀនក្នុងសាលាមធ្យមសិក្សាធនធានទាំងបី ក្នុងខេត្តកណ្ដាល។

**តារាង៣.២.១ ចំនួនសំណាកនៃការចុះប្រមូលទិន្នន័យ**

| ល.រ | ឈ្មោះវិទ្យាល័យធនធាន | ក្រុង/ស្រុក | ចំនួនសំណាក | |
|---|---|---|---|---|
| | | ៣ | ចំនួនគ្រូសរុប | ចំនួនសំណាកទទួលបានសរុប |
| ១ | វិ. ហ៊ុន សែន សេរីភាព | តាខ្មៅ | ២១២ | ៨៩ |
| ២ | វិ. ហ៊ុន សែន កោះធំ | កោះធំ | ៦៣ | ៣២ |
| ៣ | វិ. ទេពប្រណម្យ | ពញាឮ | ៨៧ | ៥៩ |
| សរុប | | | ៣៦២ | ១៨០ |

### ៣.៣.២. ឧបករណ៍សម្រាប់ការស្រាវជ្រាវ:

ទិន្នន័យជាបរិមាណវិស័យ គឺប្រើប្រាស់កម្រងសំណួរសម្រាប់ការប្រមូលទិន្នន័យទៅតាមក្រុមគោលដៅនៅកម្រិតសាលាមធ្យមសិក្សាធនធាន នៅក្នុងខេត្តកណ្ដាល តាមចំនួនសំណាកជាក់លាក់ដើម្បីយកមកធ្វើការវិភាគ។ កម្រងសំណួរត្រូវបានរៀបចំឡើង ទៅតាមដោយផ្អែកលើទ្រឹស្ដីពាក់ព័ន្ធនានា ដែលមានដូចជា៖ គោលនយោបាយសាលាមធ្យមសិក្សាធនធាន ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ឯកសារអប់រំប្រតិបត្តិស្តីពីការប្រើប្រាស់អគារធនធាន សៀវភៅណែនាំប្រតិបត្តិស្តីពីការគ្រប់គ្រងតាមសាលារៀន និង ឯកសារស្តីពីការលើកកម្ពស់សមត្ថភាពគ្រូបង្រៀន ដើម្បីសិក្សាអំពីកម្រិតសមត្ថភាពរបស់គ្រូបង្រៀនដែលកំពុងបម្រើការងារនៅក្នុងវិទ្យាល័យធនធានក្នុងខេត្តកណ្ដាល។

### ៣.៣.៣ កម្រិតចង្អុលបង្ហាញ

កម្រិតចង្អុលបង្ហាញ គឺការប្រើប្រាស់ក្នុងទម្រង់កម្រងសំណួរ ដើម្បីចុះប្រមូលទិន្នន័យពីភាគីពាក់ព័ន្ធទៅតាមការឆ្លើយតបក្នុងកម្រិតតួលេខជាក់លាក់។ កម្រិតចង្អុលបង្ហាញ បំពេញតាមរយៈ គូសដោយផ្ទាល់នៅលើកម្រងសំណួរលើប្រធានបទសិក្សាស្រាវជ្រាវ។ ក្នុងសិក្សាស្រាវជ្រាវលើប្រធានបទខាងលើ គឺមានកម្រិតចង្អុលបង្ហាញចំនួន ៥កម្រិត (Likert Scale)។ តួលេខចង្អុលបង្ហាញគឺប្រើដើម្បីវាស់វែងសូចនាករ វាយតម្លៃលើកម្រិតនៃសមត្ថភាពរបស់គ្រូបង្រៀនក្នុងសាលាមធ្យមសិក្សាធនធាន

កម្រិតចង្អុលបង្ហាញនៃកម្រងសំណួរនីមួយៗ មាន ៥កម្រិត ពីទាបបំផុត (១) ទៅខ្ពស់បំផុត (៥)៖

១ គឺ ខ្ញុំមិនយល់សោះ (I do not know)

២ គឺ ខ្ញុំយល់ដឹងខ្លះៗ (I know in low level)

៣ គឺ ខ្ញុំយល់ដឹងក្នុងកម្រិតមធ្យម (I know in middle level)

៤ គឺ ខ្ញុំយល់ដឹងក្នុងកម្រិតល្អ(I know in good level)

៥ គឺ ខ្ញុំយល់ដឹងក្នុងកម្រិតល្អប្រសើរ (I know in very good level)

ការបកស្រាយទៅលើការគណនាពិន្ទុ ពីការប្រមូលទិន្នន័យ ដើម្បីវិភាគលើមធ្យមភាគពិន្ទុនៃសូចនាករនីមួយៗ គឺមានរូបមន្តBest (1981) ដូចខាងក្រោម៖

$$\frac{\text{ពិន្ទុខ្ពស់បំផុត} - \text{ពិន្ទុទាបបំផុត}}{\text{លេខរៀងនៃកម្រិត}} = \frac{៥ - ១}{៥} = \frac{៤}{៥} = 0.៨0$$

| **មធ្យមពិន្ទុ** | | **កម្រិតចង្អុលបង្ហាញ** |
|---|---|---|
| ១.00— ១.៨0 | មានន័យថា | ខ្សោយណាស់ |
| ១.៨១— ២.៦0 | មានន័យថា | ខ្សោយ |
| ២.៦១ — ៣.៤0 | មានន័យថា | មធ្យម |

៣.៤១ – ៤.២០ មានន័យថា ល្អ

៤.២១ – ៥.00 មានន័យថា ល្អណាស់

### ៣.៣.៤ កម្រងសំណួរ

កម្រងសំណួររៀបចំឡើងដើម្បីឆ្លើយតបទៅនឹងគោលបំណងនៃការសិក្សាស្រាវជ្រាវ ដោយសំយោគចូលគ្នារវាងសូចនាករ សម្រាប់បង្កើតជាកម្រងសំណួរ។ កម្រងសំណួរត្រូវបានបែងចែកជា ២ផ្នែក ដែលបានដៅទៅសំណួរសម្រាប់គ្រូបង្រៀន ។ សម្រាប់ទិន្នន័យដែលប្រមូលបាននេះ គឺប្រើប្រាស់សម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។

**កម្រងសំណួរសម្រាប់គ្រូបង្រៀន**

កម្រងសំណួរសម្រាប់គ្រូបង្រៀន គឺប្រើប្រាស់សម្រាប់ការប្រមូលទិន្នន័យ ពីគ្រូបង្រៀនតាមមុខវិជ្ជានីមួយៗ មានដូចជា៖

**ផ្នែកទី១៖ ព័ត៌មានទូទៅ**

មាន ៧សំណួរ៖ ១) បង្ហាញថ្នាក់ទី និងមុខវិជ្ជា ២) ទីកន្លែងបម្រើការងារ ៣) ភេទ ៤) អាយុ ៥) កម្រិតវប្បធម៌ ៦) មុខវិជ្ជាឯកទេស និង ៧) បទពិសោធន៍ការងារ។

**ផ្នែកទី២៖ ចំណេះដឹង ជំនាញ និងវិធីសាស្ត្រ ដែលគ្រូមាន និងប្រើប្រាសក្នុងការបង្រៀន រៀនក្នុងបច្ចុប្បន្ននេះ។**

មានសមាសភាគចំនួន៣៖ គឺចំណេះដឹង(១១សំណួរ) ចំណេះដឹងគរុកោសល្យ (១១សំណួរ) ចំណេះដឹងលើខ្លឹមសាររៀន(១១សំណួរ) ជាឧបករណ៍សម្រាប់វាស់ពីកម្រិតសមត្ថភាពរបស់គ្រូបង្រៀននៅក្នុងសាលាមធ្យមសិក្សាធនធានទាំងអស់ក្នុងខេត្តកណ្តាល ។

### ៣.៣.៥ ការប្រមូលទិន្នន័យ

ក្រោយពីបានឆ្លងយោបល់ក្នុងក្របខណ្ឌបច្ចេកទេស ជាមួយគ្រូណែនាំគោល និងគ្រូណែនាំរងរួចមក អ្នកសិក្សាស្រាវជ្រាវបានរៀបចំកម្រងសំនួរ ដើម្បីចុះប្រមូលទិន្នន័យ។ ក្នុងពេលចុះប្រមូលទិន្នន័យ អ្នក

សិក្សាស្រាវជ្រាវ មានភាពសហការល្អអាជ្ញាធរដែនដី គណៈគ្រប់គ្រងសាលារៀន ដើម្បីបញ្ជូនលិងកម្រង សំណួរទៅតាមការជ្រើសរើសចំនួនសំណាកដែលបានគ្រោងទុក។

អ្នកសិក្សាស្រាវជ្រាវ បានចុះទៅជួបថ្នាក់ដឹកនាំការិយាល័យមធ្យមសិក្សាចំណេះទូទៅ នៃមន្ទីរអប់រំយុវជន និងកីឡាខេត្តកណ្តាល ដើម្បីជូនលិខិតឧទ្ទេសនាម និងសុំការអនុញ្ញាត ជួបក្រុមគោលដៅ ដើម្បីផ្តល់កម្រងសំណួរជូន គ្រូបង្រៀន ដោយមានកំណត់ពេលវេលាជាក់លាក់ ព្រមទាំងបានទំនាក់ទំនង នាយកសាលា តាមរយៈទូរស័ព្ទ និងផ្ញើលិខិតឧទ្ទេសនាមជូនតាមតេលេក្រាម ដើម្បីសុំការសម្របសម្រួល ជាមុន។

ជាលទ្ធផលនៃការប្រមូលទិន្នន័យសំណាកចំនួន ១៨០ ត្រូវបានប្រមូលយកមក ដើម្បីធ្វើការវិភាគ លើប្រធានបទ (តាមចំនួនកំណត់នៅក្នុងការសិក្សាស្រាវជ្រាវគឺចំនួន ១៨០)។

### ៣.៣.៦ ការវិភាគទិន្នន័យ

កម្រងសំណួរ ដែលប្រមូលបានពីក្រុមគោលដៅក្នុងការផ្តល់ទិន្នន័យ ត្រូវបានយកមករៀបចំ សម្រាប់ជាមូលដ្ឋានក្នុងការវិភាគទិន្នន័យបរិមាណវិស័យ។ ការវិភាគទិន្នន័យដោយផ្តោតទៅលើ៖ ១) ភាគរយ (%) ២) មធ្យមភាគពិន្ទុ (Mean) និង ៣) គម្លាតស្តង់ដា (Standard Deviation) ។ សំណួរស្រាវជ្រាវទី១ គឺវិភាគទៅលើកម្រងសំណួរ ដែលផ្តោតទៅលើសូចនាករគន្លឹះទាំង៣៣ និងសំណួរស្រាវជ្រាវទី២ គឺធ្វើការវិភាគដើម្បីធ្វើការឆ្លុះបញ្ចាំងតាមរយៈ វិភាគទៅលើកម្រងសំណួរ ដែលផ្តោតទៅលើសូចនាករគន្លឹះទាំង៣៣។ អ្នកសិក្សាស្រាវជ្រាវបានប្រើប្រាស់កម្រងសំណួរ ដែលមានលក្ខណៈជាពហុជ្រើសរើសទៅតាមកម្រិតចង្អុលបង្ហាញនីមួយៗ ក្នុងទម្រង់បិទ និងការផ្តល់មតិយោបល់សម្រាប់ស្វែងរកទិន្នន័យជាធាតុចូលបន្ថែម។ អ្នកសិក្សាស្រាវជ្រាវ បានប្រើប្រាស់កម្មវិធីវិភាគទិន្នន័យ SPSS, Microsoft Excel ដើម្បីសិក្សាពីភាគរយ មធ្យមភាគពិន្ទុ និងគម្លាតស្តង់ដា ដើម្បីវិភាគទៅលើសមត្ថភាពគ្រូបង្រៀន នៅក្នុងសាលាមធ្យមសិក្សាធនធាន នៅក្នុងខេត្តកណ្តាល។

## ៣.៤ ក្រមសីលធម៌នៃការស្រាវជ្រាវ

អ្នកសិក្សាស្រាវជ្រាវ បានប្រកាន់ខ្ជាប់នូវគោលការណ៍ និងក្រមសីលធម៌វិជ្ជាជីវៈក្នុងការចុះប្រមូលទិន្នន័យ នៅតាមក្រុមគោលដៅដែលបានកំណត់នៅក្នុងការស្រាវជ្រាវប្រធានបទ។ លិខិតឧទ្ទេសនាមសម្រាប់បំពេញបេសសកម្ម ត្រូវបានអនុញ្ញាតដោយវិទ្យាស្ថានជាតិអប់រំ និងបានប្រគល់ទៅតាមអង្គភាពពាក់ព័ន្ធ។ ការចុះប្រមូលទិន្នន័យលើកម្រងសំណួរ។ ទិន្នន័យដែលបានផ្តល់តាមបរិមាណវិស័យគឺសម្រាប់ប្រើប្រាស់ក្នុងគោលបំណងនៃការសិក្សាស្រាវជ្រាវលើប្រធានបទនោះតែប៉ុណ្ណោះ។ ការផ្តល់ទិន្នន័យពីក្រុមគោលដៅគឺក្នុងលក្ខខណ្ឌពេញចិត្ត មានការចូលរួមទាំងអស់គ្នាក្នុងការសហការគ្នា និងផ្តល់ព័ត៌មានដោយឈរលើភាពពិតប្រាកដ និងបទពិសោធន៍ជាក់ស្តែងទៅលើការងារអប់រំ។

# ជំពូកទី៤៖.លទ្ធផល និងការពិភាក្សា

ក្នុងជំពូកទី៤នេះ អ្នកស្រាវជ្រាវនឹងបង្ហាញពីលទ្ធផលនៃការវិភាគទិន្នន័យ ធ្វើការបកស្រាយ និងពិភាក្សា នូវអ្វីដែលត្រូវបានរកឃើញតាមរយៈការបំពេញកម្រងសំណួរអំពីក្រុមគោលដៅ ជាលោកគ្រូ អ្នកគ្រូដែលកំពុងពំពេញការងារជាប្រចាំ និងមិនស្ថិតក្នុងភាពទំនេរគ្មានប្រាក់បៀវត្ស។ រាល់ចំណុចសំខាន់ៗមួយចំនួនដែលទាក់ទងនឹងការបំពេញការងាររបស់គ្រូបង្រៀនក្នុងសាលាមធ្យមសិក្សាធនធាន ក្នុងខេត្តកណ្តាលនាពេលកន្លងមកត្រូវបានយកមកបកស្រាយ និងពិភាក្សា។

## ៤.១. ទិន្នន័យពីព័ត៌មានទូទៅរបស់គ្រូបង្រៀន

ក្នុងការសិក្សាស្រាវជ្រាវនេះ អ្នកស្រាវជ្រាវបានយកវិទ្យាល័យធនធាន ទាំងអស់ចំនួន៣សាលាក្នុងក្រុង/ស្រុក ចំនួន៣ ក្នុងខេត្តកណ្តាល ជាគោលដៅនៃការសិក្សាស្រាវជ្រាវ រួមមាន៖ ក្រុងតាខ្មៅចំនួន១គឺវិទ្យាល័យហ៊ុន សែនសេរីភាព ស្រុកកោះធំចំនួន១គឺ វិទ្យាល័យ ហ៊ុន សែន កោះធំ និងស្រុកពញាឮចំនួន១ គឺ វិទ្យាល័យទេពប្រណម្យ ដែលជាសាលាមធ្យមធនដែលនៅក្នុងខេត្តកណ្តាល។

### ៤.១.១ ព័ត៌មានទូទៅរបស់គ្រូបង្រៀន

តាមរយៈទិន្នន័យទទួលបានពីគ្រូបង្រៀនលើព័ត៌មានទូទៅ ក្នុងឧបសម្ព័ន្ធ«ក» បង្ហាញថាគ្រូបង្រៀនដែលបង្រៀននៅសាលាមធ្យមសិក្សាធនធានដូចមានបង្ហាញដូចខាងក្រោម៖

ក្រាប៤.១៖ ចំនួនសំណាក ភេទ






តាមរយៈក្រាប៤.១ បង្ហាញថាវិទ្យាល័យ ហ៊ុន សែន សេរីភាព ទទួលបានចំនួន៨៩នាក់ ស្មើនឹង ៤៩.៤% វិទ្យាល័យទេពប្រណម្យ ទទួលបានចំនួន៥៩នាក់ ស្មើនឹង៣២.៨% វិទ្យាល័យ ហ៊ុន សែន កោះធំ ទទួលបានចំនួន ៣២នាក់ ស្មើនឹង ១៧.៨% នៃចំនួនសរុប១៨០នាក់ដែលក្នុងនោះលោកគ្រូមានចំនួន៨៨ ស្មើ៤៨.៩% និងអ្នកគ្រូមានចំនួន៩២ ស្មើ៥១.១% ។

ក្រាប៤.២៖ បង្ហាញពីកម្រិតវប្បធម៌របស់អ្នកចូលរួម



តាមរយៈក្រាប៤.២ បង្ហាញកម្រិតវប្បធម៌ចំពោះកម្រិតវប្បធម៌មានភាគច្រើនមានសញ្ញាបត្របរិញ្ញាបត្រមានចំនួន១៣៦នាក់ ស្មើ៧៥.៥% សញ្ញាបត្របរិញ្ញាបត្រជាន់ខ្ពស់មានចំនួន១៩នាក់ ស្មើ១០.៥% ក្រៅពីនេះគឺជាគ្រូបង្រៀនដែលមានសញ្ញាបត្រចប់ត្រឹមថ្នាក់ទី១២និងផ្សេងៗ(ដែលគ្រូខ្លះមានកម្រិតត្រឹម៧+៣ ឬ៩+៣....)

ក្រាប៤.៣៖ បង្ហាញពីបទពិសោធន៍ការងាររបស់អ្នកចូលរួម




តាមរយៈក្រាប៤.៣ បានបង្ហាញថាអ្នកចូលរួមជាគ្រូបង្រៀនមានបទពិសោធន៍ច្រើនដែលជាចំនុចមួយល្អព្រោះគ្រូដែលបានចូលរួមមានបទពិសើធន៍លើសពី១៥ឆ្នាំ មានចំនួន៨៤នាក់ ស្មើ៤៦.៧% នៃចំនួនសរុប ១៨០នាក់ ហើយភាគតិចគឺ ចន្លោះពី១ ដល់ ៥ឆ្នាំ មានចំនួន១២នាក់ ស្មើ៦.៧% ក្រៅពីនេះមានបទពិសោធន៍ចន្លោះពី ៦ ដល់ ១០ឆ្នាំ មានចំនួន២៥នាក់ ស្មើ ១៣.៩% និងចន្លោះពី ១១ ដល់ ១៥ឆ្នាំ មានចំនួន៥៩នាក់ ស្មើ៣២.៨% នៃចំនួនសរុប១៨០នាក់។

ក្រាប៤.៤៖ បង្ហាញពីកម្រិតក្របខណ្ឌនិងមុខវិទ្យាបង្រៀន







តាមរយៈក្រាប៤.៤ បង្ហាញថាអ្នកចូលរួមក្នុងការប្រមូទិន្ន័យទទួលបានគ្រូដែលមានក្របខណ្ឌគ្រូបង្រៀននៅកម្រិតឧត្តមដែលមានចំនួន ៩៨នាក់ ស្មើ៥៤.៥% ហើយក្រៅពីនោះជាគ្រូបង្រៀននៅកម្រិតមូលដ្ឋានមានចំនួន៨២នាក់ ស្មើនិង៤៥.៥% នៃចំនួនសរុប ៨៦នាក់ ហើយចំនួនគ្រូបង្រៀនមុខវិជ្ជាភាសាខ្មែរមានចំនួន៤០នាក់ស្មើ២២.២% សិលធម៌ ពលរដ្ឋ ១៧នាក់ ស្មើ៩.៤% ភូមិវិទ្យា មានចំនួន១៤នាក់ ស្មើ៧.៨% ប្រវត្តិវិទ្យា មានចំនួន១១នាក់ ស្មើ៦.១% គណិតវិទ្យាមានចំនួន៣១នាក់ ស្មើ១៧.២%

រូបវិទ្យា ១៥នាក់ ស្មើ៨.៣% គីមីវិទ្យា មានចំនួន៧នាក់ ស្មើ៣.៩% ជីវវិទ្យា មានចំនួន១៥នាក់ ផែនដីវិទ្យា មានចំនួន៦នាក់ ស្មើ៣.% ជីវភាសា មានចំនួន១៧នាក់ ៣.៩% ព័ត៌មានវិទ្យាមានចំនួន២នាក់ ស្មើ១.១% និងមុខវិទ្យាផ្សេងទៀត(ដែលក្នុងនោះរួមមាន គេហៈ សិល្បៈ កីឡា និងសេដ្ឋកិច្ច) មានចំនួន ៩នាក់ ស្មើ ៥% នៃចំនួនសរុប ១៨០នាក់។

ក្រាប៤.៥៖ បង្ហាញអំពីកម្រិតថ្នាក់ដែលសំណាកចូលរួម




តាមក្រាប៤.៥ បង្ហាញអំពីកម្រិតថ្នាក់ដែលក្នុងនេះលោកគ្រូ អ្នកគ្រូដែលបានចូលរួមដែលបានជាសំណាកមានគ្រូដែលបង្រៀនទី៧ មាន២៥នាក់ដែលស្មើនឹង១៣.៩% គ្រូទី៨ មាន៣១នាក់ដែលស្មើនឹង១៧.២% គ្រូទី៩ មាន២៦នាក់ ដែលស្មើនឹង១៤.៤% គ្រូទី១០ មាន៣៨នាក់ ដែលស្មើនឹង ២១.១% គ្រូទី១១ មាន៣៦នាក់ ដែលស្មើនឹង២០% គ្រូទី១២ មាន២៤នាក់ ដែលស្មើនឹង ១៣.៣% នៃចំនួន១៨០នាក់ដែល១០០%។

ក្រាប៤.៦៖ បង្ហាញពីកម្រិតអាយុរបស់អ្នកចូលរួម




តាមរយៈក្រាប៤.៦ ក្នុងនោះដែរ បង្ហាញថាគ្រូដែលជាអ្នកបានចូលរួមភាគច្រើនមានអាយុលើសពី ៣៥ឆ្នាំ មានចំនួន ១០៨នាក់ស្មើ ៦០% និងភាគតិចមានអាយុចន្លោះពី ២០ ដល់ ២៥ឆ្នាំ មានចំនួន ៦នាក់ ស្មើនិង ៣.៣% ក្រៅពីនេះគឺមានអាយុចន្លោះពី ២៦ ដល់ ៣៥ឆ្នាំ មានចំនួន៦៦នាក់ស្មើ ៣៦.៧% នៃចំនួនសរុប ១៨០នាក់។

## ៤.២ លទ្ធផលនៃការសិក្សាស្រាវជ្រាវ

### ៤.២.១ ទិន្នន័យពីការឆ្លើយតបរបស់គ្រូបង្រៀន

ក្រោយពីទទួលបានទិន្នន័យរួចមក អ្នកស្រាវជ្រាវបានធ្វើការបញ្ចូលទិន្នន័យ និងវិភាគរកមធ្យមពិន្ទុក និងគម្លាតស្តង់ដា ដើម្បីឈានរកកម្រិចង្អុលបង្ហាញដូចខាងក្រោម៖

តារាង៤.១៖ ចំណេះដឹងផ្នែកបច្ចេកវិទ្យា

| ល.រ | បរិយាយ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ក. ចំណេះដឹងផ្នែកបច្ចេកវិទ្យា | | | | |
| ១ | អាចដោះស្រាយបញ្ហាបច្ចេកទេសកុំព្យូទ័របានដោយខ្លួនឯង | 2.33 | 1.15 | ទាប |
| ២ | យល់ដឹងពីមូលដ្ឋាននៃផ្នែករឹង និងផ្នែកទន់របស់កុំព្យូទ័រ | 2.29 | 1.10 | ទាប |
| ៣ | ការបង្រៀនដោយបញ្ចូលបច្ចេកវិទ្យា គឺមានភាពងាយស្រួល | 2.86 | 1.10 | មធ្យម |
| ៤ | បានតាមដានជាប្រចាំនូវការវិវត្តន៍នៃបច្ចេកវិទ្យា | 2.64 | 1.01 | មធ្យម |
| ៥ | អាចប្រើប្រាស់កម្មវិធីរដ្ឋបាលថ្នាក់រៀន( Word, Excel, Power Point) | 2.97 | 1.19 | មធ្យម |
| ៦ | អាចប្រើអ៊ីនធឺណិតក្នុងទំនាក់ទំនងការងារប្រចាំថ្ងៃ | 3.34 | 1.09 | ល្អ |
| ៧ | ចូលចិត្តប្រើប្រាស់បណ្តាញសង្គមក្នុងការរស់នៅ និងទំនាក់ទំនង (Facebook, Telegram) | 3.35 | 1.08 | ល្អ |
| ៨ | អាចប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីរក្សាទុកទិន្នន័យ (Cloud, Flash Drive) | 2.80 | 1.21 | មធ្យម |
| ៩ | អាចប្រើប្រាស់ម៉ាស៊ីនបោះពុម្ព និងស្កេន | 2.49 | 1.29 | ទាប |
| ១០ | អាចប្រើប្រាស់ម៉ាស៊ីនបញ្ចាំងស្លាយក្នុងដំណើរការបង្រៀន | 2.47 | 1.29 | ទាប |
| ១១ | អាចប្រើកាមេរ៉ាឌីជីថល Digital Camera | 2.62 | 1.16 | មធ្យម |
| សរុប | | 2.74 | 1.15 | មធ្យម |

តាមតារាង៤.១ បានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ចំណេះដឹងផ្នែកបច្ចេកវិទ្យា** ក្នុងកម្រិត មធ្យម (មធ្យមភាគពិន្ទុ = ២.៧៤)។ ហើយសូចនាករទទួលបានពិន្ទុកខ្ពស់ជាងគេ

គឺ«ចូលចិត្តប្រើប្រាស់បណ្តាញសង្គមក្នុងការរស់នៅ និងទំនាក់ទំនង (Facebook, Telegram)» ក្នុងកម្រិត ល្អ (មធ្យមភាគពិន្ទុ = ៣.៣៥)។ សូចនាករទទួលបានពិន្ទុកទាបជាងគេគឺ«យល់ដឹងពីមូលដ្ឋាននៃផ្នែករឹង និងផ្នែកទន់របស់កុំព្យូទ័រ» ក្នុងកម្រិត ទាប (មធ្យមភាគពិន្ទុ =២.២៩)។

**តារាង៤.២៖ ចំណេះដឹងផ្នែកគរុកោសល្យ**

| ល.រ | បរិយាយ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហា ៣ |
|---|---|---|---|---|
| **ខ. ចំណេះដឹងផ្នែកគរុកោសល្យ** | | | | |
| ១ | ពីរបៀបវាយតម្លៃលើលទ្ធផលរបស់សិស្សក្នុងថ្នាក់រៀន | 3.48 | 0.86 | ល្អ |
| ២ | វាយតម្លៃការសិក្សារបស់សិស្សតាមវិធីជាច្រើន | 3.49 | 0.86 | ល្អ |
| ៣ | កែសម្រួលការបង្រៀនរបស់ខ្ញុំដោយផ្អែកលើអ្វីដែលសិស្សយល់ឬមិនយល់ | 3.57 | 0.87 | ល្អ |
| ៤ | ការប្រើប្រាស់វិធីសាស្ត្រនិងបច្ចេកទេសវាយតម្លៃផ្សេងៗគ្នាក្នុងការបង្រៀន | 3.49 | 0.84 | ល្អ |
| ៥ | ការអនុវត្តទ្រឹស្តី និងវិធីសាស្ត្រសិក្សាផ្សេងៗគ្នាក្នុងការរៀន និងបង្រៀន | 3.63 | 0.83 | ល្អ |
| ៦ | ប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា ចំពោះសិស្សផ្សេងៗគ្នា ក្នុងការបង្រៀន និងរៀន | 3.59 | 0.83 | ល្អ |
| ៧ | អាចស្វែងយល់ពីតម្រូវការសិក្សារបស់សិស្ស | 3.56 | 0.76 | ល្អ |

| ល.រ | បរិយាយ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហា៣ |
|---|---|---|---|---|
| ៨ | អាចយល់ពីឥរិយាបទក្នុងការស្តែងឡើងរបស់សិស្សក្នុងការសិក្សា | 3.73 | 0.77 | ល្អ |
| ៩ | អាចរៀបរាប់បានពីរបៀបសិក្សាផ្សេងៗគ្នា និងដាច់ដោយឡែករបស់សិស្ស | 3.52 | 0.80 | ល្អ |
| ១០ | អាចពន្យល់ពីភាពខុសគ្នានៃសម្បទាសិក្សារបស់សិស្ស | 3.39 | 0.85 | ល្អ |
| ១១ | អាចពន្យល់បានពីភាពខុសគ្នា នៃល្បឿនសិក្សារបស់សិស្ស | 3.54 | 0.84 | ល្អ |
| សរុប | | 3.54 | 0.83 | ល្អ |

តាមតារាង៤.២ បានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ចំណេះដឹងផ្នែកគរុកោសល្យ** ក្នុងកម្រិត ល្អ (មធ្យមភាគពិន្ទុ = ៣.៥៤)។ ហើយសូចនាករទទួលបានពិន្ទុកខ្ពស់ជាងគេគឺ« អាចយល់ពីឥរិយាបទក្នុងការស្តែងឡើងរបស់សិស្សក្នុងការសិក្សា» ក្នុងកម្រិត ល្អ (មានមធ្យមពិន្ទុ= ៣.៧៣)។ សូចនាករទទួលបានពិន្ទុកទាបជាងគេគឺ«អាចពន្យល់ពីភាពខុសគ្នានៃសម្បទាសិក្សារបស់សិស្ស» ក្នុងកម្រិត ល្អ (មធ្យមភាគពិន្ទុ =៣.៣៩)។

តារាង៤.៣៖ ចំណេះដឹងផ្នែកខ្លឹមសារមេរៀន

| ល.រ | បរិយាយ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| គ.ចំណេះដឹងផ្នែកខ្លឹមសារមេរៀន | | | | |
| ១ | ពណ៌នាបានពីគោលនយោបាយអប់រំជាតិ និងគោលដៅអប់រំជាតិនានា.. | 3.13 | 0.88 | មធ្យម |
| ២ | ពណ៌នាបានពីវិធីដែលធ្វើអោយសម្រេចបាននូវគោលនយោបាយអប់រំជាតិ និងគោលដៅជាតិនានា.. | 2.97 | 0.93 | មធ្យម |
| ៣ | យល់ពីខ្លឹមសារ វត្ថុបំណង ពាក្យគន្លឹះក្នុងមេរៀន | 3.77 | 0.79 | ល្អ |
| ៤ | ពណ៌នាពីវត្ថុបំណង និងរៀបចំសកម្មភាពបានត្រឹមត្រូវ | 3.76 | 0.78 | ល្អ |
| ៥ | ពណ៌នាបានពី សម្ភារបង្រៀន និងរៀនសមស្រប សម្រាប់ប្រើប្រាស់ | 3.68 | 0.85 | ល្អ |
| ៦ | អភិវឌ្ឍសកម្មភាពថ្នាក់រៀន និងគម្រោងក្នុងការបង្រៀន | 3.61 | 0.83 | ល្អ |
| ៧ | តាមដានពីការវិវឌ្ឍន៍ និងកម្មវិធីថ្មីៗនៅក្នុងមុខវិជ្ជារបស់ខ្ញុំ | 3.74 | 0.85 | ល្អ |
| ៨ | គូសបញ្ជាក់ពីខ្លឹមសារ និងកម្មវិធីបានច្បាស់លាស់ | 3.66 | 0.86 | ល្អ |
| ៩ | ការបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងទៀត | 3.57 | 0.85 | ល្អ |
| ១០ | ការតាមដានធនធានថ្មី ៗ (ឧ.សៀវភៅ, ទិនានុប្បវត្តិ...) | 3.25 | 0.94 | មធ្យម |
| ១១ | តាមដាននូវសន្និសីទ និងសកម្មភាពពាក់ព័ន្ធខ្លឹមសារមេរៀនរបស់ខ្ញុំ | 3.30 | 1.00 | មធ្យម |
| សរុប | | 3.49 | 0.87 | ល្អ |

តាមតារាង៤.៣ បានបង្ហាញថា គ្រូបង្រៀនបានផ្តល់ទិន្នន័យជាសរុប ពីកម្រិត **ចំណេះដឹងផ្នែកខ្លឹមសារមេរៀន** ក្នុងកម្រិត ល្អ (មធ្យមភាគពិន្ទុ = ៣.៤៩)។ ហើយសូចនាករទទួលបានពិន្ទុកខ្ពស់ជាងគេគឺ« យល់ពីខ្លឹមសារ វត្ថុបំណង ពាក្យគន្លឹះក្នុងមេរៀន» ក្នុងកម្រិត ល្អ (មធ្យមភាគពិន្ទុ = ៣.៧៧)។ សូចនាករទទួលបានពិន្ទុកទាបជាងគេគឺ«ពណ៌នាបានពីវិធីដែលធ្វើអោយសម្រេចបាននូវគោលនយោបាយអប់រំជាតិ និងគោលដៅជាតិនានា..» ក្នុងកម្រិត មធ្យម (មធ្យមភាគពិន្ទុ =២.៩៧)។

## ៤.៣ ការពិភាក្សា

តាមរយៈលទ្ធផលដែលទទួលបានខាងលើនេះ អ្នកសិក្សាបានធ្វើការបូកសរុបដើម្បីធ្វើការពិភាក្សា និងទាញលទ្ធផលក្នុងការសិក្សាស្រាវជ្រាវទៅលើប្រធានបទមួយនេះ។

### ១. ការអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន នៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាល៖

**តារាង៤.៤៖ សរុបពីកម្រិតយល់ដឹងរបស់គ្រូបង្រៀន**

| ល.រ | បរិយាយ | មធ្យមភាគពិន្ទុ | គម្លាតស្តង់ដា | កម្រិតចង្អុលបង្ហាញ |
|---|---|---|---|---|
| ១ | **ចំណេះដឹងផ្នែកបច្ចេកវិទ្យា** | 2.74 | 1.15 | មធ្យម |
| ២ | **ចំណេះដឹងផ្នែកគរុកោសល្យ** | 3.54 | 0.83 | ល្អ |
| ៣ | **ចំណេះដឹងផ្នែកខ្លឹមសារមេរៀន** | 3.49 | 0.87 | ល្អ |
| សរុប | | 3.25 | 0.95 | មធ្យម |

តាមរយៈការសិក្សាស្រាវជ្រាវដូចដែលបានបង្ហាញនៅក្នុងតារាង៤.៤ បានបង្ហាញថាសមាសភាពទាំងបីដែលក្នុងនោះមានចំណេះដឹងផ្នែកបច្ចេកវិទ្យា ចំណេះដឹងផ្នែកគរុកោសល្យ និងចំណេះដឹងផ្នែកខ្លឹមសារមេរៀន ជារួម (ដែលមានមធ្យមពិន្ទុ=៣.២៥ និងគម្លាតស្តង់ដា=០.៩៥) ដែលក្នុងនោះផងដែរ ឃើញថាអ្នកចូលរួមគាត់មានសមត្ថភាពខ្ពស់ទៅលើជំនាញ ចំណេះដឹងផ្នែកគរុកោសល្យ(ដែលមធ្យមភាគពិន្ទុ

៣.៥៤ និងគម្លាតស្តង់ដា ០.៨៣) និងចំណេះដឹងផ្នែកខ្លឹមសារមេរៀន (ដែលមធ្យមភាគពិន្ទុ ៣.៤៩ និងគម្លាតស្តង់ដា ០.៨៧) គឺស្ថិតក្នុងកម្រិត«ល្អ» ស្របពេលនេះដែរ អ្នកសិក្សាក៏បានរកឃើញថា អ្នកចូលរួមមានកម្រិតចំណេះដឹង និងជំនាញទាប លើចំណេះដឹងផ្នែកបច្ចេកវិទ្យា ដែលមានក្នុងតារាង ៤.២.១ ខាងលើស្រាប់ ដែលក្នុងនោះរួមមាន ចំណេះដឹងក្នុងការដោះស្រាយបញ្ហាបច្ចេកទេសកុំព្យូទ័របានដោយខ្លួនឯង (ដែលមធ្យមភាគពិន្ទុ ២.៣៣ និងគម្លាតស្តង់ដា ១.១៥)អាចប្រើប្រាស់ម៉ាស៊ីនបោះពុម្ព និងស្កេន (ដែលមធ្យមភាគពិន្ទុ ២.៤៩ និងគម្លាតស្តង់ដា ១.២៩) អាចប្រើប្រាស់ម៉ាស៊ីនបញ្ចាំងស្លាយក្នុងដំណើរការបង្រៀន (ដែលមធ្យមភាគពិន្ទុ ២.៤៧ និងគម្លាតស្តង់ដា ១.២៩)និងសូចនាករដែលនៅទាបជាងគេគឺយល់ដឹងពីមូលដ្ឋាននៃផ្នែករឹង និងផ្នែកទន់របស់កុំព្យូទ័រ (ដែលមធ្យមភាគពិន្ទុ ២.២៩ និងគម្លាតស្តង់ដា ១.១០)។

តាមគន្លងវិជ្ជាជីវៈគ្រូបង្រៀន ក្នុងសតវត្សទី២១ គឺគ្រូបង្រៀនត្រូវមានចំណេះដឹងផ្នែកបច្ចេកវិទ្យាក្នុងការបង្រៀន និងរៀនគឺ ដើម្បីសំដៅជំរុញ អោយគុណភាពនៃការសិក្សាទទួលបានប្រសិទ្ធភាពខ្ពស់។ ក្នុងន័យនេះគ្រូបង្រៀនត្រូវការជាចាំបាច់នូវក្នុងការបំប៉ងសមត្ថភាពរបស់ខ្លួន ដើម្បីឆ្លើយតបទៅនឹងតម្រូវការសាលារៀន របស់សិស្សានុសិស្ស។ តាមលទ្ធផលទៅលើសូចនាករដែលទទួលបាន ដើម្បីបំពេញបន្ថែមនូវចំនុចខ្វះខាតទៅលើចំណេះដឹងផ្នែកបច្ចេកវិទ្យា គ្រូត្រូវធ្វើការអភិវឌ្ឍទៅលើមូលដ្ឋានគ្រឹះរបស់កុំព្យូទ័រមុនគេបង្អស់(សូចនាករដែលមានពិន្ទុទាបជាងគេ = ២.៧៤) ដើម្បីឈានដល់ការ ប្រើប្រាសមុខងារផ្សេងៗរបស់បច្ចេកវិទ្យានាសតវត្សទី២១ ក្នុងវិជ្ជាជីវៈរបស់ខ្លួនដើម្បីដំណើរការនៃការបង្រៀន និងរៀនប្រកបដោយប្រសិទ្ធិភាព។ដើម្បីស្របគ្នា នឹងក្រសួងបានជំរុញការប្រើប្រាស់កុំព្យូទ័រ ដើម្បីរក្សាទិន្នន័យដែលក្រសួងត្រូវការជាចាំបាច់ក្នុងការគ្រប់គ្រងកិច្ចប្រតិបត្តិការរបស់ខ្លួន។ ផ្នែកសំខាន់មួយចំនួនរបស់ក្រសួងត្រូវបានគ្រប់គ្រងដោយប្រព័ន្ធកុំព្យូទ័រ មានប្រព័ន្ធព័ត៌មានគ្រប់គ្រងអប់រំ(EMIS) ប្រព័ន្ធព័ត៌មានគ្រប់គ្រងបុគ្គលិក(HRMIS) ប្រព័ន្ធព័ត៌មានគ្រប់គ្រងការអប់រំក្រៅប្រព័ន្ធ (NFEMIS) ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ (FMIS) និងប្រព័ន្ធគ្រប់គ្រងឧត្តមសិក្សា(HEMIS)។ ប្រព័ន្ធគ្រប់គ្រងទាំងនេះ មានភាពឯករាជ្យពីគ្នា និងស្ថិតនៅក្រោមការគ្រប់គ្រងរបស់នាយកដ្ឋានជំនាញនីមួយៗ។ ដើម្បីដោះស្រាយបញ្ហា

ប្រឈមសម្រាប់ការធ្វើសមាហរណកម្ម(ICT) ក្នុងការបណ្តុះបណ្តាលគ្រូបង្រៀននៅក្នុងក្រសួងអប់រំ យុវជន និងកីឡា ហើយនិងអង្គការ VVOB សមាគមន៍ Flemish ដើម្បីកិច្ចសហប្រតិបត្តិការ ការអភិវឌ្ឍ និងជំនួយបច្ចេកទេស បានធ្វើការពង្រឹងសមត្ថភាព(ICT) របស់គ្រូតាមរយៈការប្រើប្រាស់សម្ភារៈសិក្សាឌីជីថល និងកាបណ្តុះបណ្តាលដើម្បីពង្រឹងគុណភាពពង្រីកឧបករណ៍ និងការកសាងសមត្ថភាពស្ថាប័ន (Dionys, 2011)។

មួយវិញទៀត តាមរយៈចំណេះដឹងមូលដ្ឋានគ្រឹះនៃកុំព្យូទ័រផងដែរ វាក៏បានជួយអោយគ្រូបង្រៀនអាចប្រើប្រាស់បច្ចេកវិទ្យា ដែលជាជំនួយដល់គ្រូក្នុងការដក់ស្រង់នូវខ្លឹមសារមេរៀន សំណួរតេស្ត និងវីដេអូសិក្សា មកផ្សាភ្ជាប់មុខវិជ្ជាជីវៈដែលខ្លួនកំពុងបង្រៀន ទៅនឹងតថភាពជាក់ស្តែងនៃសង្គមសព្វថ្ងៃនេះ។ម្យ៉ាងវិញទៀតតាមរយៈចំណេះដឹងមូលដ្ឋានគ្រឹះនៃកុំព្យូទ័រះជំរុញ និងផ្តល់ភាពងាយស្រួលដល់គ្រូ ឬអ្នកសិក្សាអាចស្វែងរក ចែករំលែកនូវធនធានសំបូរបែបក្នុងការសិក្សាស្រាវជ្រាវលើវិធីសាស្រ្ត អត្ថបទមេរៀន ការភ្ជាប់បណ្តាញវិជ្ជាជីវៈ តាមរយៈទំនាក់ទំនងដោយប្រើប្រាសបណ្តាញសង្គម ក្រុមតេឡេក្រាម ដែលអាចអោយគ្រូបង្រៀនគ្រប់រូបមានភាពងាយស្រួលក្នុងការចែករំលែក នូវបទពិសោធន៍ ចំណេះដឹង និងជំនាញផ្សេងៗកាន់តែមានភាពងាយស្រួល ជាពិសេសអាជួយដោះស្រាយមួយចំនួនដែលគ្រូកំពុងជួបប្រទះ និងស្វែងរកដំណោះស្រាយ។

ដូចនេះអ្នកសិក្សាអាចសន្និដ្ឋានបានថា ករអភិវឌ្ឍសមត្ថភាពគ្រូបង្រៀន នៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាលមានកម្រិត «មធ្យម» ទៅលើក្របខណ្ឌសមត្ថភាពគ្រូបង្រៀនឌីជីថល។

**២. គ្រូនៅសាលាមធ្យមសិក្សាធនជានក្នុងខេត្តកណ្តាលមានកម្រិតសមត្ថភាពខ្ពស់ ឬខ្សោយលើផ្នែកៈ**

តាមរយៈការសិក្សាស្រាវជ្រាវដូចដែលបានបង្ហាញនៅក្នុងតារាង៤.៤ បានបង្ហាញថាសមាសភាពទាំងបីដែលក្នុងនោះមានចំណេះដឹងផ្នែកបច្ចេកវិទ្យា ចំណេះដឹងផ្នែកគរុកោសល្យ និងចំណេះដឹងផ្នែកខ្លឹមសារមេរៀន ជារួម (ដែលមានមធ្យមពិន្ទុ=៣.២៥ និងគម្លាតស្តង់ដា=០.៩៥) ដែលក្នុងនោះផងដែរ ឃើញថាអ្នកចូលរួមគាត់មានសមត្ថភាពខ្ពស់ទៅលើជំនាញ ចំណេះដឹងផ្នែកគរុកោសល្យ(ដែលមធ្យមភាគពិន្ទុ ៣.៥៤ និងគម្លាតស្តង់ដា ០.៨៣) និងចំណេះដឹងផ្នែកខ្លឹមសារមេរៀន (ដែលមធ្យមភាគពិន្ទុ ៣.៤៩ និង

គម្លាតស្តង់ដា ០.៨៧) គឺស្ថិតក្នុងកម្រិត«ល្អ» ស្របពេលនេះដែរ អ្នកសិក្សាក៏បានរកឃើញថា អ្នកចូលរួមមានកម្រិតចំណេះដឹង និងជំនាញទាប លើចំណេះដឹងផ្នែកបច្ចេកវិទ្យា។

នៅក្នុងការបកស្រាយនៃចំណុចខាងលើ ដែលស្តីពីកម្រិតជំនាញ ICT របស់អ្នកចូលរួមដែលជាគ្រូបង្រៀននៅកម្រិតមធ្យមសិក្សាចំណេះទូទៅ នៅសាលាមធ្យមសិក្សាធនជាន បានបង្ហាញឲ្យអ្នកស្រាវជ្រាវស្វែងយល់បានកាន់តែទូលំទូលាយអំពីស្ថានភាពនៃការប្រើប្រាស់ បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ តាមសាលារៀនកម្រិតមូលដ្ឋាន ដែលស្ថិតនៅក្នុងខេត្តកណ្តាល។ ដូចគ្នាទៅនឹង (Richardson, 2008) ដែលបានលើកឡើងថាចំណេះដឹងបច្ចេកវិទ្យា និងប្រព័ន្ធ(ICT) នៅប្រទេសកម្ពុជានៅមានកម្រិតទាបនៅឡើយបើធៀបជាមួយនឹងបណ្តាប្រទេសជិតខាងដោយសារប្រទេសកម្ពុជាមានបញ្ហាប្រឈមមួយចំនួន។ ម្យ៉ាងវិញទៀតតាមរយៈគោលនយោបាយ យុទ្ធសាស្ត្របច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ក្នុងវិស័យអប់រំនៅកម្ពុជាបានបង្ហាញពីដំណាក់កាលមួយនៃការងារសំខាន់របស់ក្រសួងអប់រំយុវជន និងកីឡាក្នុងការធ្វើកំណែទម្រង់សេវាអប់រំនៅកម្ពុជាឱ្យមានប្រសិទ្ធភាពខ្ពស់។ នៅក្នុងគោលនយោបាយ និងយុទ្ធសាស្ត្រនោះ ក្រសួងបានចែកផែនទីសំខាន់ៗដូចជា បង្កលក្ខណៈឲ្យគ្រូ និងសិស្សគ្រប់រូបទាំងអស់ ជាពិសេសក្នុងមធ្យមសិក្សា ចេះប្រើប្រាស់ និងចូលរួមកាត់បន្ថយគម្លាតពីបច្ចេកវិទ្យា ទៅនឹងការប្រើប្រាស់ បច្ចេកវិទ្យា ក្នុងតួនាទីបង្រៀន និងរៀនតាមមុខវិជ្ជាផ្សេងៗ និងការប្រាស្រ័យទាក់ទងតាមសារអេឡិចត្រូនិច ប្រើប្រាស់បច្ចេកវិទ្យា ក្នុងការស្វ័យសិក្សា និងការសិក្សាពីចម្ងាយ ហើយរួមទាំងការធ្វើតេស្តផ្សេងៗ។ ទន្ទឹមនឹងនេះ បើប្រើប្រៀបធៀបទៅនឹងគោលនយោបាយ និងយុទ្ធសាស្ត្រ ដែលបានចេញក្នុងឆ្នាំ២០១៨ របស់ក្រសួងអប់រំ និងយោងតាមលទ្ធផលនៃការស្រាវជ្រាវខាងលើនេះការប្រើប្រាស់បច្ចេកវិទ្យារបស់គ្រូបង្រៀននៅក្នុងសាលាមធ្យមសិក្សាធនជាននៅ មិនទាន់ឆ្លើយតបទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រក្នុងវិស័យអប់រំ ក៏ដូចជារាជរដ្ឋាភិបាលនៅឡើយទេ ព្រោះនៅក្នុងចំណោមចំណេះដឹងបច្ចេកវិទ្យា ចំនួន១១ជំនាញគឺអ្នកចូលរួមខ្សោយចំណេះដឹងបច្ចេកវិទ្យា ៨ជំនាញដែលមានមធ្យមភាគទាបជាង៣.០០ចំណុចទាំងនេះក៏អាចបញ្ជាក់បានថាកម្រិតជំនាញរបស់គ្រូធៀបទៅនឹងគោលនយោបាយ និងផែនការយុទ្ធសាស្ត្រនានា គឺនៅមានគម្លាតគ្នានៅឡើយ។ លើសពីនេះទៅទៀតក្រសួងក៏បានដាក់ចេញ

នូវគោលការណ៍ និងគោលនយោបាយជាច្រើនដូចជា ធានាឲ្យសិស្សកម្ពុជាគ្រប់រូប ដែលបញ្ចប់ការអប់រំក្នុងប្រព័ន្ធអាចប្រើប្រាស់ចំណេះដឹង និងបំណិនបច្ចេកវិទ្យា ដើម្បីបង្កើនប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិនៃការបង្រៀន និងរៀនដោយប្រើប្រាស់ឧបករណ៍បច្ចេកវិទ្យា និងធនធានអេឡិចត្រូនិច ប្រើប្រាស់ការសិក្សាតាមប្រព័ន្ធ E-Learning និងការអភិវឌ្ឍសម្ថភាពស្ថាប័ន ដែលផ្តោតលើគ្រូបង្រៀន។ លើសពីនេះទៅទៀតក្នុងគោលដៅរបស់ក្រសួងអប់រំ យុវជន និងកីឡា ក៏បានដាក់គោលដៅលើ បច្ចេកវិទ្យាដើម្បីឲ្យក្លាយជាឧបករណ៍សម្រាប់បង្រៀន និងរៀន និងចែករំលែកចំណេះដឹងក្នុងវិស័យអប់រំ ដើម្បីធ្វើអន្តរកាលទៅរកពិភពការងារក្នុងសតវត្សទី២១។

ការបំប៉នសមត្ថភាពគ្រូបង្រៀនដែលកំពុងបង្រៀននៅក្នុងសាលាមធ្យមសិក្សាធនធាន សមត្ថភាពគ្រូបង្រៀនទៅលើផ្នែកបច្ចេកវិទ្យា និងទំនាក់ទំនង-ICT ពិតជាមានសារៈសំខាន់។ ការអភិវឌ្ឍសមត្ថភាពគ្រូអោយមានចំណេះដឹងក្នុងការប្រើសម្ភារៈឧបទេសដែលសាលាធនធានមានស្រាប យកមកប្រើប្រាសឱ្យអស់លទ្ធភាព ដើម្បីឆ្លើយតបអនុវត្តទៅតាមគោលនយោបាយសាលាធនធាន ដើម្បីបំពេញទៅលើធនធានគ្រូបង្រៀន ដែលពុំទាន់មិនមានសមត្ថភាពឆ្លើយតបទៅនឹងបរិបទបច្ចេកវិទ្យា ការវិវត្តន៍របស់បច្ចេកវិទ្យាលើកញ្ចប់សមត្ថភាពគ្រូបង្រៀន ដើម្បីអោយគ្រូមានសមត្ថភាពក្នុងការប្រើប្រាស់សម្ភារៈរូបវន្ត និងឧបករណ៍បច្ចេកទេសនានា តាមរយៈការប្រើប្រាស់ប្រព័ន្ធព័ត៌មាន នឹងត្រូវបានប្រើប្រាស់កាន់តែច្រើន និងមានភាពភាពងាយស្រួលក្នុងការចាប់យក ការផ្សាភ្ជាប់មុខវិជ្ជាជីវៈ ការផ្ទេរចំណេះដឹង និងអនុវត្តដាក់ស្តែង។ ដោយបានអភិវឌ្ឍសមត្ថភាពគ្រូបង្រៀនតាមរយៈការប្រើប្រាស់បច្ចេកវិទ្យា ការអនុវត្តសម្ភារៈឧបទេស ការអនុវត្តវិធីសាស្ត្រថ្មីៗជាដើម។ យោងតាម Koehler and Mishra (2009) សម័យឌីជីថលគ្រូត្រូវមានកញ្ចប់សមត្ថភាពដែលមាន ចំណេះដឹងសំខាន់ៗចំនួន ៣ ដូចជា៖ ១) ចំណេះដឹងបច្ចេកវិទ្យា ២) ចំណេះដឹងខ្លឹមសារមេរៀន និង៣) ចំណេះដឹងគរុកោសល្យ។

មួយវិញទៀតគេក៏ប្រើប្រាស់បច្ចេកវិទ្យាក្នុងការគ្រប់គ្រង និងដំណើរការព័ត៌មាន រួមមានបច្ចេកវិទ្យាផ្សេងៗសម្រាប់រៀបចំ គ្រប់គ្រង និងបង្កើតទំនាក់ទំនងផ្នែកព័ត៌មានផ្សេងៗផងដែរ។ ពិសេសជាងនេះទៀតចំណេះដឹងបច្ចេកវិទ្យា៖ ក៏ជាកាតាលិករក្នុងការលើកទឹកចិត្ត ឱ្យគ្រូទទួលយកនូវចំណេះដឹងថ្មី ក្នុង

គន្លងអាជីព (តាមរយៈការច្នៃប្រឌិត គំនិតនវានុវត្តន៍) អាចអនុវត្តតាមស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន ផ្តល់ភាពសម្បូរបែបដល់តម្រូវការសិស្ស និងចូលរួមគាំទ្រ ការអនុវត្តគោលនយោបាយគ្រូបង្រៀន។

ដូចគ្នានេះដែរគោលនយោបាយ និងយុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ ដែលមានខ្លឹមសារ និងផ្តោតការយកចិត្តទុកដាក់ចំពោះផែនសំខាន់ៗចំនួន៤ផែនសំខាន់ៗ ដែលផែនទី៤បានសង្កត់ធ្ងន់ទៅលើការប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និងសារគមនាគមន៍ ដើម្បីលើកកម្ពស់ផលិតភាព ភាពស័ក្តិសិទ្ធិ និងប្រសិទ្ធភាពការបង្រៀន និងរៀន។ (អយក, ២០០៤)។

ដូច្នេះការប្រើប្រាស់បច្ចេកវិទ្យាអប់រំបានក្លាយជារឿងសំខាន់សម្រាប់អ្នកសិក្សានាពេលបច្ចុប្បន្ននេះ ព្រោះវាផ្តល់ឱ្យពួកគេនូវឱកាសដើម្បីរៀនក្នុងល្បឿនលឿនជាងដែលពួកគេចង់បាន។

# ជំពូកទី៥៖ សេចក្ដីសន្និដ្ឋាន និងសំណូមពរ

## ៥.១ សេចក្ដីសន្និដ្ឋាន

តាមរយៈលទ្ធផលនៃការសិក្សាស្រាវជ្រាវបានបង្ហាញពីកម្រិតមធ្យមពិន្ទុនៃកម្រិតសមត្ថភាព របស់អ្នកចូលរួមដែលជាគ្រូបង្រៀននៅសាលាមធ្យមសិក្សាធនធានដែលក្នុងចំណោមជំនាញសមាសភាពទាំង៣ផ្នែកសំខាន់ៗដែលអ្នកចូលរួមបានវាយតម្លៃ ជាលទ្ធផលបញ្ជាក់ថា ការអភិវឌ្ឍសមត្ថភាពគ្រូនៅសាលាមធ្យមធនធានស្ថិតក្នុងកម្រិតមធ្យមនៅឡើយ ដែលមានមធ្យមពិន្ទុស្មើនឹង ៣.២៥។ ស្របគ្នានេះដែរ ការយល់ដឹងទៅលើផ្នែកបច្ចេកវិទ្យា ដែលអ្នកចូលរួមខ្សោយ ព្រោះកម្រិតមធ្យមភាគទាបជាង៣.០ ដែលរួមមាន៨ជំនាញដែលក្នុងនោះមានដូចជា ការដោះស្រាយបញ្ហាបច្ចេកទេសកុំព្យូទ័របានដោយខ្លួនឯង ការយល់ដឹងពីមូលដ្ឋាននៃផ្នែករឹងនិងផ្នែកទន់របស់កុំព្យូទ័រ ការប្រើប្រាស់ម៉ាស៊ីនបញ្ចាំងស្លាយក្នុងដំណើរការបង្រៀនការប្រើប្រាស់កុំព្យូទ័រ ការប្រើប្រាស់កម្មវិធីWord ការប្រើប្រាស់កម្មវិធីExcel ការប្រើប្រាស់កម្មវិធីPowerPoint អាចប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីរក្សាទុកទិន្នន័យ (Cloud, Flash Drive) ការបង្រៀនដោយបញ្ចូលបច្ចេកវិទ្យាគឺមានភាពងាយស្រួល បានតាមដានជាប្រចាំនូវការវិវត្តន៍នៃបច្ចេកវិទ្យា អាចប្រើកាមេរ៉ាឌីជីថល Digital Camera ដែលអ្នកចូលរួមមានកម្រិតទាប។

តាមរយៈលទ្ធផលនេះផងដែរ ក៏បានបង្ហាញពីកម្រិតសមត្ថភាពផ្នែកបច្ចេកវិទ្យា របស់អ្នកចូលរួមជាលទ្ធផលបានបង្ហាញថាមាន២ជំនាញដែលអ្នកចូលរួមខ្លាំង ព្រោះមធ្យមភាគមានចាប់ពី៣.០ឡើងដែលរួមមាន អាចប្រើអ៊ីនធឺណិតក្នុងទំនាក់ទំនងការងារប្រចាំថ្ងៃ ចូលចិត្តប្រើប្រាស់បណ្ដាញសង្គមក្នុងការរស់នៅ និងទំនាក់ទំនង (Facebook, Telegram)។ ក្នុងចំណោមជំនាញទាំង២ដែលអ្នកចូលរួមខ្លាំងគឺមានការប្រើប្រាស់Messenger និងការប្រើប្រាស់Telegram ដែលអ្នកចូលរួមមានជំនាញខ្លាំងជាងគេ។

អ្នកសិក្សាស្រាវជ្រាវសង្ឃឹមថា ការសិក្សាស្រាវជ្រាវនេះ អាចជំរុញ និងលើកទឹកចិត្តដល់គ្រប់ភាគីពាក់ព័ន្ធទាំងអស់ឱ្យចូលរួមយ៉ាងសកម្មក្នុងការបំពេញការងាររៀងៗខ្លួនឱ្យបានល្អ ឆ្លើយតបទៅនឹងបដិវត្តកម្មឌីជីថល ដើម្បីបង្កើតបានសមិទ្ធផល គុណភាពអប់រំ និងលទ្ធផលការសិក្សារបស់សិស្សកាន់តែមានភាពល្អប្រសើរឡើង សមស្របទៅនឹងកំណែទម្រង់គុណភាពរបស់គ្រូបង្រៀន ដើម្បីឱ្យសិស្សទទួលបាន

លទ្ធផលល្អឆ្លើយតបទៅនឹងតម្រូវការសង្គមជាតិ និងសម្រេចលទ្ធផលបានជោគជ័យ គ្រប់គ្រងដែលធ្វើឱ្យប្រព័ន្ធនៃការអប់រំរីកចម្រើនសម្រាប់សង្គម ក៏ដូចជាប្រទេសជាតិទាំងមូលជានិច្ចនិរន្តរ៍។

## ៥.២ សំណូមពរ

យោងតាមការរកឃើញ អ្នកសិក្សាស្រាវជ្រាវ សូមលើកឡើងនូវគំនិតយោបល់ ព្រមទាំងសំណូមពរមួយចំនួនសម្រាប់ភាគីពាក់ព័ន្ធ ដើម្បីចូលរួមលើកកម្ពស់សមត្ថភាពរបស់គ្រូបង្រៀន ឱ្យកាន់តែប្រសើរជាងនេះដូចជា៖

- **ក្រសួងអប់រំ យុវជន និងកីឡា**

❖ គួររៀបចំត្រួតពិនិត្យ និងតាមដានទៅលើការអនុវត្តទៅលើការប្រើប្រាស់សាលាមធ្យមសិក្សា អោយបានទៀងទាត់និងច្បាស់លាស់។

❖ ចូលរួមជួយទាំងកិច្ចសហការ ទាំងផ្នែកធនធានសម្ភារ និងបច្ចេកទេសនានា ដើម្បីឆ្លើយតបទៅនឹងតម្រូវការដែលថ្នាក់សាលា។

- **មន្ទីរអប់រំ យុវជន និងកីឡា**

❖ គួរចូលរួមលើផ្សព្វផ្សាយគោលនយោបាយ កិច្ចសហប្រតិបត្តិការនានា ដែលក្រសួងបានដាក់ចេញ

❖ គួរធ្វើសំណើគ្រូបង្រៀនទៅតាមឯកទេសដល់សាលារៀន ដែលខ្វះពិតប្រាកដ ដើម្បីបំពេញតម្រូវការចាំបាច់របស់សាលារៀន។

- **គណៈគ្រប់គ្រងសាលា**

❖ ផ្តល់ការលើកទឹកចិត្ត ជំរុញ និងផ្តល់ឱកាស ដល់គ្រូបង្រៀន ឱ្យបានទូលំទូលាយលើការងារផ្សេងៗ ជាពិសេសទៅលើការលើកកម្ពស់សមត្ថភាពនានា។

❖ ធ្វើផែនការប្រតិបត្តិប្រចាំឆ្នាំ ដោយបញ្ចូលការអភិវឌ្ឍសមត្ថភាពគ្រូ ទៅក្នុងផែនការសកម្មភាពដែលត្រូវអនុវត្តជាប្រចាំ។

- **គ្រូបង្រៀន**

❖ គួរបន្តការគោរពតួនាទី ភារកិច្ច ជាបុគ្គលិកអប់រំដោយមិនមានការមើលបំណាំគ្នា ពីភាពអសកម្មរបស់គ្រូដទៃ

❖ គួរតែបន្តពង្រឹង និង ពង្រីកចំណេះដឹងបន្ថែមទៀតឱ្យមានភាពទូលំទូលាយ ជាពិសេសការប្រើប្រាស់បច្ចេកវិទ្យា ក្នុងការបង្ហាត់បង្រៀនសិស្ស និងកិច្ចការរដ្ឋបាល ឱ្យស្របទៅតាមបរិបទថ្មីសតវត្សទី២១លើក្របខណ្ឌសមត្ថភាពគ្រូបង្រៀនឌីជីថល។

- **សម្រាប់ការសិក្សាស្រាវជ្រាវបន្ត**

ការសិក្សាស្រាវជ្រាវមួយនេះ នៅតាមតែវិទ្យាល័យធនជានក្នុងទីប្រជុំជន ក្នុងក្រុង-ស្រុកចំនួន៣ ក្នុងខេត្តកណ្តាលប៉ុណ្ណោះ ដូចនេះលទ្ធផលដែលរកឃើញអាចនៅមានចន្លោះប្រហោងនៅឡើយ។ ហេតុនេះអ្នកសិក្សាស្រាវជ្រាវក្រោយៗ ដែលមានបំណងចង់សិក្សាលើប្រធានបទមួយ គួរតែពង្រីកដែនកំណត់ និងវិសាភាពអោយបានធំជាងនេះ បើចង់សិក្សានៅក្នុងខេត្តកណ្តាលដដែល។ ក្រៅពីនេះអ្នកសិក្សាស្រាវជ្រាវក្រោយៗ ក៏អាចយកប្រធានបទនេះ ទៅសិក្សានៅតាមតំបន់ទីប្រជុំជន និងជនបទតាមបណ្តាលខេត្តនានាផងដែរ ដោយសារស្ថានភាពសមត្ថភាពគ្រូនៅទីនោះអាចមានភាពខុសគ្នាឆ្ងាយ ពីស្ថានភាពសមត្ថភាពគ្រូដែលនៅក្នុងសាលាមធ្យមសិក្សាធនជាន នៅក្នុងខេត្តកណ្តាល។

# ឯកសារយោង

ក្រសួងអប់រំយុវជន និងកីឡា (២០០៤). *គោលនយោបាយ និងយុទ្ធសាស្ត្រប្រើប្រាស់បច្ចេកវិទ្យា ព័ត៌មាន និង សារគមនាគមន៍ក្នុងការអប់រំនៅកម្ពុជា*. ភ្នំពេញ.

ក្រសួងអប់រំយុវជន និងកីឡា (២០០៨). *គោលនយោបាយស្តីពីសាលាមធ្យមសិក្សាធនធាន របស់នាយកដ្ឋានមធ្យមសិក្សាចំណេះទូទៅ*. ភ្នំពេញ.

ក្រសួងអប់រំយុវជន និងកីឡា (២០១០). *ផែនការគោលបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំ*. ភ្នំពេញ.

ក្រសួងអប់រំយុវជន និងកីឡា (២០១៦). *ស្តង់ដាវិជ្ជាជីវៈគ្រូបង្រៀន. នាយកដ្ឋានបណ្តុះបណ្តាលនិងវិក្រឹតការ*.ភ្នំពេញ.

ក្រសួងអប់រំយុវជន និងកីឡា (២០១៨). *គោលនយោបាយនិងយុទ្ធសាស្ត្រស្តីពីបច្ចេកវិទ្យាព័ត៌មាននិងសារគមនាគមន៍ ក្នុងវិស័យអប់រំ*. ភ្នំពេញ.

ក្រសួងអប់រំយុវជន និងកីឡា (២០១៨). *គោលនយោបាយ និងយុទ្ធសាស្ត្រ ស្តីពីបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ ក្នុងវិស័យអប់រំ*. ភ្នំពេញ.

ក្រសួងអប់រំយុវជន និងកីឡា (២០១៩). *បច្ចេកវិទ្យាព័ត៌មានវិទ្យា និងសារគមនាគមន៍ថ្នាក់ទី១១*. ភ្នំពេញ
.

ក្រសួងអប់រំយុវជន និងកីឡា (២០២០). *ការសិក្សាពីចំណេះដឹង ឥរិយាបថ និងការអនុវត្តជាប្រចាំដោយប្រើកុំព្យូទ័របន្ទះ នៅវិទ្យាល័យធនធានសម្រាប់ការរៀន និងបង្រៀន*. ភ្នំពេញ: នាយកដ្ឋានគោលនយោបាយ.

បាឋកថាទិវាគ្រូបង្រៀន(២០២១). *បរិវត្តកម្មឌីជីថលនៃការអប់រំ បំណិនសតវត្សទី២១ និងកំណែទម្រង់វិធីសាស្ត្របង្រៀន(បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន)*.ភ្នំពេញ.

ផែនទីបង្ហាញផ្លូវគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០(ខែកុម្ភៈឆ្នាំ២០១៩). *ស្តីពីការអប់រំនៅកម្ពុជា*. រាជធានីភ្នំពេញ

រាជរដ្ឋាភិបាលកម្ពុជា. (២០២១). *ក្របខណ្ឌគោលនយោបាយ និងសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជា ២០២១-២០៣៥*. ភ្នំពេញ.

Apelgren,(2010). *Pedagogical Competence*, A Swedish perspective on Pedagogical Competence,

Anthony, O. (2012). *Challenges of effective use of ICT* as a tool for implementing the UBE schemes 53rd annual conference of science teachers association of Nigeria.

Dionys,D. (2011).*The Status of ICT in Cambodia in 2011*. Restrieved from: http://www.checkpoint- elearning.com/university/interviews/the-status-of-ict-in-cambodia-in-2011

Koehler, M. J., & Mishra, P. (2009). *What is technological pedagogical content knowledge? Contemporary Issues in Technology and Teacher Education*, 9(1), 60-70.

Richardson, J. W. (2008*). ICT in education reform in Cambodia: Problems, politics, and policies impacting implementation*. Information Technologies & International Development, 4(4), pp-67.

Suciu , (2011).*Pedagogical Competences, International Online Journal of Educational Sciences*, Vol.3, pp.411-423, 2011,

Serkan Unal and Ibrahim Hakki Ozturk,(2012). *Barriers to ICT Integration into Teachers´ Classroom Practices*: Lessons from a Case Study on Social Studies Teachers in Turkey

Syahruddin. (2012). *Teachers Pedagogical Competence in School-Based Management*: Case Study in, A Public Secondary School.

# ឧបសម្ព័ន្ធ

## ឧបសម្ព័ន្ធ«ក»

# កម្រងសំណួរក្នុងការប្រមូលទិន្នន័យ

# សម្រាប់គ្រូបង្រៀននៅសាលាមធ្យមសិក្សាធនធាន ក្នុងខេត្តកណ្តាល

ខ្ញុំបាទឈ្មោះ **កង កុសល** ជានិស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ នៅវិទ្យាស្ថានជាតិអប់រំ កំពុងសរសេរនិក្ខេបបទស្តីពី "**ស្ថានភាពនៃការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ នៅសាលាមធ្យមសិក្សាធនធានក្នុងខេត្តកណ្តាល**" ដើម្បីបញ្ចប់ការសិក្សា។

គោលបំណងនៃកម្រងសំណួរនេះ គឺដើម្បីស្វែងយល់ពី កម្រិតសមត្ថភាពគ្រូបង្រៀន ដែលកំពុងបម្រើការងារនៅក្នុងសាលាមធ្យមសិក្សាធនធាននៅក្នុងខេត្តកណ្តាល និងដើម្បីចូលរួមក្នុងការលើកកម្ពស់សមត្ថភាពគ្រូបង្រៀនអោយកាន់តែប្រសើរ។ ទិន្នន័យប្រមូលបានពីលោក-លោកស្រី ជាបុគ្គលិកអប់រំ មានគោលបំណងយកទៅប្រើប្រាស់ក្នុងការសិក្សាស្រាវជ្រាវ ដើម្បីទទួលបានព័ត៌មានជាក់លាក់យកមកសិក្សាវិភាគ ឆ្លើយតបទៅប្រធានបទខាងលើ។

ទិន្នន័យដែលប្រមូលបាននេះ គឺប្រើសម្រាប់តែការសិក្សាស្រាវជ្រាវនេះតែប៉ុណ្ណោះ។ ក្នុងន័យនេះ សូមលោក-លោកស្រី មេត្តាជួយផ្តល់ព័ត៌មានពិតជាក់ស្តែង ដើម្បីឱ្យខ្ញុំបាទ អាចទទួលបានទិន្នន័យ និងហេតុផលគ្រប់គ្រាន់តាមបែបវិទ្យាសាស្ត្រ ដើម្បីទាញអំណះអំណាងយកមកសិក្សា បកស្រាយទៅលើ ការសរសេរនិក្ខេបបទក្នុងការសិក្សាស្រាវជ្រាវ។

ខ្ញុំបាទសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះចំពោះការចូលរួម របស់លោក/លោកស្រី។

## ផ្នែកទី១៖ព័ត៌មានទូទៅ

ការណែនាំ៖ សូមលោក-លោកស្រី ឆ្លើយសំណួរ និងគូសសញ្ញា(✓) ក្នុងប្រអប់នីមួយៗខាងក្រោមទៅតាមស្ថានភាពជាក់ស្តែងដូចខាងក្រោម។

១. កំពុងបង្រៀនថ្នាក់ទី៖..............................បង្រៀនមុខវិជ្ជា៖..................................................

២. បម្រើការងានៅវិទ្យាល័យឈ្មោះ៖...........................................ឃុំ/សង្កាត់៖.............................

ក្រុង/ស្រុក/ខណ្ឌ៖..................................................ខេត្ត៖.....................................................

៣. ភេទ ☐ ប្រុស ☐ ស្រី

៤. អាយុ ☐ ២០-២៥ ឆ្នាំ ☐ ២៦-៣០ឆ្នាំ ☐ ៣១-៣៥ឆ្នាំ ☐ លើសពី៣៥ឆ្នាំ

៥.កម្រិតវប្បធម៌ ☐ ចប់ថ្នាក់ទី១២ ☐ បរិញ្ញាបត្រ ☐ បរិញ្ញាបត្រជាន់ខ្ពស់ ☐ ផ្សេងៗ

៦. មុខវិជ្ជាឯកទេស៖..........................................................................................................

៧.បទពិសោធន៍ការងារ៖ ☐ ១ ដល់៥ ឆ្នាំ ☐ ៦ ទៅ១០ ឆ្នាំ ☐ ១១ទៅ១៥ ឆ្នាំ ☐ លើសពី១៥ឆ្នាំ

**ផ្នែកទី២៖ កម្រិតសមត្ថភាព និងជំនាញរបស់គ្រូ**

ការណែនាំ៖ ដើម្បីឆ្លើយតបទៅបរិបទនៃការរីកចម្រើនក្នុងសម័យឧស្សាហកម្ម ៤.០ ក៏ដូចជាការធ្វើដំណើរឆ្ពោះទៅរកសង្គមឌីជីថល និងសេដ្ឋកិច្ចឌីជីថលគ្រូពិតជាមានតួនាទីសំខាន់ណាស់ក្នុងការជានាផ្តល់អប់រំកាន់តែប្រសើរឡើង ដោយទំនួលខុសត្រូវ ប្រកបដោយសមត្ថភាព និងជំនាញច្បាស់លាស់។ សូមអាន ឃ្លាខាងក្រោមអោយបានច្បាស់លាស់ ជ្រើសរើសកម្រិតសូចនាករ ដែលឆ្លុះបញ្ចាំងពីគំរូនៃសមត្ថភាព និងជំនាញ ដែលលោកគ្រូ-អ្នកគ្រូយល់ដឹងទៅតាមកម្រិតចង្អុលបង្ហាញ រួចគូស សញ្ញា (✓)ក្នុងប្រអប់នីមួយៗ។ សូមធ្វើការគូសយកក្នុងកម្រិតណាមួយដែលទាក់ទងនឹងស្ថានភាពបច្ចុប្បន្ន នៃគំរូនៃការអភិវឌ្ឍសមត្ថភាពបុគ្គលិកអប់រំ នៅក្នុងសាលាមធ្យមធនជានក្នុងខេត្តកណ្តាល។

សូមចូលរួមផ្តល់ការគាំទ្រក្នុងការ បំពេញចម្លើយ នូវរាល់គ្រប់សំណួរខាងក្រោម ស្របតាមការយល់ដឹងរបស់លោកគ្រូ-អ្នកគ្រូ។

**កម្រិតនៃការយល់ដឹង:**

១ = ខ្ញុំមិនចេះសោះ (I do not know)

២ = ខ្ញុំចេះដឹងខ្លះៗ (I know in low level)

៣ = ខ្ញុំចេះដឹងក្នុងកម្រិតមធ្យម (I know in middle level)

៤ = ខ្ញុំចេះដឹងក្នុងកម្រិតល្អ(I know in good level)

៥ = ខ្ញុំចេះដឹងក្នុងកម្រិតល្អប្រសើរ (I know in very good level)

| ល.រ | បរិយាយ | កម្រិត | | | | |
|---|---|---|---|---|---|---|
| | | ១ | ២ | ៣ | ៤ | ៥ |
| ក. ចំណេះដឹងផ្នែកបច្ចេកវិទ្យា | | | | | | |
| ១ | អាចដោះស្រាយបញ្ហាបច្ចេកទេសកុំព្យូទ័របានដោយខ្លួនឯង | | | | | |
| ២ | យល់ដឹងពីមូលដ្ឋាននៃផ្នែករឹង និងផ្នែកទន់របស់កុំព្យូទ័រ | | | | | |
| ៣ | ការបង្រៀនដោយបញ្ចូលបច្ចេកវិទ្យា គឺមានភាពងាយស្រួល | | | | | |
| ៤ | បានតាមដានជាប្រចាំនូវការវិវត្តន៍នៃបច្ចេកវិទ្យា | | | | | |
| ៥ | អាចប្រើប្រាស់កម្មវិធីរដ្ឋបាលថ្នាក់រៀន( Word, Excel, Power Point ) | | | | | |
| ៦ | អាចប្រើអ៊ីនធឺណិតក្នុងទំនាក់ទំនងការងារប្រចាំថ្ងៃ | | | | | |
| ៧ | ចូលចិត្តប្រើប្រាស់បណ្តាញសង្គមក្នុងការរស់នៅ និងទំនាក់ទំនង ( Facebook, Telegram ) | | | | | |
| ៨ | អាចប្រើប្រាស់កម្មវិធីកុំព្យូទ័រដើម្បីរក្សាទុកទិន្នន័យ ( Cloud, Flash Drive ) | | | | | |
| ៩ | អាចប្រើប្រាស់ម៉ាស៊ីនបោះពុម្ព និងស្កេន | | | | | |
| ១០ | អាចប្រើប្រាស់ម៉ាស៊ីនបញ្ចាំងស្លាយក្នុងដំណើរការបង្រៀន | | | | | |
| ១១ | អាចប្រើកាមេរ៉ាឌីជីថល Digital Camera | | | | | |
| ខ. ចំណេះដឹងផ្នែកគរុកោសល្យ | | | | | | |
| ១ | ពីរបៀបវាយតម្លៃលើលទ្ធផលរបស់សិស្សក្នុងថ្នាក់រៀន | | | | | |
| ២ | វាយតម្លៃការសិក្សារបស់សិស្សតាមវិធីជាច្រើន | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៣ | កែសម្រួលការបង្រៀនរបស់ខ្ញុំដោយផ្អែកលើអ្វីដែលសិស្សយល់ឬមិនយល់ | | | | | |
| ៤ | ការប្រើប្រាស់វិធីសាស្ត្រនិងបច្ចេកទេសវាយតម្លៃផ្សេងៗគ្នាក្នុងការបង្រៀន | | | | | |
| ៥ | ការអនុវត្តទ្រឹស្តី និងវិធីសាស្ត្រសិក្សាផ្សេងៗគ្នា ក្នុងការរៀន និងបង្រៀន | | | | | |
| ៦ | ប្រើប្រាស់វិធីសាស្ត្រផ្សេងៗគ្នា ចំពោះសិស្សផ្សេងៗគ្នា ក្នុងការបង្រៀន និងរៀន | | | | | |
| ៧ | អាចស្វែងយល់ពីតម្រូវការសិក្សារបស់សិស្ស | | | | | |
| ៨ | អាចយល់ពីឥរិយាបទក្នុងការស្តែងឡើងរបស់សិស្សក្នុងការសិក្សា | | | | | |
| ៩ | អាចរៀបរាប់បានពីរបៀបសិក្សាផ្សេងៗគ្នា និងជាប់ដោយឡែករបស់សិស្ស | | | | | |
| ១០ | អាចពន្យល់ពីភាពខុសគ្នានៃសម្បទាសិក្សារបស់សិស្ស | | | | | |
| ១១ | អាចពន្យល់បានពីភាពខុសគ្នា នៃល្បឿនសិក្សារបស់សិស្ស | | | | | |
| **គ.ចំណេះដឹងផ្នែកខ្លឹមសារមេរៀន** | | | | | | |
| ១ | ពណ៌នាបានពីគោលនយោបាយអប់រំជាតិ និងគោលដៅអប់រំជាតិនានា.. | | | | | |
| ២ | ពណ៌នាបានពីវិធីដែលធ្វើអោយសម្រេចបាននូវគោលនយោបាយអប់រំជាតិ និងគោលដៅជាតិនានា.. | | | | | |
| ៣ | យល់ពីខ្លឹមសារ វត្ថុបំណង ពាក្យគន្លឹះក្នុងមេរៀន | | | | | |
| ៤ | ពណ៌នាពីវត្ថុបំណង និងរៀបចំសកម្មភាពបានត្រឹមត្រូវ | | | | | |

| | | | | | | |
|---|---|---|---|---|---|---|
| ៥ | ពណ៌នាបានពី សម្ភារបង្រៀន និងរៀនសមស្រប សម្រាប់ប្រើប្រាស់ | | | | | |
| ៦ | អភិវឌ្ឍសកម្មភាពថ្នាក់រៀន និងគម្រោងក្នុងការបង្រៀន | | | | | |
| ៧ | តាមដានពីការវិវឌ្ឍន៍ និងកម្មវិធីថ្មីៗនៅក្នុងមុខវិជ្ជារបស់ខ្ញុំ | | | | | |
| ៨ | គូសបញ្ជាក់ពីខ្លឹមសារ និងកម្មវិធីបានច្បាស់លាស់ | | | | | |
| ៩ | ការបញ្ជ្រាបខ្លឹមសារពីមុខវិជ្ជាមួយទៅមុខវិជ្ជាផ្សេងទៀត | | | | | |
| ១០ | ការតាមដានធនធានថ្មី ៗ (ឧ.សៀវភៅ, ទិនានុប្បវត្តិ...) | | | | | |
| ១១ | តាមដាននូវសន្និសីទ និងសកម្មភាពពាក់ព័ន្ធខ្លឹមសារមេរៀនរបស់ខ្ញុំ | | | | | |

មតិយោបល់បន្ថែម៖

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

.....................................................................................................................................

សូមអរគុណ

## ឧបសម្ព័ន្ធ«ខ»

| ទិន្នន័យទទួលបានពីគ្រូបង្រៀនលើព័ត៌មានទូទៅ | | | | |
|---|---|---|---|---|
| លរ. | បរិយាយ | | សរុបរួម | |
| | | | ចំនួន(នាក់) | ភាគរយ(%) |
| ១ | ជាគ្រូបង្រៀន | បង្រៀននៅកម្រិតឧត្តម | 98 | 54.5 |
| | | បង្រៀននៅកម្រិតមូលដ្ឋាន | 82 | 45.5 |
| | | **សរុប** | **180** | **100** |
| ២ | ភេទ | ស្រី | 92 | 51.1 |
| | | ប្រុស | 88 | 48.9 |
| | | **សរុប** | **180** | **100** |
| ៣ | អាយុ | ២០-២៥ ឆ្នាំ | 6 | 3.3 |
| | | ២៦-៣០ ឆ្នាំ | 14 | 7.8 |
| | | ៣១-៣៥ ឆ្នាំ | 52 | 28.9 |
| | | លើសពី៣៥ ឆ្នាំ | 108 | 60 |
| | | **សរុប** | **180** | **100** |
| ៤ | កម្រិតវប្បធម៌ | ចប់ថ្នាក់ទី១២ | 12 | 6.66 |
| | | បរិញ្ញាបត្រ | 136 | 75.6 |
| | | បរិញ្ញាបត្រជាន់ខ្ពស់ | 19 | 10.6 |
| | | ផ្សេងៗ | 13 | 7.22 |
| | | **សរុប** | **180** | **100** |
| | | ១ ដល់ ៥ឆ្នាំ | 12 | 6.7 |

| | | | | |
|---|---|---|---|---|
| ៥ | បទពិសោធន៍បង្រៀន | ៦ ដល់ ១០ឆ្នាំ | 25 | 13.9 |
| | | ១១ ដល់ ១៥ឆ្នាំ | 59 | 32.8 |
| | | លើសពី១៥ឆ្នាំ | 84 | 46.7 |
| | | **សរុប** | **180** | **100** |
| ៦ | មុខវិជ្ជាឯកទេស | ភាសាខ្មែរ | 42 | 23.3 |
| | | ភាសាបរទេស | 12 | 6.7 |
| | | គណិតវិទ្យា | 32 | 17.8 |
| | | វិទ្យាសាស្ត្រពិត | 42 | 23.3 |
| | | វិទ្យសាស្ត្រសង្គម | 52 | 28.9 |
| | | **សរុប** | **180** | **100** |

# ឧបសម្ព័ន្ធ«គ»
# លិខិតបទដ្ឋានគតិយុត្ត និងឯកសារពាក់ព័ន្ធ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខ: ២៣៤១ អយក.វដក

ថ្ងៃ សុក្រ ១៣ កើត ខែ ចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែ មេសា ឆ្នាំ២០២២

**ជម្រាបជូន**
**លោក លោកស្រីប្រធានមន្ទីរអប់រំ យុវជន និងកីឡា រាជធានី ខេត្ត**

**កម្មវត្ថុ៖** ការចុះប្រមូលទិន្នន័យ ដើម្បីសរសេរនិក្ខេបបទបញ្ចប់ការសិក្សារបស់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩។

**យោង៖** - បទប្បញ្ញត្តិស្តីពីការបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រប់អប់រំ នៅវិទ្យាស្ថានជាតិអប់រំ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។
- ផែនការអនុវត្តកម្មវិធីបណ្តុះបណ្តាលថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩និងទី១០ ឆ្នាំសិក្សា២០២១-២០២២ ចុះថ្ងៃទី១៥ ខែវិច្ឆិកា ឆ្នាំ២០២១។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជម្រាប លោក លោកស្រីប្រធាន ជ្រាបថា៖ និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំជំនាន់ទី៩ ចំនួន៥៨នាក់ នឹងចុះប្រមូលទិន្នន័យនៅតាមរាជធានីខេត្តនានា ដើម្បីសរសេរនិក្ខេបបទស្រាវជ្រាវបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ផ្នែកគ្រប់គ្រងអប់រំ នៅវិទ្យាស្ថានជាតិអប់រំ ពីថ្ងៃទី០២ ខែឧសភា ឆ្នាំ២០២២ រហូតដល់ថ្ងៃទី៣០ ខែកក្កដា ឆ្នាំ២០២២។

អាស្រ័យហេតុនេះ សូម លោក លោកស្រីប្រធាន ជួយសម្រួល និងសហការដល់ការចុះប្រមូលទិន្នន័យខាងលើឱ្យមានប្រសិទ្ធភាពខ្ពស់។

សូម លោក លោកស្រីប្រធាន ទទួលនូវការរាប់អានដ៏ស្មោះពីខ្ញុំ។

**រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**

បណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន

**ចម្លងជូន៖**
- អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យឯកឧត្តមបណ្ឌិតសភាចារ្យរដ្ឋមន្ត្រី "ដើម្បីជូនជ្រាបជាព័ត៌មាន"
- អង្គភាពក្រោមឱវាទក្រសួងអយក "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វិទ្យាស្ថានជាតិអប់រំ


Scanned with CamScanner

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

## កម្មវិធីចុះប្រមូលទិន្នន័យតាមវិទ្យាល័យធនធានក្នុងខេត្តកណ្ដាល

| ក្រុង/ស្រុក | វិទ្យាល័យ | ចំនួន(គ្រូ)សំណាក | កាលបរិច្ឆេទចុះប្រមូលទិន្នន័យ | ផ្សេងៗ |
|---|---|---|---|---|
| តាខ្មៅ | វិទ្យាល័យហ៊ុន សែន សេរីភាព | 50 | 27-28/07/2022 | |
| កោះធំ | វិទ្យាល័យ ហ៊ុន សែន កោះធំ | 50 | 28-29/07/2022 | |
| ពញាឮ | វិទ្យាល័យទេពប្រណម្យ | 50 | 30/07/2022 | |

ថ្ងៃព្រហស្បតិ៍ ៨រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦
កណ្ដាល,ថ្ងៃទី ២១ ខែកក្កដា ឆ្នាំ២០២២

**ហត្ថលេខានិស្សិត**

កង កុសល

**បានឃើញ និងជម្រាបជូន**

-លោកអភិបាលក្រុងតាខ្មៅ ស្រុកកោះធំ ស្រុកពញាឮ «ដើម្បីជូនជ្រាបជាព័ត៌មាន»
-លោកនាយកវិទ្យាល័យ ហ៊ុនសែន សេរីភាព, វិ. ហ៊ុនសែន កោះធំ, វិ. ទេពប្រណម្យ
«ដើម្បីជ្រាប និងសហការ លើការចុះប្រមូលទិន្នន័យ របស់និស្សិត កង កុសល សម្រាប់សរសេរនិក្ខេបបទបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់»
-ឯកសារ កាលប្បវត្តិ

ថ្ងៃចន្ទ ១២រោច ខែអាសាឍ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
កណ្ដាល ថ្ងៃទី ២៥ ខែកក្កដា ឆ្នាំ២០២២
**ប្រធានមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកណ្ដាល**

ចេង សំអ៊ុល

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

វិទ្យាស្ថានជាតិអប់រំ
លេខ: ៣៣៣៥ ខជអ. ស.ក

## លិខិតបញ្ជាប់ការ

យោង៖ -លិខិតឧទ្ទេសនាមលេខ: ៧០២៥ អយក.ឧទន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។
-លិខិតឧទ្ទេសនាមលេខ: ៧០២៦ អយក.ឧទន ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០២២។

បុគ្គលិកអប់រំនៃក្រសួងអប់រំ យុវជន និងកីឡា និងវិទ្យាស្ថានជាតិអប់រំ ដូចមានរាយនាមខាងក្រោម ត្រូវបានចាត់តាំងជា **គណៈកម្មការការពារនិក្ខេបបទបញ្ចប់** សម្រាប់និស្សិតថ្នាក់បរិញ្ញាបត្រជាន់ខ្ពស់ ផ្នែកគ្រប់គ្រងអប់រំ ជំនាន់ទី៩ ដែលនឹងប្រព្រឹត្តទៅនៅថ្ងៃទី៥-៦ ខែវិច្ឆិកា ឆ្នាំ២០២២ នៅវិទ្យាស្ថានជាតិអប់រំ៖

I. **គណៈកម្មការវាយតម្លៃ**

**ក្រុមទី១**

| **ល.រ** | **គោត្តនាម និងនាម** | **អង្គភាព** | **តួនាទី** |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | នី ខាំបូលី | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកស្រីបណ្ឌិត | បូ ច័ន្ទគុលិកា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៣- លោកបណ្ឌិត | ឈាង សង្វាត | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ម៉ន មុនិន្ទ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី២**

| **ល.រ** | **គោត្តនាម និងនាម** | **អង្គភាព** | **តួនាទី** |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | សៀង សុវណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោក | ម៉ៅ សារឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកបណ្ឌិត | ឈិញ នីដា | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៤- លោកបណ្ឌិត | អាន វ៉ុប្រាវ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី៣**

| **ល.រ** | **គោត្តនាម និងនាម** | **អង្គភាព** | **តួនាទី** |
|---|---|---|---|
| ១- លោកបណ្ឌិត | ឈូក ច័ន្ទធាយា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | លី គិមឡុង | សាកលវិទ្យាល័យភូមិន្ទភ្នំពេញ | សមាជិក |
| ៣- លោកបណ្ឌិត | គួយ សុគាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ប៉ូ ប៊ុន្នន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី៤**

| ល.រ | គោត្តនាម និងនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | ជ័យ សារិន | អគ្គាធិការដ្ឋាន | ប្រធាន |
| ២- លោកបណ្ឌិត | ម៉ម ចាន់សៀន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកបណ្ឌិត | សឿ សុផា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ឡុច ចាន់ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី៥**

| ល.រ | គោត្តនាម និងនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១- លោកបណ្ឌិត | អ៊ែ សុងហ៊ាង | មជ្ឈមណ្ឌល SEAMEO TED | ប្រធាន |
| ២- លោក | លឹម វ៉ាន់ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកបណ្ឌិត | ឈិញ ស៊ីថា | អ្នកឯកទេសអប់រំ | សមាជិក |
| ៤- លោកស្រី | សេង សច្ចា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី៦**

| ល.រ | គោត្តនាម និងនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | សិត សេង | វិទ្យាស្ថានគរុកោសល្យភ្នំពេញ | ប្រធាន |
| ២- លោកស្រី | ប៊ុន សុផានី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកស្រីបណ្ឌិត | ឡឹម សុគា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោកបណ្ឌិត | សោម វណ្ណៈ | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី៧**

| ល.រ | គោត្តនាម និងនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១- លោក | ទី បុណ្ណា | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | នី វេង្ហា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកបណ្ឌិត | ឡាយ សុវិជ្ជា | នាយកដ្ឋានគោលនយោបាយ | សមាជិក |
| ៤- លោកបណ្ឌិត | កាង ស៊ុងឆាង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី៨**

| ល.រ | គោត្តនាម និងនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១- លោកបណ្ឌិត | ហេង គ្រេង | នាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ | ប្រធាន |
| ២- លោក | ថៃ ហេង | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកបណ្ឌិត | មាឃ ចាន់ថេង | នាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ | សមាជិក |
| ៤- លោកបណ្ឌិត | មឿន លិនណា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី៩**

| ល.រ | គោត្តនាម និងនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១- លោកបណ្ឌិត | នូវ រីក | វិទ្យាស្ថានជាតិអប់រំ | ប្រធាន |
| ២- លោកបណ្ឌិត | ឈន ថន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោក | ចាប រតនា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ចាន់ ធឿន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

**ក្រុមទី១០**

| ល.រ | គោត្តនាម និងនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១- ឯកឧត្តមបណ្ឌិត | នៀ សុផន | នាយកដ្ឋានបុគ្គលិក | ប្រធាន |
| ២- លោកបណ្ឌិត | អ៊ុំ ចាន់ចំណាន | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៣- លោកស្រី | នូ ចន្ទី | វិទ្យាស្ថានជាតិអប់រំ | សមាជិក |
| ៤- លោក | ចាន់ រ៉ាដា | វិទ្យាស្ថានជាតិអប់រំ | សមាជិក |

II. **លេខាធិការដ្ឋាន**

| ល.រ | គោត្តនាម និងនាម | អង្គភាព | តួនាទី |
|---|---|---|---|
| ១- លោកស្រី | ហង់ ស្រីម៉ាច | វិទ្យាស្ថានជាតិអប់រំ | សម្ភារៈ និងគណនេយ្យ |
| ២- កញ្ញា | យុន គីមរៀង | វិទ្យាស្ថានជាតិអប់រំ | រៀបចំវេទិកា និងប្រមូលពិន្ទុក្រុម១-២ |
| ៣- លោកស្រី | អ៊ុំ សុចិន្តា | វិទ្យាស្ថានជាតិអប់រំ | រៀបចំវេទិកា និងប្រមូលពិន្ទុក្រុម៣-៤ |
| ៤- កញ្ញា | យុន ស៊ីណូត | វិទ្យាស្ថានជាតិអប់រំ | រៀបចំវេទិកានិងប្រមូលពិន្ទុ ក្រុម៥-៦ |
| ៥- លោក | អ៊ិច ផលរដ្ឋ | វិទ្យាស្ថានជាតិអប់រំ | រៀបចំវេទិកា និងប្រមូលពិន្ទុក្រុម៧-៨ |
| ៦- កញ្ញា | ភាព សុខនី | វិទ្យាស្ថានជាតិអប់រំ | រៀបចំវេទិកា និងប្រមូលពិន្ទុក្រុម៩-១០ |
| ៧- លោកស្រី | ឯម សុភាលក្ស្ម៊ី | វិទ្យាស្ថានជាតិអប់រំ | ធ្វើរបាយការណ៍ |
| ៨- លោកស្រី | សុខ វណ្ណា | វិទ្យាស្ថានជាតិអប់រំ | បូកពិន្ទុក្រុម ១-៥ |
| ៩- លោក | ថាច់ សន | វិទ្យាស្ថានជាតិអប់រំ | បូកពិន្ទុក្រុម ៦-១០ |

ថ្ងៃព្រហស្បតិ៍ ១០កើត ខែកត្តិក ឆ្នាំខាល ចត្វាស័ក ព.ស. ២៥៦៦

រាជធានីភ្នំពេញ ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០២២

**នាយកវិទ្យាស្ថានជាតិអប់រំ**

បណ្ឌិត.សៀង សុវណ្ណា

**បានឃើញ និងឯកភាព**

ជ. **ប្រធានគណៈកម្មាធិការកំណែទម្រង់**

បណ្ឌិត ឈួក ច័ន្ទឆាយា

**កន្លែងទទួល៖**

- ការិយាល័យ/ផ្នែកជំនាញនៃវ.ជ.អ.ដែលពាក់ព័ន្ធ "ដើម្បីជ្រាបជាព័ត៌មាន"
- សាមីជន "ដើម្បីអនុវត្ត"
- កាលប្បវត្តិ
- ឯកសារ វ.ជ.អ.